ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Aug-2015, 13:40
CMS/CFO: Sann Rada

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៣១៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក ម៉ាធូវ ម៉ាកាធី
*(Mr. Matthew McCarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ត្រាវីស ហ្វារ
*(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ែន ពៅ | ខ្មែរ |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| លោក ឈុំ សេង (2-TCW-828) | ខ្មែរ |
| លោក តក់ ប៊ុយ (2-TCW-908) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ឈុំ សេខ** (2-TCW-828)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ....................ទំព័រ ៣

សួរដោយលោក អាកទួរ វែកគែន ផ្ដើមពី ....................ទំព័រ ១៤

**ការសួរសំណួរទៅសាក្សី៖ លោក តក់ ម៉ុយ** (2-TCW-908)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ២៦

សួរដោយលោក វ៉ែន ពៅ ផ្ដើមពី ....................ទំព័រ ៣១

សួរដោយលោក ពេជ អង្គ ផ្ដើមពី ....................ទំព័រ ៥២

សួរដោយលោក ត្រាវីស ហ្វារ ផ្ដើមពី ....................ទំព័រ ៥៥

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ឈុំ សេង បញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលរហស្សនាម 2-TCW-908 សូមភាគីជ្រាប។

ហើយក៏សូមជម្រាបជូនផងដែរថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះនិងនៅថ្ងៃស្អែកទី២០ ខែសីហា ឆ្នាំ២០១៥ ដោយមានបញ្ហាខ្វះធនធានអ្នកបកប្រែភាសាផ្ទាល់មាត់ នៅក្នុងកិច្ចដំណើរការសវនាការ ដើម្បីឲ្យកិច្ចដំណើរការពិភាក្សាដេញដោលប្រព្រឹត្តទៅបានល្អ សូមភាគីទាំងអស់និយាយឲ្យបានយឺតៗ តាមដែលអាចធ្វើទៅបាន។ សូមអរគុណ។

ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០០:៣៩]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដី មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺ លោក ឈុំ សេង។ លោក និងមេធាវីប្រឹក្សារបស់លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។

នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-908 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយ

ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[០៩:០១:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ ហើយមិនអាចអង្គុយបានយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោមនេះ។

ដោយផ្អែកលើមូលដ្ឋាននេះ និងផ្អែកតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៣:០៧]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ហើយអាចបន្តដោយក្រុមមេធាវីការពារក្ដី នួន ជា មុន ហើយមុននឹងផ្ទេរវេទិកាទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។

សូមអញ្ជើញបាទ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី សហការី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនតូចទេ ដែលខ្ញុំត្រូវសួរទៅលោកនៅព្រឹកនេះ។ ទី១ ខ្ញុំមានសំណួរពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធកងចល័ត។ ខ្លួនលោកផ្ទាល់បានឆ្លើយប្រាប់មជ្ឈ-មណ្ឌលឯកសារកម្ពុជាថា មានកងតូចបីចំណុះឲ្យ តាវ៉ាល់ -- វរសេនាតូចនោះបី។ តើអ្នកណាជាអ្នកបញ្ជាទៅលើកងវរសេនាតូចទាំងបីនេះ លោកនៅចាំបានទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ក្នុងកងវរសេនាតូចបីកងនេះ គឺមានក្នុងបីវរសេនាតូច គឺមានមួយវរសេនាធំ។ បីវរសេនាតូច មានមួយវរសេនាធំ ក៏ប៉ុន្តែចំពោះវរសេនាធំ ខ្ញុំបាទពុំដឹងថាយ៉ាងណាទេ មិនដឹងថាឈ្មោះអី។ គ្រាន់តែទទួលស្គាល់ថា គឺមានតែត្រឹមវរសេនាតូចប៉ុណ្ណោះទេ។ លើវរសេនាតូចគឺ តាវ៉ាល់ ក្តាប់រួមទាំងអស់។

[០៩:០៥:៣៥]

**ស៖** តាមដែលខ្ញុំយល់នោះ គឺលោកសាក្សី តាវ៉ាល់ គឺជាបុគ្គលដែលក្តាប់រួម ប៉ុន្តែខ្ញុំចាប់អារម្មណ៍បំផុត គឺឈ្មោះមេបញ្ជាការកងវរសេនាតូចទាំងបីនេះ ឬក៏ហៅថាកងចំនួនបី ឬកងវរសេនាតូចទាំងបីនេះ?

**ឆ៖** បាទ វរសេនាតូច បីវរសេនាតូចហ្នឹង គឺត្រូវបានមួយកងវរសេនាធំ ដូចខ្ញុំជម្រាប។ មុនដំបូងគេចាត់តាំងជាក្រុម ចាត់តាំងជាក្រុម ក្នុងមួយក្រុមមាន១០នាក់។ បើនិយាយឲ្យល្អិតទៅ ចាត់តាំងតាំងពីពួកនោះ។ ក្នុងមួយពួកមានបីនាក់ ទាំងមេពួក។ ក្នុងមួយក្រុមមានបីពួក វាគ្រប់១០នាក់ ទាំងប្រធានក្រុម។ ដូច្នេះបីក្រុមត្រូវបានមួយកងអនុសេនាតូច។ បីកងអនុសេនាតូចត្រូវបានមួយកងធំ។ បីកងធំត្រូវបានមួយវរសេនាតូច។ បីវរសេនាតូចត្រូវបានមួយវរសេនាធំ។ បាទ នេះគឺដំណើរការដែលចាត់តាំងរបស់អង្គការនៅតំបន់នោះ។ ក៏ប៉ុន្តែឮតែត្រឹមតែវរសេនាតូចទេ វរសេនាធំមិនដែលឮ។

**ស៖** បាទ ខ្ញុំសូមជួយលោកបន្តិច ដើម្បីស្វែងរកឲ្យឃើញថា តើអ្នកណាជាមេបញ្ជាការនៃ

កងវរសេនាតូចទាំងបីនេះ។ តើត្រឹមត្រូវទេ ដែលថាមេបញ្ជាការកងវរសេនាតូចហ្នឹង គឺឈ្មោះ តារិុត ទី១, ទី២ បញ្ជាដោយ តាប៉ាន់ និងកងវរសេនាតូចទី៣ ត្រូវបានបញ្ជាដោយមនុស្សម្នាក់ដែលខ្ញុំបានបង្ហាញឈ្មោះកាលពីម្សិលមិញ ហើយលោកថា លោកស្គាល់មនុស្សម្នាក់នេះ? ដូច្នេះតើត្រឹមត្រូវទេថា មេបញ្ជាការនៃកងវរសេនាតូចទាំងបី គឺមានឈ្មោះ តារិុត, តាប៉ាន់ និងបុគ្គលដែលខ្ញុំបានបង្ហាញជាឈ្មោះ ទៅលោកកាលពីម្សិលមិញ?

[០៩:០៨:៥១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយសារតែគាត់គ្មានប្រភពណាមួយយកមកដកស្រង់ទាល់តែសោះ ហើយដោយសារតែសាក្សីបាននិយាយហើយថា នៅក្នុងកងវរសេនាតូចមួយ គឺមានតែ តាវន និង តាខូវ ប៉ុណ្ណោះ។ ដូច្នេះ យើងត្រូវដឹងថា តើមេធាវីការពារក្តី គាត់សំដៅទៅលើពេលវេលាណាមួយ នៅពេលដែលគាត់និយាយអំពី តារិុត, តាប៉ាន់ ហើយនិងតាមួយទៀតនោះ ពីព្រោះថាមានការផ្លាស់ប្តូរមេជាបន្តបន្ទាប់ ដោយសារតែមានការចាប់ខ្លួនមេមុនៗ។ ដូច្នេះ សំណួរនេះមិនច្បាស់ទេ ហើយគាត់អាចធ្វើឲ្យសាក្សីភ័ន្តច្រឡំ។ ហើយសាក្សី គាត់បានផ្តល់ឈ្មោះមួយចំនួនហើយ ដូច្នេះយើងអាចចេញពីវរសេនាតូចលេខ១មក ហើយគឺមាន តាវន និង តាខូវ។ នេះជាចម្លើយសាក្សី ដែលគាត់ឆ្លើយពីមុន។ អ៊ីចឹងសូមមេធាវីការពារក្តីបញ្ជាក់អំពីរយៈកាលឲ្យបានច្បាស់ ដើម្បីថាតើជាមេដឹកនាំមួយណាខ្លះនោះ។ ដូច្នេះសំណួររបស់គាត់នេះ នាំឲ្យចម្លើយឆ្លើយទៅមិនច្បាស់លាស់ ហើយនិងមិនមានភាព មិនសូវមានសារៈសំខាន់ចំពោះតុលាការ។

[០៩:១០:១០]

**លោក វិុចទ័រ កូប៉េ៖**

ខ្ញុំនិយាយសំដៅអំឡុងពេលដែល តាវ៉ាល់ គាត់ជាអ្នកគ្រប់គ្រងនៅទីនោះ។ ទី២ ខ្ញុំមិនមែនប្រឌិតឈ្មោះនេះឡើងទេ ខ្ញុំបានឈ្មោះនេះមកពីមជ្ឈមណ្ឌល -- ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា គឺបានឈ្មោះម្នាក់ក្នុងចំណោមឈ្មោះមេបញ្ជាការកងវរសេនាតូចទាំងបី ដែលយ៉ាងហោចនេះក៏សាក្សីរូបនេះ

បានឆ្លើយពីម្សិលមិញថា គាត់បានស្គាល់មនុស្សម្នាក់នេះយ៉ាងច្បាស់។ ជួនកាលយើងហៅថា កងធំៗ ដឹកនាំដោយ តារិត កងធំមួយទៀតដឹកនាំដោយ តាប៉ាន់ និងកងធំមួយទៀត--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំ -- ដើម្បីបញ្ជាប្រតិចារឹក សូមលោកបង្ហាញពីប្រភពផង។

**លោក វ៉ិចទ័រ កូប៉េ៖**

ឯកសារ E3/9076, ERN អង់គ្លេស 00731161, ខ្មែរ 00728855 ដល់ 56 មិនទាន់មាន ERN ជាភាសាបារាំងទេ លោកស្រីចៅក្រម។ បាទ នេះគឺៗខ្ញុំយោងទៅលើឯកសារដែលមាននៅក្នុងសំណុំរឿង។ លោកប្រធាន ប្រសិនបើណាអនុញ្ញាតឲ្យខ្ញុំបន្តតាំងសំណួរតទៅមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺថាកងវរសេនាតូចទាំង គឺដឹកនាំដោយ តារិត, តាប៉ាន់ និងបុគ្គលដែលយើងបាននិយាយគ្នាកាលពីម្សិលមិញ។ តើអ៊ីចឹងមែនទេ លោកសាក្សី?

[០៩:១១:៥៥]

**លោក ឈុំ សេង៖**

**ឆ៖** បាទ ចំពោះឈ្មោះ វ៉ិត បាទឈ្មោះដែលនៅក្នុងនេះគឺខ្ញុំស្គាល់ទាំងអស់ ក៏ប៉ុន្តែដោយឡែក គឺខ្ញុំមិនដឹងថាជាតួនាទីគេធ្វើអី ក៏ប៉ុន្តែខ្ញុំដឹងថា គេជាកម្មាភិបាលមួយរូបនៅក្នុងកងចល័តតំបន់។ តែបើឲ្យខ្ញុំដឹងថា គេជាមានឋានៈជាអីៗ គឺខ្ញុំមិនដឹង។ ខ្ញុំដឹងតែត្រឹមកងវរសេនាតូចរបស់ខ្ញុំ គឺមាន តាខូវ និង តាវន ប៉ុណ្ណោះ តែសម្រាប់កងគេ វរៈរបស់គេខ្ញុំដឹងអត់ដល់ បាទ។

**ស៖** បុគ្គលម្នាក់ដែលខ្ញុំបង្ហាញឈ្មោះឲ្យលោកអានពីម្សិលមិញ គឺជាមនុស្សដែលនិយាយអំពីឈ្មោះ តាវ៉ាល់ និយាយថា តាវ៉ាល់ បានចែកក្រមា បារីទៅឲ្យប្រជាជន លោកបានឆ្លើយដែរថា លោកស្គាល់បុគ្គលម្នាក់ហ្នឹងយ៉ាងច្បាស់។ តើបុគ្គលដែលលោកស្គាល់ឈ្មោះពីម្សិលមិញហ្នឹង គាត់ធ្វើអ្វីដែរក្នុងអំឡុងពេលលើកទំនប់នៅការដ្ឋានត្រពាំងថ្ម?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកជាលោកទី៣ ឈ្មោះដែលនៅនឹងពីរនាក់ហ្នឹង ខ្ញុំស្គាល់ច្បាស់ណាស់។ ក៏ប៉ុន្តែខ្ញុំមិនដឹងថាតួនាទីគេធ្វើអី ក៏ប៉ុន្តែខ្ញុំគ្រាន់តែដឹកថា គេជាកម្មាភិបាលមួយរូប ដែលនៅក្នុងៗនុ៎ង ប៉ុន្តែមិនដឹងជាឋានៈគេជាប្រធានវរៈ ជាប្រធានគោ ប្រធានកងអីម៉េច គឺខ្ញុំអត់ដឹង។ បាទដឹងថាគេជាកម្មាភិបាលមួយរូបហើយនៅក្នុងនោះ ក៏ប៉ុន្តែមិនដឹងឋានៈគេ វាជាប្រធានវរៈ វាជាប្រធានកងធំ ឬ

ក៏អីៗម៉េច ខ្ញុំមិនដឹងទេ។ ពិសេសខ្ញុំច្បាស់តែក្នុងកងខ្ញុំ ក្នុងវរៈរបស់ខ្ញុំប៉ុណ្ណោះ។

[០៩:១៤:០២]

**ស៖** បាទ ខ្ញុំសូមរៀបសំណួរផ្សេងវិញ។ មនុស្សបីនាក់ដែលខ្ញុំទើបលើកឈ្មោះមកនិយាយអម្បាញ់មិញនេះ តើពួកគាត់ហ្នឹងមានឋានៈខ្ពស់ជាងលោក ឬក៏ទាបជាងលោក? លោកចាំទេម្សិលមិញយើងនិយាយអំពីចរនាសម្ព័ន្ធនៃការបញ្ជា។ អ៊ីចឹងសំណួរខ្ញុំតើ តាវិត, តាផន និងមេបញ្ជាការទី៣ មនុស្សទាំងបីនាក់នេះមានឋានន្តរសក្តិ មានបុណ្យស័ក្តិខ្ពស់ជាងលោក ឬក៏ទាបជាងលោក?

**ឆ៖** ខ្ញុំជម្រាបលោកលើកទី៤ ថាខ្ញុំដឹងថាគេកម្មាភិបាលនៅក្នុងជួរហ្នឹងហើយ ក៏ប៉ុន្តែមិនដឹងគេមានឋានៈជាអី មិនដឹងជាប្រធានកងតូច កងធំ ឬក៏ប្រធានវរៈ ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែត្រឹមមួយកងរបស់ខ្ញុំ គឺខ្ញុំដឹង តែដល់កងគេ គឺខ្ញុំពុំបានដឹង។

**ស៖** បាទ មិនថ្វីទេលោកសាក្សី។ នៅពេលឆ្លើយទៅនឹងសំណួរដំបូងរបស់ខ្ញុំ លោកនិយាយថា កងវរសេនាតូច បីវរសេនាតូចវាកើតបានមួយវរសេនាធំ។ តើប្រធានកងវរសេនាធំជាមនុស្សដែលមានឈ្មោះថា តាសាន ហ្នឹងឬក៏មិនមែនទេ?

**ឆ៖** ត្រង់ចំណុចហ្នឹងគឺខ្ញុំអត់ដឹង អត់ស្គាល់។ បើស្គាល់ៗទៅដល់ តាវ៉ាល់ តែម្តង ក្តាប់រួម។ តែកងវរសេនាធំ គឺខ្ញុំមិនដែលឮ ហើយមិនស្គាល់ឈ្មោះទេ។

**ស៖** តើត្រឹមត្រូវដែរឬទេ ឬក៏ថាលោកដឹងរឿងនេះទេថា មេបញ្ជាការកងវរសេនាតូចទាំងបី ឬក៏កងមេកងធំនោះគឺថា ជាអ្នកដែល -- គឺថាមានជំនួយការហ្នឹងជាស្ត្រីធ្វើការនៅឯការដ្ឋានទំនប់ត្រពាំងថ្ម?

[០៩:១៦:២១]

**ឆ៖** បាទ ទាំងអស់រឿងហ្នឹងគឺជារឿងពិត។ សុទ្ធតែមានឈ្មោះហ្នឹង សុទ្ធតែជាអ្នកដែលធ្វើការនៅអាងត្រពាំងថ្ម។ ក៏ប៉ុន្តែដោយឡែក ដូចជាវរសេនាធំឈ្មោះ សាន ឈ្មោះអីហ្នឹង គឺខ្ញុំមិនដែលស្គាល់។ បើឈ្មោះ វិត, ឈ្មោះ ស្រេះ ឈ្មោះអីខ្ញុំស្គាល់ ក៏ប៉ុន្តែមិនដឹងថាតួនាទីគេធ្វើអី។ ប៉ុន្តែខ្ញុំដឹងថាគេជាកម្មាភិបាលមួយរូបនៅក្នុងនោះ នៅក្នុងកងចល័ត ក៏ប៉ុន្តែមិនដឹងជាគេឋានៈរបស់គេជាប្រធានកងតូច កងធំ ប្រធានវរៈ អីខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំស្តាប់ចម្លើយនេះច្បាស់ហើយ តែខ្ញុំសួរផ្សេងនេះថា លោកស្គាល់ឈ្មោះមេបញ្ជាការនារីបីនាក់ ដែលដឹកនាំបញ្ជាកងវរសេនាតូចបីសម្រាប់នារីៗ លោកស្គាល់ទេ?

**ឆ៖** បាទ ពេលនោះខ្ញុំស្គាល់នារីម្នាក់ឈ្មោះ ដែត ជាប្រធានកង ហ្នឹងខ្ញុំស្គាល់មែន ព្រោះពេលនោះគឺខ្ញុំស្នើប្រពន្ធ គឺស្នើនឹងមិត្តនារីហ្នឹងឯង គឺជាប្រធានកង។ ស្គាល់មួយហ្នឹង។

**ស៖** ចុះលោកធ្លាប់ឮឈ្មោះមេបញ្ជាការនារីបីនាក់ ដែលគ្រប់គ្រងកងវរសេនាតូចទាំងបី មួយឈ្មោះ ម៉ៅ, នារីម្នាក់ទៀតឈ្មោះ មិត្ត និងនារីទី៣ ឈ្មោះ គិន។ លោកស្គាល់ឈ្មោះទាំងបីនេះទេ?

**ឆ៖** បាទ ខ្ញុំបាទសូម្បីតែមុខក៏មិនស្គាល់ ឈ្មោះក៏មិនដែលឮ មិនស្គាល់ដែរបាទ។

**ស៖** ឥឡូវខ្ញុំសួរលោកអំពីឈ្មោះ តាវ៉ាល់ ឡើងវិញ ជាពិសេសសួរចំពោះប្រពន្ធរបស់គាត់។ លោកដឹងដែរថាប្រពន្ធ តាវ៉ាល់ ជាអ្នកណាដែរ?

**ឆ៖** ពេលដែល តាវ៉ាល់ លើកផ្ទះនៅនឹងជប់វារីក្នុងស្រុកព្រះនេត្រព្រះ ខ្ញុំបានឃើញប្រពន្ធគាត់ តែមិនដឹងជាឈ្មោះអី ហើយទីលំនៅនៅឯណា។ ខ្ញុំមិនស្គាល់ទេ ប៉ុន្តែស្គាល់ៗដឹងថានេះគឺជាប្រពន្ធ តាវ៉ាល់ តែថាតើ តាវ៉ាល់ ហ្នឹងប្រពន្ធឈ្មោះអី ហើយនៅភូមិ ឃុំ ស្រុក ខេត្តណា គឺខ្ញុំមិនដឹង មិនស្គាល់។

[០៩:១៩:២៧]

**ស៖** ឥឡូវគិតថា លោកមិនស្គាល់ឈ្មោះគាត់ទៅចុះ តែបើសិនខ្ញុំប្រាប់ឈ្មោះប្រពន្ធរបស់គាត់ឈ្មោះ គិន។ បើខ្ញុំប្រាប់ឈ្មោះអ៊ីចឹង តើលោកអាចនឹកឃើញឈ្មោះរបស់ប្រពន្ធ តាវ៉ាល់ នេះទេ?

**ឆ៖** ការពិតទៅ គឺប្រពន្ធ តាវ៉ាល់ ខ្ញុំពុំដែលស្គាល់ឈ្មោះទេ ក៏ប៉ុន្តែមុខបើសព្វថ្ងៃគឺស្ទើរតែមិនស្គាល់ ព្រោះវាជាង៣០ឆ្នាំទៅហើយ។ ដូច្នេះខ្ញុំ ឈ្មោះគឺមិនស្គាល់សោះ បាទ។ ព្រោះប្រពន្ធ តាវ៉ាល់ គឺមិនដែលចុះការដ្ឋានដែរអី គឺនៅតែផ្ទះនៅតែអី ឬក៏ការងារគាត់យ៉ាងណា ខ្ញុំមិនដឹង។ ក៏ប៉ុន្តែពេលដែលខ្ញុំធ្លាប់ចុះឡើងផ្ទះគាត់មួយសាៗហ្នឹង គឺដឹងថានេះគឺប្រពន្ធ តាវ៉ាល់ តែឈ្មោះគឺមិនស្គាល់ បាទអត់ស្គាល់ឈ្មោះ ហើយមិនដឹងថានៅភូមិ ឃុំ ស្រុក ខេត្តណា អត់ដឹងបាទ។

**ស៖** តើលោកធ្លាប់ឮ -- តើលោកដឹងថាឈ្មោះ គិន នេះសព្វថ្ងៃនៅរស់រានទេ?

**ឆ៖** សូម្បីតែឈ្មោះខ្ញុំមិនស្គាល់ ចុះធ្វើម៉េចខ្ញុំបានដឹងថាគេរស់រាន ឬមានជីវិត បើខ្ញុំមិនដែលស្គាល់ទាំងឈ្មោះគេផង ហើយមិនដឹងថាគេនៅភូមិ ឃុំ ស្រុក ខេត្តណាផង។

**ស៖** តើលោកនៅចាំឈ្មោះលេខាស្រីម្នាក់របស់ តាវ៉ាល់ ទេ?

**ឆ៖** បាទ ការពិតទៅ គឺខ្ញុំស្គាល់តែ តាវ៉ាល់ ម្នាក់គត់ ក្រៅពីហ្នឹងគឺខ្ញុំមិនដែលស្គាល់ បាទ ទាំងលេខា ទាំងអី ហើយខ្ញុំក៏មិនដឹងថា តាវ៉ាល់ មានលេខាដែរ។ បាទ អត់ដឹងទេចំណុចហ្នឹង។

[០៩:២១:៤៩]

**ស៖** ពីម្សិលមិញលោកថា លោកជិតស្និទ្ធជាមួយ តាវ៉ាល់ លោកនិយាយទៅកាន់ តាវ៉ាល់ញឹកញាប់ដែរ។ តើស្ត្រីដែលនៅជុំវិញខ្លួនគាត់ហ្នឹង មាននារីម្នាក់ជាប្រជាជនថ្មី គឺថាមានជំនាញក្នុងការងារជួយ តាវ៉ាល់ នេះខ្លាំងណាស់ ឬក៏លោកមិនដែលឃើញនារីនោះទេ?

**ឆ៖** បាទ ចំពោះខ្ញុំមិនអាចកុហកបានទេ ខ្ញុំបានពិតជាបានជិតស្និទ្ធជាងគេជាមួយ តាវ៉ាល់។ ព្រោះដូចជាទៅណាទៅណី ក៏ តាវ៉ាល់ តែងតែប្រើខ្ញុំ ទៅសហករណ៍នេះយកស្ករ ប្រាប់ឲ្យគេនេះធ្វើអីគឺខ្ញុំ។ ក៏ប៉ុន្តែត្រង់កន្លែងដែលផ្ទះគាត់នៅ កន្លែងដែលចំណុចដែលគាត់នៅណេះ គឺខ្ញុំមិនដែលបានចូលមិនដែលបានឃើញ។

**ស៖** លោកដែលឮសូរមនុស្សម្នាក់នៅពេលនោះឈ្មោះថា បងយុក? លោកស្គាល់ទេ?

**ឆ៖** បាទ ខ្ញុំបានពុំដែលស្គាល់ទេបាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំកំពុងតែដូចជាស្ទាក់ស្ទើរបន្តិច។ ឥឡូវនេះខ្ញុំចង់ស្នើសុំការអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញរូបថតទៅសាក្សីមើល ថាតើ យុក ហ្នឹងជាសាក្សីម្នាក់ដែលធ្លាប់បានមកផ្តល់សក្ខីកម្មហើយ ឬក៏យ៉ាងណា? ប្រហែលជាអាចថា គាត់មិនស្គាល់ឈ្មោះទេ ប៉ុន្តែបើបង្ហាញរូបថតទៅ អាចនៅចាំណាំមុខបានមើលទៅ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី កូប៉េ លោកអាចបញ្ជាក់បានទេថា លោកយករូបថតនេះមកពីណា? វាមាននៅក្នុងសំណុំរឿង ឬក៏ជាឯកសារថ្មី? វាជារូបថតយ៉ាងម៉េច? ហើយយើងធ្វើយ៉ាងម៉េច ដឹងថារូបថតហ្នឹងជារូបថតរបស់ បងយុក?

[០៩:២៥:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំក៏មិនច្បាស់១០០ភាគរយដែរ ប៉ុន្តែគ្រាន់តែដឹងថា យុក នេះបានផ្តល់សក្ខីកម្ម មានឈ្មោះ យុក នេះមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ខ្ញុំមានរូបថតដែលសួរទៅឈ្មោះបុគ្គលកាលពីម្សិលមិញ ក៏ដូចរូបថតពីដែលចម្លើយនៃការឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ រូបថតទាំងនេះប្រហែលជាអាចមាននៅក្នុងសំណុំរឿង គឺមានសាក្សីម្នាក់ដែលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីសប្តាហ៍មុន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីឲ្យយល់ច្បាស់ តើវាជារូបថតដែលមាននៅក្នុងបទសម្ភាសន៍នៃសាក្សីមួយដែលមកផ្តល់សក្ខីកម្មនៅទីនេះ ហើយនិងដែលបានឆ្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា ឬក៏យ៉ាងម៉េច? ដូច្នេះ រូបថតហ្នឹងមាននៅក្នុងឯកសាររបស់មជ្ឈមណ្ឌលកម្ពុជាមែនទេ មជ្ឈមណ្ឌលឯកសារកម្ពុជា?

**លោក វិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវហើយលោកចៅក្រម គឺមាននៅក្នុងសំណុំរឿងដែរ គឺឯកសារ E353.1 ជាសេចក្តីសង្ខេបនៃឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា។ ក្នុងនោះក៏មានសួរពាក់ព័ន្ធទៅនឹងទំនប់នេះដែរ និងការសួរពាក់ព័ន្ធទៅដល់ ហើយមនុស្សដែលគេសួរឈ្មោះ ដែលធ្វើការនៅឯការដ្ឋានទំនប់នុំង គឺក៏មានរូបថតពួកគាត់។ ដូច្នេះខ្ញុំគិតថា បុគ្គលដែលខ្ញុំសួរនេះអាចជា បងយុក ឬក៏ បងយុត នេះគឺថាក៏មានរូបថតនៅក្នុងសំណុំរឿងដែរ មើលទៅ។ ពីព្រោះថារូបថត តែកាលណាមានអ្នកណាឆ្លើយជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា គាត់តែងតែថតរូប។

[០៩:២៦:២៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអាន តើឈ្មោះ យុក ហើយនិងរូបថតនេះ លោកគិតយ៉ាងម៉េច បានថាវាមានទំនាក់ទំនងគ្នាពិតជារូបថតរបស់ យុក? យុក ជាឈ្មោះរបស់ម្ចាស់រូបថតហ្នឹង?

**លោក វិចទ័រ កូប៉េ៖**

នៅក្នុងចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ E3/906 -- បាទ E3/9076 យើងមានសាក្សីនៅក្នុង ដែលមកឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះ ក៏មានឈ្មោះ យុក ដែរ។ យ៉ាងហោចណាស់ក៏ខ្ញុំប្រាកដបាន៩០ភាគរយដែរថា ឈ្មោះនេះបានមកផ្តល់សក្ខីកម្ម។ ឥឡូវនេះ យើងមានរូបថតហើយនេះ គឺជាមនុស្សម្នាក់ដែលបានមកចំពោះមុខអង្គជំនុំជម្រះ គឺឯកសារ E353.1, *អ៊ីងគ្លីស* ERN -- បាទ លោកប្រធានសូមការអនុញ្ញាតដើម្បីបង្ហាញរូបថតនេះ ឲ្យសាក្សីមើលថា តើសាក្សីរូបនេះ គាត់ស្គាល់បុគ្គលរូបនេះ ឬក៏អត់?

[០៩:២៧:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៧:៥៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវីការពារក្ដី អាចដាក់រូបថតនេះ មើលអាចពិនិត្យមើលរូបថតនេះបាន។ យើងនឹងដាក់មកលើអេក្រង់មក!

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះ សមមិត្តយុក ឬ យឿក នោះគឺ E3/9076 *អ៊ីងគ្លីស*ERN 007--

**អ្នកបកប្រែ៖**

លោកប្រធានញាប់មែនទែន តាមអត់ទាន់។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ សាជាថ្មីម្ដងទៀត លោកញាប់ពេក អ្នកបកប្រែបកមិនទាន់ទេ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងឱ្យអានឱ្យឃើតបន្ដិច E3/9076, ERN អង់គ្លេស 00731178, ខ្មែរ 00728880។ សាក្សីរូបនេះបាននិយាយថា គឺថា យុក នេះគឺទទួលខុសត្រូវខាងផ្នែកសេដ្ឋកិច្ច គឺជាអ្នកចែកចាយអង្ករ។ ទទួលខាងផ្នែកសេដ្ឋកិច្ចនេះ ដូច្នេះ យុក ឬក៏ យឿក នេះគឺថាជាបុគ្គលនេះហើយ។ បាទ ឥឡូវនេះគឺថា យើងខ្ញុំអាចបង្ហាញរូបគាត់នៅលើអេក្រង់កុំព្យូទ័រហើយ។

[០៩:៣០:២២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងបានឃើញហើយលោកមេធាវី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីលោកនៅស្គាល់មនុស្សម្នាក់នេះទេ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ខ្ញុំស្គាល់ឈ្មោះ យឿក – ឈ្មោះ តាយឿក បាទ។

**ស៖** តើ យឿក នេះមានតួនាទីធ្វើអ្វីដែរនៅឯការដ្ឋានលើកទំនប់នោះ?

**ឆ៖** បាទ ជាប្រចាំខ្ញុំតែងតែឃើញគាត់ដឹកអង្ករៗចែកកងចល័តបាទ។

**ស៖** លោកដឹងថា យឿក មានប្អូនចិញ្ចឹមឈ្មោះ នួន ណារិន្ទ នោះទេ?

**ឆ៖** បាទ ខ្ញុំបាទស្គាល់តែឈ្មោះ យឿក មួយគត់ ដែលធ្លាប់នៅកងចល័ត ក្រៅពីនោះគឺបងប្អូនគាត់ ឬក៏ប្រពន្ធកូនគាត់ ក៏ខ្ញុំមិនដែលស្គាល់ដែរ។

**ស៖** មិនថ្វីទេលោកសាក្សី។ ខ្ញុំបន្តទៅសួរតទៅទៀត ពីម្សិលមិញលោកចាំទេ យើងនិយាយអំពីការសម្លាប់។ លោកនិយាយអំពីការសម្លាប់មនុស្ស១១នាក់ សម្លាប់នៅឯស្ពានទី១ ជិតការដ្ឋានលើកទំនប់នោះ។ ខ្ញុំក៏បានសួរសំណួរជាក់លាក់មួយចំនួនទៅលោកដែរ លោកថា តាវ៉ាល់ ជាអ្នកបញ្ជាឲ្យសម្លាប់មនុស្សទាំង១១នាក់នេះ។ មនុស្សម្នាក់ដែលខ្ញុំបានយកចម្លើយរបស់គាត់ យកមកសំអាងព្រឹកមិញ ហើយដែលលោកស្គាល់យ៉ាងច្បាស់នេះបានឆ្លើយថា នៅពេលធ្វើការនៅឯការដ្ឋានលើកទំនប់ គាត់មិនដែលឃើញខ្មែរក្រហមចាប់មនុស្សយកទៅសម្លាប់ចោលនោះទេ។ វាអាចជាសំណួរដែលពិបាក ប៉ុន្តែតើលោកអាចមានមូលហេតុពន្យល់ទេ ថាហេតុអ្វីបានជាមេបញ្ជាការកងវរសេនាតូចបីនេះ ម្នាក់ក្នុងទាំងបីនេះឆ្លើយថា គាត់មិនដែលឃើញគេចាប់មនុស្សយកទៅសម្លាប់ ឯលោកវិញលោកថា លោកឃើញ?

[០៩:៣៣:២៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

នេះជាវិធីសាស្ត្រមួយដែលមិនសូវត្រឹមត្រូវទេ ដែលគាត់បានប្រើប្រាស់ព័ត៌មាន ដោយមិនដកស្រង់ប្រភព។ គាត់បាននិយាយពីម្សិលមិញមកហើយ ក៏ប៉ុន្តែគួរតែផ្ដល់លេខ ERN ផង។ ទី២ បញ្ហានេះ សំណួរនេះគឺជាសំណួរដូចជាម្សិលមិញអីចឹង គាត់សួរសំណួរទៅនរណាម្នាក់ដើម្បីឲ្យគាត់ឆ្លើយស្មាននូវអ្វីដែលគាត់មិនបានដឹងនោះ។ ដូច្នេះគាត់នៅទីនេះជាសាក្សី ដើម្បីផ្ដល់ព័ត៌មានអំពីអ្វីដែលគាត់បានឃើញ បានស្ដាប់ឮ។ គាត់មិនអាចនិយាយអំពីអ្វីដែលគាត់មិនដឹង មិនឃើញទេ គាត់មិនមែនជាអ្នកជំនាញទេ។ គាត់មិនអាចពន្យល់បានទេ គាត់មិនអាចឆ្លើយដោយស្មានៗ ដោយទាញសេចក្ដីសន្និដ្ឋានអំពីអ្វីដែលអ្នកផ្សេងមិនបានឃើញទេ។ អីចឹងសំណួរនេះជាសំណួរមិនត្រឹមត្រូវទេ លោកប្រធាន សូមឲ្យគាត់ចូលទៅប្រធានបទថ្មី។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ត្រឹមត្រូវ ហើយសាក្សីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះរបស់មេធាវីទេ។ មេធាវីមានសំណួរថ្មីគឺចូលសំណួរថ្មី។

[០៩:៣៥:០៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងព្យាយាមសួរតាមរបៀបផ្សេងវិញ។ ពីម្សិលមិញ លោកនិយាយអំពីការសម្លាប់មនុស្សដែលបានសម្លាប់ដោយតាមរយៈការបញ្ជារបស់ តាវ៉ាល់។ លោកដឹងថា មានអ្នកណាផ្សេងទៀតធ្វើការនៅការដ្ឋានលើកទំនប់ហ្នឹង ដែលដឹងអំពីការសម្លាប់ដូចដែលលោកបានដឹងហ្នឹងទេ?

**លោក ឈុំ សេង៖**

**ឆ៖** រឿងទាំងអស់ហ្នឹង ខ្ញុំមិនអាចសន្និដ្ឋានបានថា អ្នកណាដឹង ឬមិនដឹងទេ។ ជាក់ស្តែងដូចជារូបខ្ញុំ បើដឹងថាដឹង បើមិនដឹងថាមិនដឹង។ ដូចជាលោកបង្ហាញអំមិញ រូបថតថាឈ្មោះស្អីអីណា ខ្ញុំមិនដែល -- ឃើញមុខ ខ្ញុំស្គាល់។ ដូច្នេះខ្ញុំដឹងថាដែលខ្ញុំឃើញតែប៉ុណ្ណោះ តែចំពោះអ្នកដទៃ គឺខ្ញុំមិនមិនដែលដឹងថាឃើញ ឬមិនឃើញនោះទេ។ បើចំពោះខ្ញុំឃើញតែម្តងនេះ ដែលខ្ញុំបានជម្រាបមុន។ ក្រៅពីនោះ គឺខ្ញុំមិនដែលបានឃើញ។

**ស៖** ប៉ុន្តែនៅពេលដែលលោកពង្រាបខ្នងទំនប់ហ្នឹង លោកឃើញសព អាហ្នឹងលោកឃើញលោកឆ្លើយអ៊ីចឹង? លោកឃើញខ្មោចហ្នឹង តើមានអ្នកដទៃទៀតបានឃើញដូចលោកដែរទេ?

[០៩:៣៦:៣៧]

**ឆ៖** ពេលហ្នឹង គឺដែលយកទៅសម្លាប់ចោលនោះ គឺចំកងរបស់ខ្ញុំ ព្រោះកងអ្នកណា គឺអ្នកនោះជាអ្នកពង្រាប។ ហើយដល់វាយហ្នឹង ក៏នៅក្បែរកងខ្ញុំដែរ ដែលយកទៅចោលនោះ ហើយឲ្យពួកពលករនោះរែកយកដីកប់នោះ។ ក៏ប៉ុន្តែខ្ញុំមិនបានឃើញគេវាយផ្ទាល់ភ្នែកទេ ប៉ុន្តែឃើញគេចាប់ ឃើញគេដឹកកាត់ភ្លើងនោះ មនុស្សសុទ្ធតែអត់អាវ ខ្លះមានខោខ្លី មានខោជើងវែងតិចណាស់។ ភាគច្រើន គឺមានតែខោជើងខ្លី។ ដល់យកទៅដាក់នោះ ដល់ខ្ញុំនៅនេះដី គឺសុទ្ធតែអត់អាវ បានខ្ញុំដឹងថា អ៎!អា១១នាក់យប់មិញ ព្រោះចាប់ក្បែរកងចល័ត កងរបស់ខ្ញុំ យកទៅវាយចោលបែបក្បែរហ្នឹង។ ខ្ញុំមិនបានឃើញគេវាយទេ ក៏ប៉ុន្តែខ្ញុំ ចំណុចសំខាន់របស់ខ្ញុំ ត្រង់ចំណុចថាវាអត់អាវៗតែទាំងអស់។ ហើយខ្មោចហ្នឹងច្រងេងច្រងាងសុទ្ធតែអត់អាវ មិនដឹងថាៗម៉េច ខ្ញុំថាមានតែអាហ្នឹងឯង។

**ស៖** ដើម្បីប្រតិចារឹកលោកប្រធាន ខ្ញុំយោងទៅឯកសារ E3/9076 ERN 00731169, ខ្មែរ 00728867 ដែលឆ្លើយថា មេបញ្ជាការ -- គាត់ជាមេបញ្ជាការកងវរសេនាតូច ហើយបានឆ្លើយថា៖ “មិនដែលឃើញទាហានខ្មែរក្រហម កងទ័ពខ្មែរក្រហមមកចាប់មនុស្សយកទៅសម្លាប់នៅការដ្ឋានការងារនោះទេ។” ខ្ញុំសូមបន្តទៅសួរសំណួរពីរបីចុងក្រោយរបស់ខ្ញុំ លោកសាក្សី លោកដែលធ្លាប់ឮសួរមន្ទីរពេទ្យនោះឈ្មោះ “អន្លង់ស”?

**ឆ៖** បាទ ការពិតមិនមែន “អន្លង់ស” ទេគឺ “អន្លង់សារ” សព្វថ្ងៃស្ថិតនៅក្នុងស្រុកព្រះនេត្រព្រះ នៅក្បែរជិតនឹងស្ទឹងរំដួល – ស្ទឹងរំដួល ឃុំភ្នំលៀប គឺអន្លង់សារ មិនមែនអន្លង់សទេ។ ពិតជាមានមន្ទីរពេទ្យនៅត្រង់ហ្នឹងមួយមែន ក៏ប៉ុន្តែខ្ញុំបាទគឺមិនដែលបានចូល ក៏ប៉ុន្តែដឹងថាមានមន្ទីរពេទ្យ។

[០៩:៣៩:២៤]

**ស៖** តើមន្ទីរពេទ្យមួយនេះ ជាមន្ទីរពេទ្យរបស់កងចល័ត ដែលក្នុងនោះលោកក៏ជាសមាជិកនៃកងចល័តនេះដែរ ឬក៏មន្ទីរពេទ្យនេះ មន្ទីរពេទ្យកងចល័ត ឬមិនមែនទេ?

**ឆ៖** បាទ ខ្ញុំថាមន្ទីរពេទ្យកងចល័ត ព្រោះចល័តដឹកចេញពីការដ្ឋានហ្នឹង បើច្រើន បើល្មមៗ តិចតួចអី គេអាចយកទៅព្យាបាលនៅហ្នឹងស្ពាន -- នៅនឹងវត្តត្រពាំងថ្ម ក៏ប៉ុន្តែដល់ច្រើនហួសហេតុអីទៅ គេក៏យកទៅដាក់នៅមន្ទីរពេទ្យអន្លង់សា៊ារវិញ។

**ស៖** តើខ្លួនលោកផ្ទាល់ ធ្លាប់ដែលបញ្ជូនអ្នកណាម្នាក់ដែលឈឺ ដែលថាមិនអាចព្យាបាលនៅការដ្ឋានបាន បញ្ជូនទៅមន្ទីរអន្លង់សារ ធ្លាប់ទេ?

**ឆ៖** បាទ ក្នុងកងរបស់ខ្ញុំពុំដែលមានឈឺធ្ងន់រហូតបញ្ជូនទៅមន្ទីរពេទ្យអន្លង់សារទេ។ កងរបស់ខ្ញុំមានតែឈឺល្មមៗ ឬក៏ឈឺ ជួនកាលឈឺខ្លាំងដែរ អ្នកដើរមិនរួច ពេទ្យគឺមានតួនាទីភារកិច្ចយកអ្នកជំងឺនោះទៅសម្រាកនៅវត្តត្រពាំងថ្ម តែប៉ុណ្ណឹងទេសម្រាប់កងខ្ញុំ។

**ស៖** ចុះលោកធ្លាប់ដែរឮថា មន្ទីរពេទ្យនេះមានកន្លែងរក្សាទុកនូវថ្នាំបុរាណ មិនមែនត្រឹមថ្នាំបុរាណទេ មានរហូតដល់ប៉ារ៉ាសេតាម៉ុល លេខ៣០០ មាន -- ចង់សួរម៉្យាងទៀតថា លោកមានដឹងថាមន្ទីរពេទ្យនេះ មិនមែនត្រឹមតែទុកថ្នាំបុរាណទេ មានទុករហូតដល់ថ្នាំសម័យទៀត លោកដឹងទេ?

**ឆ៖** ខ្ញុំបាទពុំបានឃើញ ហើយក៏ពុំបានដឹងដែរ ព្រោះខ្ញុំបាទពុំដែលបានទៅដល់ផង។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

[០៩:៤២:៣២]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិការជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**លោក អាកធួរ វ៉េកកែន៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរភាគីទាំងអស់។

**សួរដោយលោក អាកធួរ វ៉េកកែន៖**

**ស៖** ខ្ញុំមានសំណួរខ្លីទេ ដោយសារតែមេធាវីការពារក្តី នួន ជា បានសួរស្ទើរតែអស់ទៅហើយ។ ពាក់ព័ន្ធទៅនឹងឋានៈរបស់លោកជាអតីតទាហាន លន់ នល់ ខ្ញុំចង់ដឹងថាតើលោកអាចលាក់ប្រវត្តិរបស់លោកដែលជាអតីតទាហាន លន់ នល់ ហ្នឹងបានទេក្នុងរបបខ្មែរក្រហមហ្នឹង ពីព្រោះថាលោកធ្លាប់បានធ្វើជាទាហាន លន់ នល់ ហ្នឹងអស់រយៈពេល២ឆ្នាំដែរ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ ខ្ញុំបាទគេជម្លៀសចេញពីភូមិភ្នំលៀប ទៅនៅភូមិកំបោរ ខ្ញុំពុំអាចលាក់ប្រវត្តិរូបខ្ញុំបានទេ ព្រោះកងឈ្លបរបស់គេគឺតាមចាប់សម្លាប់។ ក៏ប៉ុន្តែមានឈ្លបមួយនោះគេស្គាល់ឪពុកខ្ញុំ ហើយគេមកប្រាប់ឪពុកខ្ញុំថា “ពូអ៊ំ អាសេង ត្រូវគេយកទៅទុកដាក់ហើយ។” ហើយពុកខ្ញុំសួរថា “ទុកដាក់យ៉ាងណា?” ថា “គេយកទៅវ៉ៃចោល។” អ៊ូ! ពូអ៊ំឯងទៅសុំមេភូមិទៅ ក្រែងលោសុំបាន។” មេភូមិនោះគេឈ្មោះ តាឆេង នៅបត់ត្រង់ ក្នុងឃុំភ្នំលៀបបច្ចុប្បន្ន ក៏ប៉ុន្តែគាត់ស្លាប់ហើយ។ ដល់ពុកខ្ញុំទៅសុំ គាត់ថាមិនបានទេអ៊ំ អីៗជួយបាន តែទាហានអាយ៉ង គឺមិនជួយបាន។ ពុកខ្ញុំប្រាប់ខ្ញុំ ថាកូន ពុកជួយមិនបានទេ កូនឯងគេចចេញទៅ។ ខ្ញុំក៏រត់ចេញ ដែលគេជម្លៀសពីភូមិកំបោរ មកចូលកងចល័ត តាវ៉ាល់ នៅឆ្នាំ១៩៧៥។

[០៩:៤៤:៥៩]

**ស៖** ពិតណាស់ ចំណុចនេះហើយគឺខ្ញុំផ្តោតទៅលើ។ ព្រោះលោកបាននិយាយអំពីបញ្ហាឪពុករបស់លោកជាមួយឈ្លបរួចមកហើយ។ ក៏ប៉ុន្តែនៅក្នុងភូមិកំណើតរបស់លោក ឬក៏នៅកន្លែងដែលលោកធ្វើជាអង្គរក្សឲ្យមេបញ្ជាការម្នាក់នៃរបបសាធារណរដ្ឋខ្មែរ ហើយនិងនៅទំនប់ត្រពាំងថ្ម គឺកន្លែង

ទាំងអស់ហ្នឹងនៅក្បែរគ្នាណាស់ នៅជិតគ្នាណាស់ គឺថាចម្ងាយគ្នាពីគ្នាតែប៉ុន្មានគីឡូតែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំចង់សួរលោកថា លោកចូលនៅក្នុងកងមួយ ហើយលោកបានក្លាយទៅជាមេកង លោកមានអំណាចដាច់ខាតទៅលើកូនក្រុមរបស់លោក ពីព្រោះលោកបានបញ្ជាក់កាលពីម្សិលមិញថា លោកមានសិទ្ធិអំណាចក្នុងការសម្លាប់មនុស្សទៀត។ ហើយកន្លែងដែលលោកកើតហ្នឹង គឺនៅជិតនឹងកន្លែងដែលលោកបំពេញការងារនៅក្នុងរបបសាធារណរដ្ឋខ្មែរទៀត។ អ៊ីចឹងមិនមានអ្នកណាម្នាក់ស្គាល់ប្រវត្តិរបស់លោកទេ ឬក៏យ៉ាងម៉េច? ពីព្រោះថាកន្លែងហ្នឹងគឺថាជិតគ្នាណាស់ ម៉េចបានជាគេមិនដឹងអ្វីសោះពីប្រវត្តិរបស់លោកនោះ លោកពន្យល់បានយ៉ាងម៉េចពីចំណុចនេះ?

**ឆ៖** ខ្ញុំបាទសូមជម្រាបថា ពីភូមិទ្រលោក ភូមិកំបោរ មករកភ្នំលៀប ខ្ញុំពុំបានចូលភូមិទេ គឺនៅកងចល័តជាមួយឈ្មោះ សៀក ជាប្រធានកង។ ហើយធ្វើបានតែបីបួនថ្ងៃ គេក៏ដកពីហ្នឹងមក មករៀបកងនៅព្រៃមាន់។ រៀបព្រៃមាន់រួច ទៅលើកទំនប់កំបោរ-ស្រេះ។ ក៏ប៉ុន្តែនៅក្នុងនោះ គឺខ្ញុំបានលាក់ប្រវត្តិរូបជិត។ នៅក្នុងនោះ គឺមិនសូវមានប្រជាជនមូលដ្ឋានណាដែលនៅជាមួយទេ ដូចជានៅភូមិភ្នំលៀបអីជាដើម គឺមានតែអ្នកដែលទៅពីចម្ងាយ ដូច្នេះគេមិនដឹងថាប្រវត្តិខ្ញុំធ្វើអីទេ។ តែបើសិនជាគេសួរគេអី ខ្ញុំក៏ឆ្លើយដំណាលថា ខ្ញុំគ្រាន់តែធ្វើស្វ័យត្រាណ ការពារភូមិប៉ុណ្ណោះ ខ្ញុំមិនដែលបានធ្វើទាហាន លន់ នល់ទេ។ បានអ៊ីចឹងទៅៗបានជាខ្ញុំបានរស់។ បើសិនជាគេដឹងថាខ្ញុំជាទាហាន លន់ នល់ ដែរ ក៏ខ្ញុំក៏មិនបានរស់សព្វថ្ងៃដែរ។

[០៩:៤៧:៥០]

**ស៖** អ្នកដែលនៅក្រោមបង្គាប់របស់លោកនៅក្នុងកងរបស់លោកនៅទំនប់ត្រពាំងថ្មហ្នឹង សុទ្ធតែជាប្រជាជនថ្មីទាំងអស់ មែនទេ?

**ឆ៖** បាទ ប្រធានកងគឺមូលដ្ឋាន។ នៅក្នុងនោះដូចជាខ្ញុំជាប្រធាន ហើយអាមួយទៀតឈ្មោះ អាស៊ូ មួយទៀតឈ្មោះ អាហួរ វានៅរងខ្ញុំ។ ខ្ញុំក៏មិនដឹងច្បាស់ថា អាស៊ូ និង អាហួរ នោះវានៅភូមិណាដែរ ព្រោះមួយថ្ងៃៗគឺនិយាយតែពីរឿងលាក់ប្រវត្តិរូបបណ្តោយ អត់មាននិយាយអីទេ។ ទី១ គោរពវិន័យចាត់តាំងរបស់អង្គការ។ ទី២ គឺលាក់ប្រវត្តិខ្លួនឯងឲ្យៗកំបាំង ឲ្យជិត។ ហើយអ្នកមួយចំនួននៅភ្នំលៀប អ្នកដែលធ្វើទាហាន គ្នារត់មិនរួចអីមិនរួច គឺអស់ហើយបាទ សល់ប៉ុន្មានពីរបីនាក់អីប៉ុណ្ណឹងទេ។

**ស៖** ខ្ញុំដឹងថាឪពុករបស់លោកស្លាប់ក្នុងរបបនោះ។ លោកបានបញ្ជាក់ថា ការស្លាប់របស់គាត់ដោយសារតែខ្វះទឹក អត់មានទឹកហូប។ អ៊ីចឹងគាត់ស្លាប់តាំងពីមុនរបបខ្មែរក្រហមទៅទៀត បើគិត

ទៅ។ ដូច្នេះខ្ញុំអាចនិយាយបានទេថា ឪពុករបស់លោកមិនមែនស្លាប់ដោយសារតែគាត់បានរាយការណ៍ប្រាប់ឈ្លបថា លោកជាទាហាន លន់ នល់ ទេ? ខ្ញុំគិតថា គាត់បានរាយការណ៍ពីស្ថានភាពរបស់លោកប្រាប់ឈ្លប ក៏ប៉ុន្តែខ្ញុំគិតថា មិនមែនដោយសារតែការរាយការណ៍ហ្នឹងទេ បានធ្វើឲ្យគាត់ស្លាប់នោះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំបាទសូមជម្រាបថា ឈ្មោះ ហ៊ានៗ ហ្នឹងវាស្លាប់ហើយ នៅភូមិភ្នំលៀប វាជាឈ្លប ប្រាប់ឪពុកខ្ញុំ បានខ្ញុំរត់គេច។ ហើយឪពុកខ្ញុំមិនមែនស្លាប់ពីសម័យ លន់ នល់ ទេ គឺស្លាប់សម័យ៣ឆ្នាំ ៨ខែ ២០ឆ្នាំនេះឯង គឺឆ្នាំ១៩៧៥-៧៦ហ្នឹងឯង ដែលខ្ញុំនៅកងចល័តបាទ។ ពេលនោះគេជម្លៀស គាត់ពីណោះវិញ មកនៅភូមិបត់ត្រង់-ឡោទេរនេះ ហើយឪពុកខ្ញុំស្លាប់នេះដោយសារតែការបង្អត់អាហារ។ ឪពុកខ្ញុំគាត់ចំណាស់ដែរ ហើយទៅធ្វើការមិនកើត គេឲ្យទៅនៅចាំចម្ការ ចាំមិនបាន ឲ្យទៅនៅចិញ្ចឹមមាន់ ទៅមិនរួច ព្រោះគាត់ចំណាស់ហើយ។ ដូច្នេះអ្នកដែលធ្វើការបានគ្រាន់ បើបានអាហារគ្រាន់ដូចជាឪពុកខ្ញុំថ្ងៃណាម៉ែខ្ញុំប្រាប់ថា បីស្លាបព្រាក៏មាន។ ដល់អ៊ីចឹងទៅគាត់ហើមៗទៅ គាត់ក៏ស្លាប់ទៅ។ មិនមែនស្លាប់កាលតាំងសម័យមុនទេ ដោយសារអត់ទឹកទេ ដោយសារស្លាប់ដោយហើម ដោយអត់បាយ។

[០៩:៥១:១៨]

**ស៖** នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសលោក លោកបានឆ្លើយពាក់ព័ន្ធទៅនឹងសិទ្ធិអាចសម្រេចឲ្យអ្នកណារស់ ឬក៏ស្លាប់ចំពោះកូនចៅរបស់លោក។ អ៊ីចឹងខ្ញុំចង់អានអ្វីដែលលោកបានឆ្លើយឡើងវិញ ពីព្រោះថាខ្លឹមសារនៃចម្លើយនេះ វាធ្វើឲ្យខ្ញុំចង់សួរអំពីអ្វីដែលលោកបានធ្វើ ឬក៏មិនធ្វើនៅសម័យនោះ។ ERN ជាភាសាបារាំងគឺ 01123596, អង់គ្លេស 00728623, ភាសាខ្មែរ 00730784។ ខ្ញុំនឹងអាននូវចម្លើយរបស់ ដារ៉ា ជាមួយនឹងសមាជិកមួយចំនួនដែលបានបាត់ខ្លួន។ តាយ៉ាល់ ប្រធានវរសេនាតូចហ្នឹង គាត់មានសួរអំពីការស្លាប់របស់សមាជិកកងទេ? ខ្ញុំសូមសួរម្តងទៀត ពីព្រោះគេប្រាប់ខ្ញុំថា ខ្ញុំសួរលឿនពេក។ “ដោយសារតែមានសមាជិកមួយចំនួនបាត់ខ្លួន តាវ៉ាល់ ដែលជាប្រធានវរសេនាតូចហ្នឹង មានបានសួរអំពីមូលហេតុនៃការបាត់ខ្លួនរបស់សមាជិកកងទាំងអស់ហ្នឹងទេ?” ពេលនោះលោកឆ្លើយថា៖ “អត់ទេ គាត់អត់មានសួរសំណួរអីទេ។ ក៏ប៉ុន្តែឧទាហរណ៍ថានៅពេលដែលមេកងស្អប់អ្នកណាម្នាក់មួយនោះ គេនឹងសម្លាប់អ្នកនុំងចោលហើយ។ បន្ទាប់ពីសម្លាប់ហើយយើងរាយការណ៍ទៅមេវរសេនាតូចនៅពេលព្រឹក ថាមិត្តបង ខ្ញុំបានសម្លាប់អាមួយហ្នឹងហើយ វាប្រឆាំងនឹងបញ្ជា ហើយវាអត់ធ្វើការ។ វាបាននិយាយថា ការរែកដីហ្នឹងមិនមែនជារឿងរបស់វាទេ ហើយអត់ការហូបចុកអី

គ្រប់គ្រាន់ទៀត។ តែតាមពិតទៅ បុគ្គលហ្នឹងគឺមិនបាននិយាយអ្វីទេ។ ហើយនៅពេលដែលប្រាប់អ៊ីចឹង ហើយ គឺមេកងអីហ្នឹងមានសិទ្ធិសម្លាប់បានតាមចិត្ត។" សូមបញ្ចប់ការដកស្រង់។

[០៩:៥៣:៤៧]

នៅពេលដែលខ្ញុំអានចម្លើយនេះ គឺលោកនិយាយអំពី -- លោកនិយាយរបៀបអ្នកទី១ បុគ្គលទី១ គឺលោកឆ្លើយថា "មេៗហ្នឹងអាចសម្លាប់អ្នកណាម្នាក់ក៏បាន ដោយគ្រាន់តែចោទថាអត់គោរវិន័យ"។ ហើយបន្ទាប់មកទៀត លោកនិយាយពាក្យថា "យើង"។ ខ្ញុំដឹងថា លោកឆ្លើយរួចមកហើយ ប៉ុន្តែខ្ញុំចង់សួរលោកម្តងទៀត តើលោកធ្លាប់ប្រើសិទ្ធិរបស់លោកក្នុងការសម្លាប់មនុស្សទេ នៅសម័យនោះនោះ? ពីព្រោះថាទៅតាមចម្លើយរបស់លោកហ្នឹង គឺថាមើលទៅលោកមានការងាយស្រួលណាស់ ចង់សម្លាប់អ្នកណាម្នាក់ក៏បានដែរ ដោយគ្រាន់តែចោទអ្នកណាម្នាក់ថា រិះគន់បក្ស ឬក៏រិះគន់របប ឬក៏មិនគោរពអង្គការវិន័យជាដើមនោះ។

**លោក ឌុច ផារី៖**

សូមគោរពលោកប្រធាន ដោយសារសំណួររបស់មេធាវីការពារក្តីអន្តរជាតិរបស់ ខៀវ សំផន សួរចុងក្រោយនេះ បានសួរបញ្ជាក់ថា តើសាក្សីធ្លាប់បានប្រើសិទ្ធិអំណាចរបស់ខ្លួន នៅក្នុងការបញ្ជាសម្លាប់អ្នកណាដែរមួយក៏អត់? វាជាប្រភេទដែលជាចម្លើយដែលធ្វើឲ្យសាក្សីឆ្លើយដាក់បន្ទុកលើខ្លួនឯង។ ដូច្នេះខ្ញុំសូមការអនុញ្ញាតពិភាក្សាជាមួយសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ!

*(សម្រាករយៈពេលខ្លី)*

[០៩:៥៦:០៥]

**លោក ឈុំ សេង៖**

**ឆ៖** បាទ សំណួរនេះពិសេសណាស់។ សំណួរត្រឹមត្រូវ ព្រោះសម័យនោះគឺ តាវ៉ាល់ ជាអ្នកបញ្ជាផ្ទាល់។ អ្នកណាដែលថានៈត្រឹមកងធំ អ្នកណាដែលមិនប៊ាន ដែលមិនសម្លាប់ ឬក៏អីហ្នឹង គឺ តាវ៉ាល់ គាត់ត្រូវតែសម្លាប់អ្នកនោះ។ តែចំពោះកងរបស់ខ្ញុំបាទវិញ ឬក៏ក្រុមខ្ញុំបាទវិញ ពុំបានដែលមានបញ្ហានោះកើតឡើងទេ។ បាទ ហើយចំពោះកងផ្សេងៗ គឺខ្ញុំបាទដឹងពុំដល់ តែចំពោះបុគ្គលខ្ញុំ សម្រាប់បងប្អូនក្រោមការគ្រប់គ្រងរបស់ខ្ញុំ គឺមិនដែលមានបញ្ហាណាមួយ ថាឲ្យប្រធានកងពិបាកចិត្តទៅអីៗ គឺ

មិនមានទេ។ ដោយសារអី ខ្ញុំចេះតែបញ្ជាក់ប្រាប់វាថា "បច្ចុប្បន្ននេះគេមិនត្រូវការអ្នកចេះ មិនត្រូវការអ្នកអីទេ។ តែល្ងង់ៗទៅ គេឱ្យរែកដីក៏រែកទៅ កុំទៅពោលរអ៊ូរទាំអី ធ្វើម៉េច អ្នែងទៅតវ៉ាសុំអី សុំនេះសុំនោះ ប្រយ័ត្ន បាទ"។ ដែលខ្ញុំនិយាយនេះគឺបញ្ជា តាវ៉ាល់ ទេ ជាអ្នកថាត្រឹមប្រធានកងមានសិទ្ធិសម្លាប់បាន។ តែចំពោះក្នុងកងខ្ញុំ គឺមិនដែលមិនមានប្រធានកងណាទៅសម្លាប់នោះទេ។ តែចំពោះកងដទៃខ្ញុំបាទពុំបានដឹងទេ បាទ។

**សួរដោយលោក អាកឡូរ វែកគែន៖**

**ស៖** ក៏ប៉ុន្តែចំពោះលោក លោកសាក្សីទោះបីជាលោកមិនបានប្រើសិទ្ធិអំណាចនេះក៏ដោយ គឺលោកមានសិទ្ធិ ទោះបីជាលោកបញ្ជាក់ថាលោកមិនបានប្រើសិទ្ធិនេះក៏ដោយ ក៏ប៉ុន្តែលោកមានសិទ្ធិនេះ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ឱ្យលោក ឱ្យបានច្បាស់ម្តងទៀតថា តើលោកមានសិទ្ធិសម្រេចសម្លាប់កូនចៅរបស់លោកណាមួយបានដែរឬទេ?

[០៩:៥៨:២៤]

**ឆ៖** បាទ ត្រង់ចំណុចហ្នឹង ខ្ញុំនិយាយដដែលៗទេ។ តាវ៉ាល់ បញ្ជាមកគឺឱ្យប្រធានកងតាមដានរហូត ដូច្នេះកងណា គឺកងនោះមានសិទ្ធិសម្លាប់។ បាទនេះគឺជាបញ្ជាមកពី តាវ៉ាល់។ បាទ ប៉ុណ្ណឹងទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំយល់ច្បាស់អំពីចម្លើយរបស់លោកនេះ។ នៅក្នុងចម្លើយរបស់ដែលបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលខ្ញុំបានអានជូនលោកអម្បាញ់មិញនេះ លោកបានរៀបរាប់អំពីស្ថានភាពមួយ ដែល តាវ៉ាល់ មិនបានសួរនាំអ្វីអំពីការបាត់ខ្លួនរបស់សមាជិកនៅក្នុងកងទេ។ ដោយសារតែគេបានប្រាប់ តាវ៉ាល់ ថាអ្នកដែលស្លាប់ អ្នកដែលត្រូវគេសម្លាប់នុំង បានរិះគន់ មិនស្តាប់បញ្ជា ហើយមិនធ្វើការ គឺគ្រាន់តែមូលហេតុប៉ុណ្ណឹង គឺគ្រប់គ្រាន់ហើយ អាចសម្លាប់បានហើយ។ អ៊ីចឹងខ្ញុំចង់សួរលោកបញ្ជាក់ឱ្យបានច្បាស់ថា ប្រសិនបើ គឺថានៅពេលដែលយើងពន្យល់ប្រាប់ថ្នាក់លើថាអ្នកណាម្នាក់ដែលមិនគោរពបញ្ជា ប្រឆាំងនឹងបញ្ជា ហើយមិនធ្វើការអ៊ីចឹង គឺអាចជាហេតុផលគ្រប់គ្រាន់ដើម្បីសម្លាប់ចោលហើយ ហើយនៅពេលដែលសម្លាប់ចោលដោយហេតុផលបែបនេះ គឺតាវ៉ាល់ ឬក៏ថ្នាក់ដឹកនាំអីខាងលើហ្នឹង គឺមិនបាច់សួរនាំអីទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ បញ្ជារបស់ តាវ៉ាល់ បញ្ជាមែន ក៏ប៉ុន្តែដូចគាត់មិនតាមដាន ស្លាប់ប៉ុន្មាន រស់ប៉ុន្មាន គឺមិនដែលមកសួរ ឬមកតាមដាន ថាកងនេះតិច កងនេះច្រើន គឺមិនដែលឃើញសួរទេ។ គ្រាន់តែបញ្ជាថាឱ្យកម្ទេចអ្នកណាដែលក្បត់បដិវត្តន៍ អាណាដែលប្រឆាំងអង្គការ សេ.អ៊ី.អា យួន អីជាដើម។ ក៏ប៉ុន្តែខ្ញុំក៏

មិនដែលឃើញថា ប្រធានកងណាមួយ បាទជាពិសេសក្នុងកងខ្ញុំ បើកងអ្នកដទៃ ខ្ញុំមិនបានឃើញទេ ហើយខ្ញុំមិនអាចយកមកនិយាយបាន។ ខ្ញុំនិយាយនេះ គឺសម្រាប់តែចំពោះរូបខ្ញុំ និងកងរបស់ខ្ញុំ គឺមិនដែលមានបញ្ហានោះកើតឡើងមែន។ ថ្វីត្បិតតែ តាវ៉ាល់ ប្រគល់សិទ្ធិឲ្យមែន ក៏ប៉ុន្តែកងខ្ញុំពុំដែលមាន ហើយក្នុងកងវរៈរបស់ខ្ញុំ គឺពុំដែលមានការណ៍នោះកើតឡើងទេ បាទ។

[១០:០១:១៧]

**ស៖** ប្រសិនបើខ្ញុំច្រឡំ លោកអាចបញ្ជាក់បាន។ លោកបានពន្យល់ថា អ្នកដែលមានទំនួលខុសត្រូវនៅទំនប់នោះ គឺសុទ្ធតែជាអ្នកមិនបានរៀនសូត្រ។ ខ្ញុំដឹងថា លោកមេធាវី កូប៉េ បានសួរលោកយ៉ាងយូរអំពីអ្នកដែលមានទំនួលខុសត្រូវប្រហាក់ប្រហែលនឹងលោក។ ហើយពេលហ្នឹង គឺខ្ញុំស្តាប់ទៅដូចមិនសូវច្បាស់ទេ ក៏ប៉ុន្តែខ្ញុំចង់ឲ្យលោករៀបរាប់ឲ្យបានច្បាស់ នៅពេលដែលលោកនិយាយអំពីការទទួលខុសត្រូវរបស់អ្នកដែលមិនបានរៀនសូត្រហ្នឹង គឺលោកសំដៅទៅដល់មេកងដែលលោកបានជួបនៅក្នុងពេលប្រជុំ ឬក៏ក្នុងឱកាសផ្សេងៗទៀត លោករួមបញ្ចូលទាំងមេកង ដែលមានឋានៈប្រហាក់ប្រហែលនឹងលោកទេ នៅពេលដែលលោកនិយាយថាអ្នកទទួលខុសត្រូវនៅទំនប់ហ្នឹង គឺសុទ្ធតែជាអ្នកមិនបានរៀនសូត្រនោះ?

**ឆ៖** បាទ ចំពោះដែលខ្ញុំនិយាយនេះ គឺនិយាយតែបុគ្គលខ្ញុំម្នាក់គត់។ ខ្ញុំចេះដែរ ក៏ប៉ុន្តែចេះស្ទើរបាទ។ ចេះអាចអានបានខ្លះ ព្រោះខ្ញុំរៀនបានដល់ថ្នាក់ទី៩ចាស់ដែរ ដូច្នេះ ខ្ញុំអាចអានបានខ្លះ បើសរសេរក៏អាចបានខ្លះ។ ក៏ប៉ុន្តែក្នុងដំណាក់កាលនោះ គេមិនត្រូវការអ្នកចេះទេ គេត្រូវការតែអ្នកល្ងង់ ព្រោះវាស្រួលប្រើ ស្រួលសម្លាប់។ ឲ្យសម្លាប់ឪឯង ម៉ែឯងក៏សម្លាប់ដែរ គេមិនសម្លាប់ពុកម៉ែឯណា គេសម្លាប់ខ្មាំង។ អ៊ីចឹងបានជាដំណាក់កាលនោះ គេរកតែអ្នកដែលល្ងង់ឲ្យធ្វើការ។ ដូច្នេះសម្រាប់ខ្ញុំ ល្ងង់ដែរ ក៏ប៉ុន្តែមិនអាចយកការនេះឯងមកបញ្ជាខ្ញុំ មកប្រាប់ខ្ញុំ ឲ្យធ្វើអីចេះៗ អត់បាន ខ្ញុំមិនធ្វើតាម។ មិនធ្វើតាមនេះ គឺដោយសារតែថា ចុះបើយើងក្តិចសាច់ខ្លួនយើង នៅតែឈឺ ចុះទម្រាំក្តិចសាច់អ្នកដទៃទៀត គេឈឺប៉ុនណា។ ចុះបើយើងសម្លាប់គេ ថ្ងៃក្រោយគេនឹងសម្លាប់យើងវិញ។ បាទ ខ្ញុំយល់ប៉ុណ្ណេះ។ ហើយដែលខ្ញុំនិយាយថា អ្នកដែលល្ងិតល្ងង់ គឺខ្ញុំនិយាយតែរូបខ្ញុំទេ ហើយចំពោះបុគ្គលដទៃ ខ្ញុំក៏មិនដឹងថា គេរៀនបានកម្រិតណា ចំណេះគេប៉ុនណា ខ្ញុំអត់ដឹងទេបាទ។

[១០:០៤:០៥]

**ស៖** ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកចំណុចមួយដែលជាចំណុចចុងក្រោយ។ គឺនៅពេលដែលលោក

ធ្វើការនៅជើងស្ពានទី១ ដើម្បីបង្ហាប់ដី គឺបង្ហាប់កាយដីកប់ទៅលើសព។ លោកបានឆ្លើយថា ជាទូទៅ នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ហ្នឹង គឺថាគឺលោកពង្រាបដី លោកឈូសឆាយដី។ មានន័យថាយ៉ាងម៉េច ខ្ញុំអត់សូវយល់ មានន័យថា មានអ្នកជីកដី ហើយបន្ទាប់មកទៀតលោកមានឧបករណ៍សម្រាប់ពង្រាបដី ឬកិនបង្ហាប់ដី ឬក៏យ៉ាងម៉េច ឬក៏លោកមានរ៉ូឡូសម្រាប់បើកកិនពង្រាប ឬក៏បង្ហាប់ដីនេះ?

**ផ៖** បាទ ដំណាក់កាលនោះ គឺតាមកង មុខសញ្ញាកងខ្ញុំគឺពលករ គឺប្រជាជនរែកដីពីខាងក្រោមទៅចាក់ឯលើ ក៏ប៉ុន្តែការចាក់នោះមិនបានស្មើទេ ជួនកាលត្រង់ណោះខ្ពស់ខាងនេះទាប។ ដូច្នេះខ្ញុំមានតែចបមួយគត់ៗដែលឡើងទៅពង្រាបដីឲ្យវាស្មើ ពង្រាបទីខ្ពស់មកទាប ហើយយកចបនោះដំបណ្ដើរៗទៅឲ្យវាស្មើគ្នា។ បាទតែប៉ុណ្ណឹងទេ គឺគ្មានរ៉ូឡូ គ្មានអីឯណាឯណីមកទេ។ តាមកងគឺប្រគល់តួនាទី គឺប្រធានកងត្រូវតែពង្រាបឲ្យស្មើអីចឹងឯង បាទគ្រប់តែកង។

**ស៖** អ្វីដែលខ្ញុំយល់កាលពីព្រឹកមិញនេះ គឺលោកបានឆ្លើយថា នៅពេលដែលគេធ្វើតេស្តឲ្យមនុស្សដើរលើរងើកភ្លើងនុ៎ង អ្នកដែលខ្វាក់មាន់នោះ ខ្ញុំដូចជាមិនសូវយល់ថា ម៉េចបានជាលោកមានអីពាក់ព័ន្ធទៅនឹងកន្លែងដែលថាគេធ្វើតេស្តហើយ ឲ្យដើរលើភ្លើងហើយ បន្ទាប់មកលោកៗទៅឆាយដី ទៅពង្រាបដីនេះ ហេតុអីលោកទៅកន្លែងហ្នឹង? តើគេប្រាប់លោកយ៉ាងម៉េច? លោករៀបរាប់ឲ្យបានបញ្ជាក់បន្តិចមើលថា គេប្រាប់លោកថា ឲ្យលោកទៅកប់សព ឬក៏យ៉ាងម៉េច? ឬក៏លោកទៅកន្លែងហ្នឹងដើម្បីធ្វើការជាធម្មតា តែចៃដន្យអីលោកបែរជាត្រូវកប់សពទៅវិញអីអ៊ីចឹង? តើលោកអាចបញ្ជាក់ម្ដងទៀតឲ្យបានច្បាស់បានទេ?

[១០:០៧:១២]

**ផ៖** បាទ ពេលនោះធម្មតាជីកទំនប់ គេមិនជីកខាងក្រៅទេ គេជីកខាងក្នុងលើកមកដាក់ ក៏ប៉ុន្តែពេលនោះគឺលើកយប់ ដល់ពេលលើកយប់ទៅ ចំខ្សែត្រៀមរបស់កងរបស់ខ្ញុំដែលនៅជិតរោងដែលពួកចលតសម្រាក។ ឃើញដុតភ្លើងភ្លឺរន្ទាល ហើយខ្ញុំនៅលើខ្នងទំនប់។ ឃើញដុតភ្លើងភ្លឺរន្ទាល ខ្ញុំដើរទៅមើល ឃើញគេជុំ ដើរៗទៅ ខ្ញុំក៏ដើរទៅមើល លីចបមួយដើរទៅមើល។ ទៅមើលទៅ ចុម! ឃើញមនុស្ស១២នាក់ ខ្ញុំរាប់ផ្ទាល់ភ្នែក ១២នាក់។ ហើយមនុស្សទាំងអស់នោះគឺអត់អាវ ជួនកាលមានខោខ្លី អាខោវែងដូចជាស្ទើរមិនមានផង ដល់រាងងឹតចុះ។ ដល់ទៅទៀតទៅ ទៅដល់ឃើញគេមកបណ្ដោយ។ ឃើញឈ្មោះ ផន ដែលជាអ្នកដឹកដៃ។ ដឹកមក ស្រាប់តែអា១១នាក់ វាអត់ជាន់ភ្លើង។ អត់ជាន់ភ្លើង ដឹក

ហួស អាមួយនោះវាមិនដឹងម៉េច វាដើរមកជាន់ភ្លើង "អ្ហ៎! បងក្តៅៗ" ប៉ុណ្ណឹង។ ស្រាប់តែប៉ាប់រួច អាមួយនោះ ហើយអាប៉ុន្មាននាក់នោះអត់អាវនោះ យោធាគេមកព្រឹបៗ គេចង។ ខ្ញុំអឺយ៉ា! មិនស្រួលទេ ចល័តអីហ្នឹងឈប់រែកដី ឈប់អីទាំងអស់ហើយ នោះចាប់ដែលនេះគេពីនោះមក ដល់ពេលសម្រាក។ ព្រឹកឡើង យើងម៉ោងប្រាំ ម៉ោងអីជួនកាលវាអត់ទៀងដែរ ម៉ោងបួនម៉ោងប្រាំអី ក៏ក្រោកទៅរែកទៀត។ ដល់ពេលទៅរែក ទៅរែកដីទៅចាក់ទៀតនេះ ខ្ញុំក៏ឡើងដូចខ្ញុំបានជម្រាបហើយថា ឡើងទៅឈ្មូសដីឲ្យស្មើ។ ដល់យកទៅវ៉ៃ វ៉ៃចំអាកងចល័ត ចំអាខ្សែត្រៀមដែលកងខ្ញុំលើក។ បានខ្ញុំឃើញ ឃើញថា អ្ហ៎! ខ្មោចនេះបែបពួកអាយប់មិញ អា១១នាក់យប់មិញ សុទ្ធតែអត់អាវ។ ពេលនោះគឺអ៊ីចេះ តែឲ្យខ្ញុំឃើញផ្ទាល់ថា គេវ៉ៃ គេបាញ់ ខ្ញុំមិនបានឃើញផ្ទាល់ទេ ខ្ញុំឃើញតែខ្មោច ព្រោះខ្មោចដែលខ្ញុំឃើញវាអត់អាវ។ ដល់យកទៅកប់ យកទៅដាក់លើខ្នងទំនប់ច្រងេងច្រងាង វាអត់អាវដូចតែគ្នា។ បាននេះគឺការសន្និដ្ឋានរបស់ខ្ញុំទេ ថាប្រាកដជាអា១១នាក់ហ្នឹងឯង។ បាទសូមជម្រាប។

[១០:០៩:៤១]

**ស៖** ប្រសិនបើគេបាញ់សម្លាប់អ្នកទាំងនុ៎ង គឺលោកគួរតែស្តាប់ឮហើយ នៅកន្លែងដែលលោកនៅហ្នឹង។ អ៊ីចឹងលោកអត់មានស្តាប់ឮសំឡេងកាំភ្លើងអី គេបាញ់អ្នកទាំង១១នាក់ហ្នឹងទេឬ?

**ឆ៖** ដំណាក់កាលនោះ គេមិនសូវប្រើគ្រាប់កាំភ្លើងទេ។ គ្រាប់កាំភ្លើងគេប្រើនៅព្រំដែនសម្រាប់ប្រជាជន ឬក៏អាណាដែលក្បត់បដិវត្តន៍រត់ទៅប្រទេសថៃ អាហ្នឹងគេប្រើគ្រាប់កាំភ្លើង។ ក៏ប៉ុន្តែប្រើសម្រាប់កងចល័ត ឬក៏នៅសហករណ៍អីហ្នឹង តាមដែលខ្ញុំពិនិត្យមើលទៅ គេចូលចិត្តប្រើត្បូងចប ចូលចិត្តប្រើព្រនង់ ដំបង ហើយនិងត្បូងចបទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅកន្លែងរង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង១០:៣០ នាទី)*

[១០:៣០:២៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោកសាក្សី សូមលោកព្យាយាមរំឭកឲ្យបានច្បាស់អំពីការធ្វើតេស្តឲ្យដើរលើភ្លើង ហើយនិងការកប់សាកសពទាំង១១ ធ្វើដូចជាលោកមានវត្តមាននៅទីនោះតែម្តង។ ខ្ញុំចង់ឲ្យលោកគិតមើលឡើងវិញ ថាតើហេតុការណ៍ហ្នឹងកើតឡើងតាំងពីដំបូងនៅពេលដែលលោកទៅដល់ការដ្ឋានទំនប់ហ្នឹងតែម្តង ឬក៏នៅចុងពេលចុងក្រោយពេលដែលសាងសង់ចប់ហើយទេ? លោកគិតឡើងវិញទៅមើលថាហេតុការណ៍ហ្នឹងកើតឡើងនៅពេលណាដែរ នៅពេលដែលលោកធ្វើការនៅទីនោះ?

**លោក ឈុំ សេង៖**

**ឆ៖** បាទ សំណួរហ្នឹងបញ្ជាក់ហើយបញ្ជាក់ទៀត បួនដងហើយ ក៏ប៉ុន្តែខ្ញុំអាចឆ្លើយបាន។ ថាពេលនោះគឺកងចល័តរែកដីយប់ ហើយខ្ញុំនៅលើខ្នងទំនប់ បងប្អូនរែកខាងក្នុង ក៏ប៉ុន្តែដល់ដុតភ្លើងគឺដុតនៅចំខ្សែត្រៀមដែលខ្ញុំលើក ដុតនៅខាងក្រៅ។ ខ្ញុំបាទនៅលើខ្នងទំនប់ឃើញភ្លើងភ្លឺៗ ខ្ញុំក៏ដើរទៅមើលចុម! ដុតអីភ្លឺៗហ្នឹង ដើរទៅមើលស្រាប់តែឃើញគេបណ្តោយ។

**ស៖** ខ្ញុំសូមកាត់ចម្លើយលោកៗសាក្សី សូមអភ័យទោស។ លោកប្រហែលជាមិនយល់សំណួរខ្ញុំ សូមលោកស្តាប់ឲ្យច្បាស់ម្តងទៀត។ លោកបាននិយាយអំពីហេតុការណ៍ដែលលោកបានឃើញថាគេធ្វើ

តេស្តឱ្យអ្នកខ្វាក់មាន់១២នាក់ដើរលើរងើកភ្លើងនៅពេលយប់ ហើយបន្ទាប់មកស្អែកព្រឹក លោកបានកាយកប់សាកសព។ ខ្ញុំចង់ដឹងថា ហេតុការណ៍ដ៏គួរឱ្យរន្ធត់នេះបានកើតឡើងនៅពេលដែលលោកទៅចូលធ្វើការនៅការដ្ឋានហ្នឹងដំបូង មានន័យថាលោកទៅដល់ការដ្ឋានហ្នឹងភ្លាម មានរឿងហ្នឹងកើតឡើងភ្លាម ឬក៏នៅចុងក្រោយពេលដែលលោកធ្វើការចប់ហើយទេ? លោកអាចកំណត់បានឱ្យច្បាស់ទេ ថាពេលដែលកើតឡើងហ្នឹង គឺលោកទៅដល់ភ្លាម ឬក៏ពេលដែលលោកជិតចេញពីការដ្ឋានហ្នឹងហើយ? ខ្ញុំមិនសំដៅទៅលើពេលព្រឹកពេលថ្ងៃអីទេ ខ្ញុំចង់សំដៅលើរយៈកាលដែលលោកមានវត្តមាននៅទីនោះ។ ថាទៅដល់ហ្នឹង ពេលកើតឡើងហ្នឹងនៅពេលលោកទៅដល់ភ្លាម ឬក៏ពេលដែលលោកជិតចាកចេញពីទំនប់នោះហើយ?

[១០:៣៩:១០]

**ឆ៖** បាទ ឆ្នាំនោះនៅក្នុងអំឡុងឆ្នាំ៧៨ ដែលកងចល័តរែកដីពីទំនប់ -- ពីស្ពានទី១ទៅកាន់ភូមិពង្រ។ បាទ ក្នុងអំឡុងឆ្នាំ១៩៧៨ ពេលនោះកងចល័តរែកដីពីស្ពានទី១ទៅភូមិពង្រ បាទ។

**ស៖** លោកសាក្សីអម្បាញ់មិញនេះ នៅពេលដែលលោករៀបរាប់ពីហេតុការណ៍នៅពេលយប់ក្រោយពីគេធ្វើតេស្តឱ្យដើរលើភ្លើងហើយ លោកបានឆ្លើយថាគេសម្លាប់អ្នកទាំងនោះចោល។ តើនៅពេលយប់នោះ លោកធ្វើយ៉ាងម៉េចបានជាដឹងថា គេសម្លាប់អ្នកទាំង១១នាក់ហ្នឹង? លោកស្តាប់ឮសំឡេងស្រែក លោកបានបញ្ជាក់ហើយថា អត់មានឮសំឡេងកាំភ្លើងអីទេ អ៊ីចឹងក្រោយពីអ្នកទាំងអស់ហ្នឹងដើរលើភ្លើងហ្នឹងហើយ គេនាំយកទៅសម្លាប់ចោលភ្លាម ឬក៏យ៉ាងម៉េច? លោកបញ្ជាក់ឱ្យបានច្បាស់បន្តិចទៅមើល? ហើយគេនាំយកទៅហ្នឹង គេយកទៅសម្លាប់នៅកន្លែងណា?

**ឆ៖** ពេលដែលឃើញយោធាចង បាទដឹកចេញ ខ្ញុំពុំបានឃើញថាដឹកៗចេញ ដឹកបែរមុខទៅខាងជើង ហើយមិនដឹងថា ដល់គោលដៅណាទេ។ បាទ មនុស្សទាំងអស់សុទ្ធតែអត់អាវ ក៏ប៉ុន្តែព្រឹកឡើងទេ ដែលខ្ញុំទៅកាយនោះ ក៏ឃើញអាវអត់អាវនៅចំខ្សែត្រៀមខ្ញុំបាទ។ ខ្ញុំមិនបានឃើញគេវ៉ៃ ឃើញគេបាញ់ទេ ប៉ុន្តែឃើញតែខ្មោច។ ខ្មោចនោះ សុទ្ធតែអត់អាវដូចដែលគេដឹកទៅពីយប់ហ្នឹងឯង បាទ។

[១០:៣៦:២៥]

**ស៖** អ៊ីចឹងនៅពេលដែលលោកទៅដល់កន្លែងនុ៎ង គឺស្ពានទី១ហ្នឹង សាកសពមិនទាន់បានគេកប់នៅឡើយទេ អ៊ីចឹងមែនទេ គឺគេដាក់ចោលនៅលើដី អត់មានកប់អត់មានអីទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវណាស់ ដាក់នៅចំពីលើខ្នងទំនប់ដែលយើងរែកចាក់បន្តៗ។

ឧទាហរណ៍ថា យើងវែកដល់ចំណុចនេះ ត្រូវព្រឹកឡើងទៅវែកពីនេះចាក់មកនេះទៀត ដូច្នេះដាក់នឹងអាកន្លែងដែលយើងត្រូវព្រឹកឡើងយើងវែកចាក់ហ្នឹងឯង។

**ស៖** តែម្ដងហ្នឹងទេ ដែលលោកបានឃើញសាកសពហ្នឹង មែនទេ?

**ឆ៖** បាទ ខ្ញុំបាទ ឃើញតែម្ដងគត់ ប៉ុណ្ណឹងទេ ក្រៅពីហ្នឹងខ្ញុំបាទ ពុំបានឃើញទេ។

**ស៖** ចុះយ៉ាងម៉េចបានជាលោកចាំថា ហេតុការណ៍ហ្នឹង កើតឡើងនៅក្នុងឆ្នាំ១៩៧៨ ម៉េចបានជាលោកចាំច្បាស់ថា ឆ្នាំ៧៨បែបនេះ?

**ឆ៖** បាទ ព្រោះក្នុងអំឡុងឆ្នាំ១៩៧៨ហ្នឹងឯង ខ្ញុំចាំពុំបានច្បាស់ មិនដឹងជាដើមឆ្នាំ ឬចុងឆ្នាំ ឬពាក់កណ្ដាលឆ្នាំទេ។ ផែនការត្រូវលើកពីស្ពានទី១ ទៅភូមិពង្រ លើកពីភូមិពង្រឆ្ពាយទៅខាងមុខទៀតនោះ ទៅដល់ខាងគេហៅត្រពាំងស្នួលទៀតនោះ។ ដូច្នេះគម្រោងដែលគេប្រុងលើកបណ្ដើរៗ ក៏ប៉ុន្តែនៅពីត្រឹមស្ពានទី១ទៅលិច ក៏មិនទាន់រួចស្រួលបួលដែរ នៅមិនទាន់រួចទេ ក៏ប៉ុន្តែគ្រាន់តែដកកម្លាំងមួយចំនួនវៃសម្រុកបន្តបន្ទាប់។

[១០:៣៩:០០]

**ស៖** សូមអរគុណ។ ខ្ញុំមានប្រធានបទចុងក្រោយ ពាក់ព័ន្ធទៅនឹងការងាររបស់លោកជាកងការពារមេបញ្ជាការទាហាន លន់ នល់។ លោកបានធ្វើការជាទាហាន លន់ នល់ ២ឆ្នាំមុនរបបខ្មែរក្រហម។ លោកអាចរៀបរាប់អំពីភារកិច្ចរបស់លោក នៅពេលដែលលោកធ្វើជាទាហាននៅក្នុងកងទ័ពសាធារណរដ្ឋខ្មែរបានរយៈពេល២ឆ្នាំហ្នឹងបានទេ?

**ឆ៖** បាទ នៅឆ្នាំ១៩៧២ ពេលនោះខ្ញុំរៀនអត់ចូល ម៉ែឪឲ្យទៅរៀនក៏មិនចូលដែរ ខ្ញុំក៏រត់ពីភូមិភ្នំលៀប មកស្ម័គ្រធ្វើជាទាហាន លន់ នល់ នៅមជ្ឈមណ្ឌលហ្វឹកហ្វឺនទី៤ សព្វថ្ងៃដែលនៅក្នុងខេត្តបន្ទាយមានជ័យរាល់ថ្ងៃនេះ ត្រង់ផ្សារចំការគ។ ក្រោមការគ្រប់គ្រងរបស់ធំជាងគេបំផុតគឺ តាន់ ឈាងម៉េង។ បន្ទាប់មកទៀតគឺ អ៊ុក សំអឿន ៧ស័ក្តិ៤៧។ ពេលនោះ ខ្ញុំគេឲ្យរៀនយុទ្ធសាស្ត្រដើម្បីទៅ គេប្រាប់ថាទៅនែនេះ ទៅឡាំសឹង ទៅស្រុកវៀតណាម។ ក៏ប៉ុន្តែដោយឈ្មោះ អ៊ុក សំអឿន ឃើញខ្ញុំតូចទាបជាងគេ ក៏គាត់ហៅចេញពីកងមក គាត់មិនឲ្យទៅណា ក៏ឲ្យខ្ញុំនៅជាអង្គរក្សរបស់គាត់ ការពារគាត់ផ្ទាល់។ បាទប៉ុណ្ណឹង។

**ស៖** នៅពេលដែល អ៊ុក សំអឿន ហ្នឹងគាត់ចុះទៅប្រតិបត្តិការផ្សេងៗហ្នឹង លោកមានការពារគាត់ទេ? ការពារពេលដែលគាត់ចុះទៅណាមកណាហ្នឹង លោកតាមការពារគាត់រហូត ឬក៏យ៉ាងម៉េច?

[១០:៤១:០៤]

**ឆ៖** បាទ ខ្ញុំជាអ្នកការពារគាត់ក្នុងមួយក្រុមនោះ ព្រោះគាត់បានចុះទៅដល់ម៉ាឡៃ ដល់ទៅសាលាអ៊ិនតាំ នៅម៉ាឡៃ។ ក្រោយមកទៀត មកនៅគេហៅព្រំដែនថៃ គឺនណង់សាំងណង់អៀន នៅប៉ោយប៉ែតនៅខាងត្បូងគីឡូលេខ៦ គឺតំបន់នោះ គឺខ្ញុំធ្លាប់ឈរជើង។ ទឹកដីនៅ ដីម៉ាឡៃនៅត្រង់សាលាអ៊ិនតាំ នៅហ្នឹងៗគឺនៅចំនួន២ខែទេ។ ងាកមកវិញ មកនៅវត្តណក់ហ៊ីន គោកនិមិត្តខែដន រួចបានដកទៅនៅគេហៅ ណង់សាំងណង់អៀន ព្រំដែនថៃនិងខ្មែរ ក៏ប៉ុន្តែគាត់ពុំសូវបាននៅជាប់លាប់ទេ។ គាត់ទៅតែមួយរយៈ គាត់ក៏ត្រឡប់មកវិញ ហើយខ្ញុំបាទក៏ត្រឡប់តាមគាត់មកវិញដែរ។ ទុកតែត្រឹមថ្នាក់ក្រោម ឲ្យនៅគ្រប់គ្រងកន្លែងនោះ។

**ស៖** ដូច្នេះមានន័យថា ក្នុងរយៈពេល២ឆ្នាំដែលលោកធ្វើជាកងទ័ព លោកកម្រចូលទៅសមរភូមិប្រយុទ្ធណាស់ មែនអ៊ីចឹងមែនទេ? តាមរយៈការរៀបរាប់របស់លោកនេះ លោកនិយាយអំពីការហ្វឹកហ្វឺនយោធា ហើយលោកការពារមេរបស់លោក ទៅកន្លែងមួយចំនួន។ អ៊ីចឹងខ្ញុំអាចសន្និដ្ឋានបានថា លោកបានទៅសមរភូមិប្រយុទ្ធហ្នឹងតិចតួចណាស់ មែនទេ?

**ឆ៖** បាទ ការពិតទៅខ្ញុំបានគ្រាន់តែបានហាត់រៀនយុទ្ធសាស្ត្រប៉ុណ្ណឹងទេ តែរឿងលើសមរភូមិខ្ញុំបាទពុំដែលទេ បាទពុំដែលសោះ។ មានតែជិះឡានអាហ្វ៊ីបអា-ដឺមួយគ្រឿង ហើយនិងមួយក្រុមខ្ញុំត្រូវទៅឯណា ទៅខេត្តសៀមរាប ត្រូវទៅខាងណាខាងណី ស្រេចនឹងគាត់។ ទៅឯណា គឺខ្ញុំតាមការពារគាត់។

**លោក អាកទូរ វែកកែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណ។ លោកមេធាវី គង់ សំអុន ក៏គ្មានសំណួរទៀតដែរ លោកប្រធាន។

[១០:៤៣:៥០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ការស្តាប់សក្ខីកម្មសាក្សី ឈុំ សេង ឥឡូវនេះ ដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះសូមអរគុណលោក ឈុំ សេង ដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាសាក្សី ក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ។ សក្ខីកម្មរបស់លោក នឹងរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ឥឡូវនេះ វត្តមានរបស់លោកនៅ

អ.វ.ត.ក លែងមានភាពចាំបាច់ហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោកជួយតែសំណាងល្អ មានសេចក្ដីសុខ សេចក្ដីចម្រើន នៅក្នុងដំណើរជីវិតរបស់លោក។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ឈុំ សេង វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះសូមអរគុណលោក ឌុច ផារី មេធាវីប្រឹក្សាសាក្សី សវនាការស្ដាប់សក្ខីកម្មសាក្សី ឈុំ សេង បានចប់ហើយ ដូច្នេះលោកអាចសម្រាកបានហើយ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-908 ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-908 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

*(សម្រាករយៈពេលខ្លី)*

[១០:៤៨:១០]

**ប្រធានអង្គជំនុំ៖**

លោក ឯម ហ៊ុយ ទៅពិនិត្យមើលមើល៍ តើមានបញ្ហាអ្វីបានជាមានការយឺតយ៉ាវនៅក្នុងការនាំសាក្សីចូលមកកាន់កន្លែងផ្ដល់សក្ខីកម្ម?

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអ្វី?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ តក់ ប៊ុយ។

**ស៖** អរគុណលោក តក់ ប៊ុយ។ ហើយតើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ? លោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ?

**ឆ៖** បាទ ខ្ញុំបាទកើតនៅថ្ងៃទី១០ ខែ១០ ឆ្នាំ១៩៥៤។

**ស៖** អរគុណ។ ហើយតើលោកកើតនៅទីកន្លែងណា?

**ឆ៖** បាទ ខ្ញុំបាទកើតនៅភូមិត្រពាំងថ្មខាងត្បូង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។

[១០:៥០:៤៥]

**ស៖** អរគុណ។ ចុះសព្វថ្ងៃវិញ តើលោករស់នៅទីកន្លែងណាដែរ?

**ឆ៖** បាទ សព្វថ្ងៃ ខ្ញុំកើត -- រស់នៅភូមិត្រពាំងថ្មខាងត្បូង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។

**ស៖** អរគុណ។ តើលោកប្រកបមុខរបបរកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** បាទ ខ្ញុំប្រកបមុខរបបធ្វើស្រែចម្ការ។

**ស៖** អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ តក់ ប៊ុន គាត់ស្លាប់នៅរបប ប៉ុល ពត។ ម្ដាយរបស់ខ្ញុំឈ្មោះ ប៊ុត គឹន គាត់ស្លាប់នៅរបប លន់ នល់។

**ស៖** អរគុណ ចុះភរិយារបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ ប្រពន្ធរបស់ខ្ញុំបាទឈ្មោះ ជឿន ចន្ថា។ កូនបង្កើតខ្ញុំមានប្រាំមួយនាក់ តែបច្ចុប្បន្នមានតែប្រាំ គ្រោះថ្នាក់ចរាចរណ៍ស្លាប់អស់មួយ។

**ស៖** អរគុណលោក តក់ ប៊ុយ។ តាមរបាការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមានមិនជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ទេ ហើយក៏មិនជាប់ញាតិលោហិត និងញាតិពន្ធជាមួយបុគ្គលទាំងឡាយដែលត្រូវទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០២ នេះទេ។ តើពិតមែនដែរទេ?

[១០:៥២:៤៥]

**ឆ៖** បាទ ខ្ញុំបាទមិនជាសាច់ឈាម ញាតិសន្ដាន ឬជាប់សាច់ញាតិជាមួយគាត់ទេ។

**ស៖** ចុះមុននឹងចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានស្បថនៅចំពោះមុខអ្នកដំបងដែកនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបាទមុននឹងឡើងមកកន្លែងនេះ ខ្ញុំបាទបានទៅស្បថនៅតាដំបងដែករួចហើយ។

**ស៖** អរគុណលោក។ ហើយជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈជា

សាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក តក់ ប៊ុយ ក្នុងឋានៈជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនលោក។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបទៅរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់សាក្សីរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សី លោកត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ តើលោកយល់អំពីសិទ្ធិ និងករណីយកិច្ចដែលយើងប្រាប់នេះដែរឬទេ?

[១០:៥៤:៣៨]

**ឆ៖** បាទ សូមលោកប្រធានបញ្ជាក់ម្ដងទៀត ខ្ញុំចាប់ចាំមិនទាន់បាន។

**ស៖** អំពីសិទ្ធិ គឺលោកមានសិទ្ធមិនឆ្លើយតបទៅនឹងសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោកដាក់ពិរុទ្ធភាពលើខ្លួនឯង។ បានន័យថា មានអំពើឧក្រិដ្ឋកម្មណាដែលលោកប្រព្រឹត្តដោយផ្ទាល់ ឬក៏បញ្ជាឲ្យប្រព្រឹត្តអ៊ីចឹង អានេះជាសំណួរដែលនាំឲ្យចម្លើយហ្នឹងដាក់ពិរុទ្ធភាពលើខ្លួនឯង។ អ៊ីចឹងលោកអាចឆ្លើយក៏បាន មិនឆ្លើយក៏បាន។ លោកអាចបដិសេធថា មិនឆ្លើយតបនឹងសំណួរនោះទេ ប្រសិនបើលោកសម្រេចចិត្តថាមិនឆ្លើយ។ ហើយចំពោះករណីយកិច្ច គឺលោកមានសិទ្ធិនៅក្នុងការ -- មានករណីយកិច្ចត្រូវតែឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគីពាក់ព័ន្ធសួរ ឬក៏ចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក ព្រោះលោកជាសាក្សី។ ប៉ុន្តែលើកលែងតែសំណួរណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយចំណែកឯកាតព្វកិច្ចមួយទៀត គឺលោកត្រូវឆ្លើយតែការណ៍ដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការកត់សម្គាល់ សង្កេតមើលដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយណាដែលពាក់ព័ន្ធនឹងការសួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោកយល់ទេ?

**ឆ៖** បាទ អ្វីដែលខ្ញុំឆ្លើយ គឺឆ្លើយក្នុងការខ្ញុំយល់ ខ្ញុំដឹង។ អ្វីដែលខ្ញុំមិនដឹង គឺខ្ញុំបាទមិនមានឆ្លើយ

ទេ តបទេ។ សូមអរគុណ។

[១០:៥៦:១៥]

**ស៖** បាទ នេះជាការត្រឹមត្រូវហើយ លោកបញ្ជាក់នេះគឺឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់សាក្សី ហើយ គឺឆ្លើយតែអ្វីដែលលោកដឹង លោកចងចាំ លោកបានឃើញ បានមានបទពិសោធន៍ជួបប្រទះតែប៉ុណ្ណោះ។ លោក តក់ ប៊ុយ តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា នៅពេលណា? លោកដែរទេ ហើយលោកចាំទេ?

**ឆ៖** បាទ កាលពីឆ្នាំ២០០៧ គឺបានទៅសម្ភាសរូបខ្ញុំបាទនៅដល់ផ្ទះផ្ទាល់តែម្តង។ រហូតដល់ឆ្នាំ២០០៨ គឺមានលិខិតអញ្ជើញឱ្យមកខ្ញុំ ទស្សនកិច្ចនៅគុកទួលស្លែង និងវាលពិឃាតជើងឯក និងកន្លែងនេះតែម្តង នៅតាដំបងដែក។ ដល់ឆ្នាំ២០១២ គឺបានចុះទៅសម្ភាសខ្ញុំ ដឹកនាំខ្ញុំទៅកន្លែងជីកប្រឡាយនៅស្ពានស្រែង រួចបានវិលត្រឡប់មកនឹងអាងត្រពាំងថ្ម។ ដល់ឆ្នាំ២០១៥ គឺមាននារី និមល ទៅជួបខ្ញុំផ្ទាល់នៅផ្ទះ។ បាទ សូមអរគុណ។

**ស៖** មានឱកាសណា ពេលណាមួយដែលគេធ្វើកំណត់ហេតុជាក់លាក់ ហើយសួរ ហើយកត់ត្រានូវសម្តីរបស់លោកឱ្យឆ្លើយបំភ្លឺដែរទេ?

**ឆ៖** បាទ មានកំណត់ហេតុ ហើយឱ្យឆ្លើយបំភ្លឺ មានឯកសារនោះស្រេច។

[១០:៥៨:១២]

**ស៖** ដឹងថាធ្វើ -- លោកចាំទេ ធ្វើនៅពេលណា ហើយនៅទីកន្លែងណា?

**ឆ៖** ដែលសម្ភាសរបស់ខ្ញុំបាទ គឺនៅនឹងកន្លែងផ្ទះរូបខ្ញុំបាទតែម្តង។

**ស៖** ហើយមុនពេលចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុននៅនឹងផ្ទះរបស់លោក ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ មានអានខ្លះ មានចាំបានខ្លះ។ បាទ សូមអរគុណ។

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុដែលស្តាប់ចម្លើយ ដែលលោកបានអានដើម្បីរំឭកការចងចាំ វាពិតជាត្រឹមត្រូវ ឬក៏វាស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកបានផ្តល់កិច្ចសម្ភាសន៍អង្កាល់ពីពេលមុន នៅនឹងផ្ទះរបស់

លោកនោះដែរឬទេ?

**ឆ៖** បាទ ព្រោះខ្ញុំបាទបានអាន ហើយនិងចងចាំ ព្រោះមានការដែលខ្ញុំឆ្លើយទៅយល់ព្រមទៅនឹងកំណត់ហេតុដែលគេបានកត់ត្រាទុក។

[១០:៥៩:៥១]

**ស៖** បាទ អរគុណ។ សូមលោកសង្រួមអារម្មណ៍ឲ្យបានល្អ ឲ្យបាននឹងនរ កុំព្រួយបារម្ភអី មិនខ្លាចអីទេនៅទីនេះ មិនមានអ្នកណាប៉ះពាល់ ឬក៏ធ្វើបាបលោកទេ គឺឲ្យលោកមកឆ្លើយបំភ្លឺដើម្បីស្វែងរកការពិតក្នុងរឿងក្ដីនេះ រួមវិភាគទានក្នុងការស្វែងរកការពិតប៉ុណ្ណោះ។ ហើយសូមលោកស្ដាប់ឲ្យបាននូវសំណួរដែលសួរ ហើយសូមឆ្លើយតប។ ក្នុងករណីលោកស្ដាប់ទៅមិនយល់នូវសំណួរដែលសួរ លោកអាចសុំឲ្យម្ចាស់សំណួរតាំងសំណួរនោះសាជាថ្មីម្ដងទៀត ដើម្បីលោកស្ដាប់យល់ ហើយនិងលោកឆ្លើយតប។

ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរដេញដោលរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថា ប្រសិនបើមានការផ្លាស់ប្ដូរយ៉ាងណានោះ ក៏អាចប្ដូរបានដែរ ព្រោះអង្គជំនុំជម្រះក្ដាប់មិនបាន រវាងទំនាក់ទំនងរវាងភាគីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាទេ។ ហើយសូមបញ្ជាក់ថា ភាគីទាំងពីរនេះមានពេលពីរវគ្គ នៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគី។ ចំពោះសាក្សីរូបនេះគឺខាងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកស្នើនៅក្នុងបញ្ជីសម្រាប់ស្ដាប់សាក្សី។ ដូច្នេះហើយបានជាយើងខ្ញុំបានពិភាក្សាជាមួយខាងសហព្រះរាជអាជ្ញា ដើម្បីសុំឲ្យខាងតំណាងមេធាវីនាំមុខសួរជាដំបូង។ បាទសូមលោកប្រធានជ្រាប។ ហើយសម្រាប់ខាងមេធាវីនាំមុខ គឺមេធាវីនាំមុខសូមអនុញ្ញាតផ្ទេរសិទ្ធិជូនលោក វ៉ែន ពៅ ដើម្បីសួរសាក្សីរូបនេះ។ បាទ សូមអរគុណលោកប្រធាន។

[១១:០១:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោក វ៉ែន ពៅ!

**លោក វ៉ែន ពៅ៖**

សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងសូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** បាទ ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ វ៉ែន ពៅ ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ នៅម៉ោងដំបូងនេះ គឺខ្ញុំនឹងចាប់ផ្តើមសំណួរសួរលោកអំពីបទពិសោធន៍របស់លោកដែលលោកបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមទាំងមូល។ សំណួរជាដំបូងរបស់ខ្ញុំដែលសួរលោក ខ្ញុំចង់ឲ្យលោកបញ្ជាក់ជូនអង្គសវនាការ ថាតើមុនៗថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកនៅឯណា? ហើយលោកមានតួនាទី ឬការងារជាអ្វីដែរបាទ?

**លោក គក់ ប៊ុយ៖**

**ឆ៖** បាទ ខ្ញុំបាទ គឺមុនឆ្នាំ១៩៧៥ ខ្ញុំបាទនៅភូមិត្រពាំងថ្ម ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង។ ហើយតួនាទីរបស់ខ្ញុំ ក្រោយពីការរៀនចប់ គឺគេត្រូវជ្រើសខ្ញុំចូលជាកងទ័ពធ្វើទាហាន លន់ នល់ បាទ។

[១១:០៣:១៩]

**ស៖** តើលោកចូលធ្វើជាទាហាន លន់ នល់ នៅឆ្នាំណា ហើយនៅកន្លែងណា កន្លែងដែលលោកឈរជើងនៅៗពេលនោះ?

**ឆ៖** បាទ គឺខ្ញុំធ្វើទាហាននៅឆ្នាំ១៩៧២ ហើយឈរជើងនៅស្រុកភ្នំស្រុកបាទ។

**ស៖** តើលោកមានតួនាទី ឋានៈជាអ្វីដែរបាទ? ជាពលទាហានធម្មតា ឬក៏មានឋានន្តរសក្តិអ្វីដែរបាទ?

**ឆ៖** បាទ ខ្ញុំបាទជាពលទោ ពុំមានឋានៈជាអ្វីទេបាទ។

**ស៖** សូមអរគុណ។ សំណួរជាបន្ទាប់ទៀតពាក់ព័ន្ធនឹងក្រោយថ្ងៃ១៧ មេសា ១៩៧៥ តើលោកនៅឯណា? ហើយលោកមានការងារតួនាទីជាអ្វីខ្លះដែរបាទ លោកអាចរៀបរាប់បានទេ?

**ឆ៖** បាទ ក្រោយថ្ងៃ០៧ មករា ឆ្នាំ១៩៧៥ ខ្ញុំបាទ រស់នៅភូមិត្រពាំងថ្មខាងត្បូង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង មានតួនាទីជាចល័តយុវជននៅក្នុងភូមិ។

**ស៖** លោកជាកងចល័តធម្មតានៅក្នុងភូមិ តើបន្ទាប់មកទៀត តើគេមានបញ្ជូនលោកទៅណាខ្លះទៀតដែរបាទ?

**ឆ៖** បាទ គឺខ្ញុំក្នុងនាមជាយុវជនមួយនៅក្នុងភូមិ គឺចល័តលើកភ្លឺស្រែនៅក្នុងភូមិ មិនបានទាន់ចល័តទៅអីណាទេ គឺនៅក្នុងភូមិឃុំតែម្តងបាទ។

[១១:០៥:១៦]

**ស៖** សំណួរខ្ញុំចង់បញ្ជាក់ថា តើលោកស្គាល់អាងត្រពាំងថ្មដែរទេបាទ?

**ឆ៖** បាទ ខ្ញុំបាទស្គាល់អាងត្រពាំងថ្ម គឺនៅនឹងទឹកដីរបស់ខ្ញុំបាទ ក្នុងភូមិរបស់ខ្ញុំបាទ។ ក៏ប៉ុន្តែពេលនោះដែលខ្ញុំនិយាយអំមិញពីបញ្ហា--

**ស៖** បាទៗលោក! ខ្ញុំសួរប៉ុណ្ណឹងសិន ហើយខ្ញុំសួរបន្តទៀតថា តើលោកដឹងថា អាងត្រពាំងថ្មហ្នឹងមានទីតាំងនៅឯណា? ហើយនៅតំបន់ណា ភូមិភាគណា? នៅសម័យនោះលោកដឹង ឬមានអ្នកណាប្រាប់លោកទេបាទ?

**ឆ៖** បាទ អាងទឹកត្រពាំងថ្មស្ថិតនៅក្នុងត្រពាំងថ្ម នៃតំបន់៥ នៃភូមិភាគពាយ័ព្យ។ អរគុណ។

**ស៖** តើលោកដឹងទេ មុនមានបើកការដ្ឋានអាងទឹកត្រពាំងថ្មនេះ ថាតើមានគេកោះប្រជុំប្រជាជននៅក្នុងភូមិ ក៏ដូចជាលោកផ្ទាល់បានទៅចូលរួមប្រជុំ ឬចូលជាពិធីសម្ពោធ មីទ្ទិងអីទេពាក់ព័ន្ធនឹងការចាប់ផ្តើមសាងសង់អាងទឹកត្រពាំងថ្មនេះ? បាទ លោកមានចងចាំ ឬនឹកឃើញរឿងនេះទេមុន?

**ឆ៖** បាទ ខ្ញុំអត់បានចងចាំ អត់បានដឹងទេ។ មិនដឹងគេធ្វើយ៉ាងម៉េចទេអាហ្នឹង ព្រោះមិនទាន់ដល់ពេលខ្ញុំណា។ បាទ សូមអរគុណ។

[១១:០៦:៥៤]

**ស៖** លោកអាចបញ្ជាក់បានទេ តើលោកធ្លាប់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹងដែរទេ? បើគេបញ្ជូនទៅ នៅពេលណា? លោកនៅនឹកឃើញ លោកនៅចងចាំទេ?

**ឆ៖** បាទ គេបញ្ជូនពួកខ្ញុំទៅ គឺនៅឆ្នាំ១៩៧៧ បានទៅលើទំនប់នៅអាងត្រពាំងថ្ម។ គេដកចេញពីភូមិបាទ។

**ស៖** ពេលគេបញ្ជូនលោកទៅហ្នឹង បញ្ជូនទៅជាក្រុម ឬទាំងអស់ អ្នកណាខ្លះដែលគេបញ្ជូនទៅ តែលោកម្នាក់ ឬក៏ជាក្រុម ទៅយ៉ាងដូចម្តេចបាទ?

**ឆ៖** បាទ ក្នុងកាលនោះ គេជ្រើសរើសឲ្យតែមានយុវជននៅក្នុងភូមិ នារីក្នុងភូមិ ដែលមិនមាន

គ្រួសារ ដែលនៅលីវ គឺគេបញ្ចូលឲ្យទៅរៀបចំជាកង ទៅកន្លែងចល័តតំបន់។ អរគុណ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ការបញ្ជូនទៅធ្វើការនៅទីនោះដំបូងហ្នឹង តើជាការបង្ខំលោកទៅ ឬជាការចាត់តាំងដោយការបង្ខំ ឬក៏ជាការស្ម័គ្រចិត្ត? តើលោកមានសិទ្ធិបដិសេធមិនទៅបានទេបាទ?

**ឆ៖** បាទ នៅពេលនោះ គឺគេបង្ខំ ឬគេតម្រូវ។ ដូច្នេះក្នុងរូបម្នាក់ៗមិនអាចបដិសេធបានទេ។ បើសិនជាបដិសេធត្រូវតែបាត់ខ្លួន គេដាក់ទិសទៅណាត្រូវតែទៅ។ បាទ សូមអរគុណ។

**ស៖** តើនៅពេលនោះ អ្នកណាអ្នកចាត់តាំងឲ្យលោកទៅ? លោកចាំឈ្មោះ ឬក៏ឋានៈគាត់ទេ អ្នកដែលចាត់តាំងឲ្យលោកទៅធ្វើការនៅទីនោះ ក្រុមលោកទៅនោះ?

[១១:០៨:៥០]

**ឆ៖** បាទ គឺប្រធានសហករណ៍អ្នកជ្រើសរើសឲ្យយុវជន និងយុវនារីចូលកងចល័តបាទ ព្រោះគាត់ឈ្មោះ ឈិន ប៉ុន្តែគាត់ស្លាប់បាត់ទៅហើយ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្ថែមទៀត ពាក់ព័ន្ធនឹងពេលដែលលោកទៅដល់ការដ្ឋាននោះ។ នៅពេលដែលលោកទៅនុ៎ង គឺនៅឆ្នាំលោកបានបញ្ជាក់ហើយ នៅឆ្នាំ១៩៧៧ តើជាដើមឆ្នាំ ចុងឆ្នាំ ឬក៏ពាក់កណ្ដាលឆ្នាំ លោកអាចចាំបានទេ?

**ឆ៖** បាទ បើខ្ញុំគិតទៅប្រហែលជាខែកុម្ភៈ ឆ្នាំ២០៧៧*(ស៊ិក)* ដែលរើសខ្ញុំចូលជាកងចល័ត ព្រោះពេលនោះជារដូវប្រាំង។

**ស៖** បាទ អ៊ីចឹងបានន័យថា ខែកុម្ភៈ ឆ្នាំ១៩៧៧ បាទ សូមអរគុណ។ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថា តើពេលលោកទៅដល់ដំបូង ក្រុមលោកហ្នឹងគេមាន -- នៅទីនោះ គេមានផ្ដល់ជាជម្រក ឬក៏កន្លែងស្នាក់នៅយ៉ាងម៉េចដែរ? លោកអាចបញ្ជាក់ជូនអង្គសវនាការបានទេ?

**ឆ៖** បាទ ការដែលជម្រកដែលនៅកន្លែងនោះ គឺថាដោះស្រាយដោយខ្លួនឯង គឺនាំគ្នាទៅកាប់ដើមឈើ យកមកធ្វើរោង ធ្វើត្រសាលនៅ។ គេគ្រាន់តែចាត់តាំងថា ឲ្យយើងទៅកាប់ដើមឈើធ្វើជម្រកដោយខ្លួនឯង គ្មានអ្នកណាគេដោះស្រាយឲ្យទេ។ បាទអរគុណ។

**ស៖** តើរោងៗដែលលោកថា ទៅធ្វើកាប់កូនឈើមកធ្វើខ្លួនឯង នៅចម្ងាយប៉ុនណាពីការដ្ឋាននោះ? នៅក្បែរនុ៎ង ឬនៅកន្លែងណា លោកអាចបញ្ជាក់ឲ្យច្បាស់ទៀតបានទេ?

[១១:១០:៥៨]

**ធ៖** បាទ រឿងធ្វើជម្រកនោះ ចម្ងាយពីការដ្ឋានអាងត្រពាំងថ្មទៅប្រហែលជា១គីឡូម៉ែត្រ បានដល់ព្រៃ ឬក៏ជិត៥០០ម៉ែត្រ។ បាទ អរគុណ។

**ស៖** ពាក់ព័ន្ធនឹងការចែកសម្លៀកបំពាក់ ក៏ដូចជាមុង ភួយ ថាតើអង្គការហ្នឹង គេមានចែកជាសម្លៀកបំពាក់ ឬមុងភួយដល់ក្រុមពលករ ឬក៏កងចល័តលោកដែរទេ ឬក៏លោកយកពីភូមិមក?

**ធ៖** ចូលទៅដល់ គឺមិនបានប៉ុន្មាននេះផង គេបើកខោមួយ អាវមួយឲ្យស្លៀកពាក់។ អាខោផាឌិប ជ្រលក់ពណ៌ខ្មៅ បាទ។

**ស៖** បាទ សូមអរគុណ។ មាន១ចែកជាមុង ឬភួយឲ្យដែរទេបាទ?

**ធ៖** បាទ មុង ភួយ អត់មានទេ ពួកខ្ញុំអត់។

**ស៖** ចុះដូចជាកន្ទេលអី អង្រឹងអីអត់មានទេ តើលោកក្រុមលោកហ្នឹង សម្រាកដោយៗរបៀបណាទៅ នៅលើរនាប ឬយ៉ាងម៉េចបាទ? សូមលោកបញ្ជាក់ពីស្ថានភាពនៃការស្នាក់នៅរបស់លោកបន្តិចបានទេ បាទ?

**ធ៖** បាទ ក្នុងនោះគឺមានខ្លះ ពុះឫស្សីបានធ្វើរនាប ដេក កន្ទេលអត់មាន ខ្លះមានបាវ បាវធ្វើជាអង្រឹង ដាក់ខ្សែសងខាង ចងជាអង្រឹង សម្រាន្តដេកនៅកន្លែងនោះតែម្តង។

**ស៖** បាទ សូមអរគុណ។ ហើយពាក់ព័ន្ធនឹងបន្ទប់ទឹក ក៏ដូចជាបង្គន់អនាម័យ តើមានខាងអង្គការ ឬក៏ប្រធានកង គេធ្វើជូនទេ ឬក៏យ៉ាងម៉េចដែរបាទ?

**ធ៖** បាទ កាលនោះអត់មានបន្ទប់ទឹក ឬបង្គន់អនាម័យធំដុំទេ គ្រាន់ថាតាមកងនីមួយៗ គឺដោះស្រាយជីកជាអន្លង់ជម្រៅកន្លះម៉ែត្រ កន្លះម៉ែត្របួនជ្រុង ទៅដាក់ឈើគងជាពីរទៅ បត់ជើងនៅពីលើនោះ ហើយនិងហ៊ុមស្បូវណា។ ឧបមាថាយើងឃើញអង្គុយទៅ ឃើញតែក្បាលត្រឹមនេះ លាក់តែគូទកុំឲ្យឃើញ ឃើញតែក្បាលនោះឯង។ ខ្លះទៅក៏បត់ដៃបត់ជើងតាមវាលតាមអី ពាសណាពាសណី។ សូមអរគុណ។

[១១:១៣:៥៦]

**ស៖** តាមការសង្កេតរបស់លោកនៅពេលនោះ ថាតើមានកងចល័តច្រើនទេបាទ ច្រើននាក់ទេដែលនៅធ្វើរោងតៗគ្នាហ្នឹង? លោកអាចបញ្ជាក់ច្រើន លោកអាចសន្និដ្ឋានបានទេ ប្រហែលជាប៉ុន្មានរយប៉ុន្មានពាន់នាក់ដែរ លោកអាចបញ្ជាក់បានទេ?

**ធ៖** បាទ ខ្ញុំមិនដឹងទេ ព្រោះវាច្រើន ព្រោះក្នុងនោះមានតាំងពីស្រុកថ្មពួក មង្គលបុរី ស៊ីសុផុន

ព្រះនេត្រព្រះ ភ្នំស្រុក ហើយនិងចល័តតំបន់ ដែលឲ្យខ្ញុំប៉ាន់ស្មានថា កម្លាំងចំនួនប៉ុន្មាននាក់ ខ្ញុំអត់បានដឹងទេ។ អរគុណ។

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងការងារនៅទីនោះជាក់ស្តែងដែរ ខ្ញុំចង់សួរលោក ថាតើលោក ក្រុមលោកនេះ ឬកងលោកនេះធ្វើការនៅត្រង់ណានៃអាងនោះ នៃទំនប់អាងត្រពាំងថ្មនោះ? នៅកណ្តាល នៅចំហៀង នៅចុង ឬយ៉ាងម៉េច កងរបស់លោកធ្វើការនោះ?

**ឆ៖** បាទ កងពួកខ្ញុំ គឺបើនិយាយទៅនៅខាងជើងស្ពានទី១ ត្រង់បត់កែង មិនបាននៅចំកណ្តាលឬក៏នោះទេ។ មិនដល់ជាចុងទេ ចុងខាងជើង មិនដល់ចុង នៅខាងជើងស្ពានទី១។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់បានទេ នៅទីនោះលោកមានឋានៈជាអ្វីដែរ? ជាកងចល័តធម្មតា ឬក៏មានមុខងារអ្វីដែរ?

**ឆ៖** បាទ នៅក្នុងនោះខ្ញុំបាទគឺក្នុងនាមជាប្រធានកងតូចមួយរូប។

**ស៖** ថាតើមុខងារលោកជាប្រធានកងតូចនៅទីនោះ លោកមានអ្នកនៅក្រោមបង្គាប់លោកប៉ុន្មាននាក់ដែរ ក្រុមលោក កងលោក កូនចៅលោកនោះ?

**ឆ៖** បាទ នៅក្រោមបង្គាប់របស់ខ្ញុំគឺមានពីរនាក់ មួយអនុប្រធាន ពីរសមាជិក ប៉ុន្តែគាត់ស្លាប់បាត់អស់ហើយ។ ធ្វើទាហានទៅគាត់ស្លាប់។

**ស៖** លោកអាចបញ្ជាក់ឲ្យច្បាស់ជាងនេះទេថា កូនចៅលោកមានតែពីរនាក់ គឺមួយកងតូចមានគ្នាប៉ុន្មាននាក់ សរុបកងចល័តទាំងអស់? ឬក៏លោកគិតតែសមាជិក និងអនុលោក ដែលលោកថាពីរនាក់នេះបាទ? សូមលោកបញ្ជាក់ឲ្យច្បាស់។

**ឆ៖** ក្នុងកងតូចរបស់យើងខ្ញុំមាន៣០នាក់។ មិនមែនត្រឹមតែពួកខ្ញុំទេ មានសមាជិកនៅក្នុងក្រុម៣០នាក់។ ប៉ុន្តែនៅក្នុងនោះមិនមែននៅក្នុងភូមិខ្លួនឯងទេ មានលាយឡំពីខាងណេះខាងណោះ ហើយមកពីភ្នំពេញ កាលសម័យនោះគេជម្លៀសទៅ។

[១១:១៧:២៥]

**ស៖** បាទ អ៊ីចឹងបានន័យថានៅក្នុងកងលោក៣០នាក់នោះ មានអ្នកមូលដ្ឋានខ្លះ និងមានពួកថ្មីបានន័យថាប្រជាជនថ្មី គឺពួក១៧មេសា ដែលជម្លៀសពីភ្នំពេញទៅ។ លោកអាចបញ្ជាក់បានទេ រវាងការងាររវាងអ្នកមូលដ្ឋានចាស់ ហើយនិងពួក១៧មេសាហ្នឹង មានការបែងចែកភាពខុសប្លែកគ្នាដែរទេ?

**ឆ៖** បាទ ត្រង់ណោះគឺខ្ញុំយល់ដឹងថា បើនិយាយទៅគឺអ្នករំដោះ១៧មេសាដូចគ្នា ក៏ប៉ុន្តែមួយនៅ

នឹងមូលដ្ឋាន មួយទៅពីទីក្រុងភ្នំពេញ។ អាចសន្និដ្ឋានបានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ តែខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើស្ថានភាពចែកការងារឲ្យធ្វើហ្នឹង ចែកឲ្យរែកដី ឬក៏លើកទំនប់នុំង ថាតើអ្នក១៧មេសា និងពួកមូលដ្ឋានចាស់ហ្នឹងមានចែកចំនួនដីរែកដូចគ្នា ឬក៏មានភាពខុសគ្នាបាទ?

**ឆ៖** បាទ អត់មានចែកជាឋានៈ ឬជាៗៗអីទេ គឺថា៣ម៉ែត្រគូបដូចគ្នា ទាំងមេកង ទាំងមេក្រុម ទាំងសមាជិកក្រុមទាំងអស់ ឲ្យតែនៅក្នុងក្រុម គឺដីចំនួនប៉ុនណា គឺដូចគ្នាត្រង់ណោះ។

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនៅក្នុងនាមលោកជាប្រធានកងតូចនោះ ថាតើមានដែលមានផែនការ ឬឲ្យលោករៀបចំជាប្រជុំអីញឹកញាប់ដែរទេ នៅក្នុងក្រុម?

**ឆ៖** បាទ មិនសូវជាបានប្រជុំញឹកញាប់ទេ គ្រាន់យូរៗម្តង។ គ្រាន់តែដាស់តឿនថា កុំឲ្យមានឈឺទម្រន់ស្អក់អីណា។ បាទ សូមអរគុណ។

[១១:១៩:២៨]

**ស៖** ចុះពាក់ព័ន្ធនឹងប្រវត្តិរូបវិញ ថាតើពេលប្រជុំ ឬក៏មានផែនការឲ្យក្រុមលោក ឬក៏តាមដានកូនក្រុម ឲ្យស្រាវជ្រាវប្រវត្តិអីដែរទេ?

**ឆ៖** បាទ មិនដែលបានតាមដានទូវប្រវត្តិរូបទេ ព្រោះខ្ញុំបាទជាទាហានផង ដល់តែពេលនោះខ្ញុំខ្លាចខ្លួនឯងថា បើសិនជាគេដឹងថាខ្ញុំជាទាហាន ជាអី អានោះថ្ងៃណាមួយនឹងបាត់ខ្លួន។ ដូច្នេះខ្ញុំមិនបានថាតាមដានរឿងប្រវត្តិរូបនៅក្នុងសមាជិករបស់ខ្លួនឯងទេ។ មិនដឹងជាអ្នកនោះជាស្អីទេ។

**ស៖** បើនិយាយខ្លី ហាក់ដូចលោកបង្ហាញថា តើលោកនៅក្នុងសម័យនេះលោកលាក់ប្រវត្តិរូបលោកមែនទេ?

**ឆ៖** បាទ ខ្ញុំបាទលាក់ដែរ ក៏ប៉ុន្តែលាក់មិនបានជាជិតទេ គ្រាន់ថាជាតិចតួច បន្តិចបន្តួច។ ខ្ញុំតែងជួបដូចជាថា គេដកមេកងនេះទៅបាត់ ហើយផ្លាស់មេកងទៀត ខ្ញុំក៏លាក់ប្រវត្តិរូប គឺធ្វើទាហានបន្តិចបន្តួចៗ។ រហូតដល់និរតីចូលមក អានោះបានខ្ញុំឈប់ទៅជាស្វ័យត្រាណ ហើយប្រជាពលរដ្ឋធម្មតា។

**ស៖** សូមអរគុណ។ តើលោកអាចបញ្ជាក់ឲ្យច្បាស់ថែមទៀតបានទេថា មូលហេតុអ្វីបានជាលោកភ័យខ្លាច រហូតដល់លាក់ប្រវត្តិរូប? តើមានព័ត៌មានអី ឬក៏លោកបានដឹងហេតុការណ៍អ្វីចំពោះអ្នកដែលជាជាទាហាន លន់ នល់ ឬយ៉ាងណាបាទ? លោកអាចបញ្ជាក់ច្បាស់បានទេ?

[១១:២១:១៨]

**ឆ៖** បាទ គឺនៅពេលនោះ បើសិនឮថាទាហាន ឬក៏ប៉េ.អឹម ឬក៏គយ គិញអីណាមួយនោះ គឺគេមិនអាចទុកទេ គេត្រូវតែសម្លាប់ចោល។

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងការចែកការងារ អំមិញលោកបានបញ្ជាក់ហើយថា គេចែកឱ្យលោក ឬក៏កងចល័តនោះធ្វើការរែកដីយ៉ាងហោចណាស់ក៏៣ម៉ែត្រគូបដែរក្នុងមួយថ្ងៃ។ សំណួររបស់ខ្ញុំសួរថា តើមានក្នុងក្រុមរបស់លោក ឬក៏មានចល័តកងចល័តណាដែលធ្វើមិនហើយ តើគេដាក់ពិន័យបែបណា បើគាត់ធ្វើមិនហើយតាមផែនការកំណត់នោះបាទ?

**ឆ៖** បាទ ដូច្នេះគឺកម្លាំងពួកខ្ញុំបាទេ គឺផែនការដាក់ទិស ប៉ុន្តែមុនដំបូងមិនបានជា៣បីម៉ែត្រគូបទេ គឺក្នុង២ម៉ែត្រគូប។ បើធ្វើរួច គេដំឡើងទៀតណ៎ា រហូតដល់មួយថ្ងៃ៣ម៉ែត្រគូប។ ដូច្នេះក្នុងម្នាក់ៗគឺប្រឹង មិនមានថាអ្នកណាធ្វើមិនរួចទេ ធ្វើរួចដូចគ្នា។

**ស៖** ខ្ញុំសូមធ្វើសួរសំណួរបញ្ជាក់ទៅក្រោយបន្តិច។ អំមិញលោកថា បើសិនបើគេដឹងថាជាទាហាន ឬក៏ជាគយ ជាគិញអី គេនឹងយកទៅសម្លាប់ចោល។ ថាតើការដែលដឹងឮអស់នេះ លោកដឹងដោយរបៀបណា? មានប្រធានកង ថ្នាក់លើលោកប្រាប់លោក ឬក៏អ្នកណាអ្នកប្រាប់លោក លោកអាច -- ឬជាគោលនយោបាយទាំងមូលរបស់អង្គការ លោកដឹងដោយរបៀបណាបាទ?

**ឆ៖** ខ្ញុំបាទ គឺមិនមែនថ្នាក់លើផ្សព្វផ្សាយឬក៏ដាក់ទិសទេ គឺឃើញថា នៅៗឃើញថាបាត់ខ្លួន នៅៗបាត់ខ្លួន។ ដូច្នេះខ្ញុំសម្គាល់ថាដែលបាត់នោះ គឺទាហាននៅនឹងភូមិរបស់ខ្ញុំបាទ។ ដូច្នេះបានខ្ញុំបាទចេះតែភ័យលាក់ប្រវត្តិរូប រហូតដល់ខ្ញុំមិនបាននៅក្នុងភូមិ ចេញក្រៅភូមិ។

[១១:២៣:៣៧]

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងម៉ោងពេលធ្វើការវិញ។ តើលោកអាចបញ្ជាក់បានទេ តើចាប់ផ្ដើមពីម៉ោងប៉ុន្មាន ដល់ម៉ោងសម្រាកម៉ោងប៉ុន្មាន ហើយចូលធ្វើការវិញម៉ោងប៉ុន្មានក្នុងមួយថ្ងៃៗនោះ?

**ឆ៖** បាទ ព្រឹកឡើងពីម៉ោងប្រាំពីរដល់ម៉ោងដប់មួយ។ ពីម៉ោងពីរដល់ម៉ោងប្រាំបានចប់ ក្នុងមួយថ្ងៃសម្រាក។

**ស៖** តើលោកមានដឹងទេ នៅអាងត្រពាំងថ្មនោះ មានធ្វើការនៅពេលយប់ដែរទេ ក្រៅតែពីអ្វីដែលលោកបានដឹងថាធ្វើដល់ម៉ោងប្រាំសម្រាកនេះ?

**ឆ៖** បាទ ព្រោះនៅពេលយប់គឺធ្វើ ថ្ងៃក៏ធ្វើ ក៏ប៉ុន្តែមុនដំបូងគេធ្វើថ្ងៃ ដល់ពេលនេះទៅគេ

ចម្រាញ់ៗយកអ្នកដែលខ្លាំក់មាន់ឲ្យធ្វើការថ្ងៃ អ្នកណាដែលមិនខ្លាំក់មាន់គឺលើកនៅពេលយប់។

**ស៖** សូមអរគុណ។ តើលោកធ្លាប់ឮពាក្យ "កងករណី" ដែរឬទេ នៅពេលដែលលោកធ្វើការនៅទំនប់អាងត្រពាំងថ្មនោះ?

**ឆ៖** បាទ នៅក្នុងនោះខ្ញុំអត់ដឹងទេរឿងកងករណី ព្រោះវានៅដោយឡែកផ្សេងពីគ្នា។

**ស៖** ពាក់ព័ន្ធនឹងកំហុសដែរ តើលោកដែលធ្លាប់ជួបប្រទះ ឬដឹងថាមានអ្នកដែលខុសសីលធម៌អីទេបាទ មានធ្លាប់ឮ ឬដែលចូលរួមមីទ្ទិងពាក់ព័ន្ធនឹងអ្នកខុសសីលធម៌អីដែរទេ?

[១១:២៥:៤១]

**ឆ៖** បាទ ខ្ញុំបាទគ្រាន់តែឮ អារឿងខុសសីលធម៌ខុសអី ក៏មិនដឹងថាយ៉ាងម៉េចយ៉ាងណានោះទេ ព្រោះខ្ញុំអត់បានដឹងទេ នៅដោយឡែកផ្សេងពីគ្នា។ តែការចូលរួមមីទ្ទិង គឺពេលមីទ្ទិងតែពេលដែលចូលឆ្នាំប៉ុណ្ណោះ។

**ស៖** តើមីទ្ទិងនោះ គេៗធ្វើអំពី -- គេនិយាយអំពីអ្វីទៅបាទ លោកថាពេលចូលឆ្នាំនោះ?

**ឆ៖** ខ្ញុំចាំអត់បានទេ វាយូរណាស់ទៅហើយអារឿងការធ្វើមីទ្ទិង។ គ្រាន់តែគេចាក់វិទ្យុទៅ គ្រាន់តែអង្គុយតាមកង អង្គុយទះដៃ ឃើញថ្នាក់លើគេទះដៃម៉េច ក៏ទះតាមគេ។ អារឿងការចងចាំរបស់ខ្ញុំបាទ គឺចាំមិនបាន។ បាទ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ សំណួរខ្ញុំចុងក្រោយមួយទៀតពាក់ព័ន្ធនឹងយើងជិតដល់ម៉ោងសម្រាកហើយ។ ខ្ញុំចង់សួរលោកថាតើនៅពេលដែលកងចល័តទាំងអស់កំពុងធ្វើការនៅទីនោះ តើមានកងឈ្លបឬមួយទាហានអីយាមកាមអីទេបាទ?

**ឆ៖** បាទ កន្លែងដែលខ្ញុំធ្វើការគ្មានយោធា ឬក៏កងឈ្លបណាទៅបៀតទេណា និយាយថាធ្វើតែឯង។ ពេលដែលពេលយប់ អានោះមានពួកយោធាគេដើរធ្វើការ មិនដឹងថាគេដើរយ៉ាងម៉េច យ៉ាងណានោះទេ យើងតាមយើង គេតាមគេប៉ុណ្ណោះ។

**លោក វ៉ែន ពៅ៖**

លោកប្រធាន ខ្ញុំមើលម៉ោងដូចដល់ម៉ោងហើយ ខ្ញុំសូមផ្អាកប៉ុណ្ណឹងសិនបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

[១១:២៧:៤២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាគួរតែមានការបញ្ជាក់ពាក់ព័ន្ធនឹងសាក្សីរូបនេះ ពីព្រោះថា លោក តក់ ប៊ុយ គាត់បង្ហាញខ្លួនក្នុងនាមជាសាក្សី ក៏ប៉ុន្តែខ្ញុំសូមបញ្ជាក់ថាក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០៤ លោក តក់ ប៊ុយ ជាដើមបណ្តឹងរដ្ឋប្បវេណី ហើយឯកសារពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នៅក្នុងសំណុំរឿង០០២ មានលេខដូចតទៅគឺ E319/25.3.48 និង E319/25.3.48/1។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ក្នុងសំណុំរឿង០០២ ឬក៏សំណុំរឿង០០៤ នៅគាត់តាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី លោកបញ្ជាក់ខ្មែរ ភាសាខ្មែរក្នុងសំណុំ០០២។ យើងបានកោះហៅគាត់ជាសាក្សីក្នុងឋានៈជាសាក្សីនៅក្នុងសំណុំរឿង ០០២ នៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ មិនមែនឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

មិនមានការលំបាកអ្វីនៅក្នុងក្របខ័ណ្ឌ នៅក្នុងសំណុំរឿង០០២ទេ។ ខ្ញុំគិតថាប្រហែលមានបញ្ហាបកប្រែ។ តែគេស្តាប់ខ្ញុំឮទេ ខ្ញុំបាននិយាយអម្បាញ់មិញនេះថានៅក្នុងសំណុំរឿង០០២ លោក តក់ ប៊ុយ មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីទេ គាត់មកបង្ហាញខ្លួនជាសាក្សី។ ក៏ប៉ុន្តែដើម្បីតម្លាភាព និងជាព័ត៌មានជូនទៅដល់ភាគី ខ្ញុំសូមបញ្ជាក់ថានៅក្នុងសំណុំរឿង០០៤ លោក តក់ ប៊ុយ ជាដើមបណ្តឹងរដ្ឋប្បវេណី។ ហើយខ្ញុំសូមបញ្ជាក់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤ ត្រូវបានបញ្ជូនមកក្នុងសំណុំរឿង០០២ ហើយខ្ញុំបានឲ្យលេខយោងរួចមកហើយ ដែលមាននៅក្នុងសំណុំរឿង០០២ ហើយភាគីអាចពិនិត្យមើលបាន ហើយដូច្នេះឯកសារគាត់នេះ ឥឡូវនេះគឺវាស្ថិតនៅក្នុងសំណុំរឿង០០២។

[១១:៣០:២៨]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមឆ្លើយតបសង្ខេបទេ។ ខ្ញុំឆ្ងល់ដែរថា ហេតុអ្វីបានជាក៏ត្រូវបានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរមុនទៅវិញ ដោយសារថាគាត់ជាសាក្សី។ ខ្ញុំមិនដឹងដែរថា ប្រសិនបើជាអ្នកណាម្នាក់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤ តើគេត្រូវបញ្ជូនពាក្យសុំរបស់គាត់ដាក់មកចូលសំណុំរឿងយើង តើនៅជាដើមបណ្តឹងរដ្ឋប្បវេណីដដែល ឬក៏យ៉ាងណា?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រហែលជាមានការយល់ច្រឡំហើយ។ ខ្ញុំសូមនិយាយជាភាសាអង់គ្លេស លោកចៅក្រមឡាវែន៍ គាត់និយាយថា គាត់ជាសាក្សីនៅទីនេះ ឋានៈរបស់គាត់គឺជាសាក្សី។ សម្រាប់បញ្ហាតម្លាភាពវិញ ថាបុគ្គលនេះបានដាក់ពាក្យ និងបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤ ដូច្នេះគាត់មានឋានៈពីរ។

**លោក វ៉ិចទ័រ កូប៉េះ៖**

ចុះក្នុងករណីនេះ ហេតុអីក៏មេធាវីនាំមុខចាប់ផ្តើមមុនទៅវិញ?

[១១:៣១:៣៧]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមបញ្ជាក់ថា ដោយអនុវត្តតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ហើយនិងបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងដែលអង្គជំនុំជម្រះផ្តល់ទៅឲ្យភាគីម្ចាស់សំណើសុំសួរមុន។ យើងបានបញ្ជាក់ហើយ សាក្សីរូបនេះនៅក្នុងសំណុំរឿង០០២ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាម្ចាស់សំណើ ជាអ្នកស្នើសុំឲ្យស្តាប់សក្ខីកម្មសាក្សីរូបនេះ។ នេះជាការអនុវត្តដែលយើងបានបញ្ជាក់តាមវិធានផ្ទៃក្នុង ដែលតម្រូវឲ្យប្រធានអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាចនៅក្នុងការសម្របសម្រួលក្នុងការរៀបចំកាលវិភាគសវនាការទៅតាមអាទិភាពនៃ ដែលខ្លួនយល់ឃើញថាសមស្រប។

បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី នៅរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ នៅចំពោះមុខអង្គជំនុំជម្រះនេះ នៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោយសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:០៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

បាទ សូមផ្អាកតិចសិន! សូមអញ្ជើញលោក អាកទូរ វែកគែន!

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់មួយ ឬក៏ជាសំណួរមួយ។ ខ្ញុំមិនថា តើហៅយ៉ាងម៉េចឲ្យត្រូវទេ។ គឺបន្ទាប់ពីការកត់សម្គាល់របស់លោកចៅក្រម ឡាវែន៍ ដែលគាត់បញ្ជាក់ថា មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សាក្សីរូបនេះនៅក្នុងសំណុំរឿង០០៤។ ខ្ញុំចង់ដឹងថា តើអង្គជំនុំជម្រះសម្រេចដាក់ចូលឯកសារនេះទៅក្នុងសំណុំរឿងជាស្វ័យប្រវត្តិតែម្តង ឬក៏យ៉ាងម៉េច? តាមរយៈលោក លីសាក់ លោកសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ខ្លួននឹងធ្វើបែបនេះ ក៏ប៉ុន្តែសាក្សីរូបនេះមកផ្តល់សក្ខីកម្មលឿនជាងអ្វីដែលបានគ្រោងទុក។ ខ្ញុំដឹងថា វាជាចម្លើយពីមុនរបស់សាក្សី។ ចំពោះខ្ញុំៗមិនមានពេលវេលាគ្រប់គ្រាន់ទេ ពីព្រោះថាសាក្សីរូបនេះមកលឿនពេក ខ្ញុំមិនទាន់បានត្រៀមខ្លួនបានរួចរាល់ ហើយខ្ញុំមិនទាន់បានអានសក្ខីកម្មពីមុនរបស់គាត់ទេ ហើយក៏មិនទាន់បានអានពាក្យសុំតាំងខ្លួនរបស់គាត់ដែរ។ ដូច្នេះខ្ញុំចង់ដឹងថា តើអង្គជំនុំជម្រះដាក់បញ្ចូលឯកសាររបស់គាត់ជាភស្តុតាង ជាស្វ័យប្រវត្តិតែម្តង ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំស្ដាប់ការបកប្រែជាភាសាអង់គ្លេសអត់បានទេ អត់ឮទេអម្បាញ់មិញ។ ដើម្បីជាប្រតិចារឹក គឺថាឯកសារទាំងអស់នេះគឺត្រូវបានដាក់បង្ហាញ ហើយភាគីទាំងអស់មានលទ្ធភាពអាចទទួលបានឯកសារនេះហើយ។ ដូច្នេះ យើងខ្ញុំមិនជំទាស់ទៅនឹងឯកសារនេះទេ។

**ប្រធានអង្គជំនុំ៖**

យើងនៅដូចជាមិនទាន់ច្បាស់លាស់នៅឡើយទេ។ លោកដាក់បង្ហាញ ហើយលោកមិនជំទាស់ មិនមានន័យថា ឯកសារដែលលោកដាក់បង្ហាញ ខាងការិយាល័យសហព្រះរាជអាជ្ញាដាក់បង្ហាញអាចយកមកដេញដោលបានទេ។ បានបញ្ជាក់រួចហើយ ការដាក់បង្ហាញឱ្យភាគីដឹង គ្រាន់តែដើម្បីជាតម្លាភាពប៉ុណ្ណោះ។ ការដើម្បីឱ្យឯកសារមួយអាចយកមកដេញដោលបាន លុះត្រាតែភាគីដែលដាក់បង្ហាញនោះ ស្នើសុំមកអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះចេញសេចក្ដីសម្រេចទទួលយកជាភស្តុតាងដាក់នៅក្នុងសំណុំរឿង០០២ ដាក់ដេញដោល។ នេះសូមឱ្យច្បាស់លាស់ កុំនិយាយអាចនិយាយគឺសង្ខេបពេក ដែលកម្រិតយល់ដឹងប្រហែលជាអាចនឹងមានបញ្ហា។ យើងប៉ុន្មានថ្ងៃនេះ ក៏ចង់បញ្ជាក់បញ្ហាហ្នឹងឱ្យច្បាស់លាស់ដែរ។

ហើយខ្ញុំគ្រាន់តែបញ្ជាក់បញ្ហាអ៊ីចេះទេលោក អាកទួរ វែកគែន សំណុំឯកសារដែលបានលើកឡើងដោយលោក ហ្សង់ម៉ាក ឡាវែន៍ នេះគឺបានចំណាត់ជាឯកសារ E319/25 នេះរួចហើយ ហើយគឺមិនដឹងថា តើបញ្ហាហ្នឹងវាពាក់ព័ន្ធនឹងការបានទទួលយកបានកម្រិតណាដែរ ដោយសារតែបញ្ហាអម្បាញ់មិញនេះ យើងក៏កំពុងតែសិក្សាស្វែងយល់អំពីបញ្ហានេះឱ្យបានច្បាស់លាស់ដែរ។ ពីព្រោះយើងមានកំហិតច្បាស់លាស់លើបញ្ហានេះ ក្នុងព្រំដែននៃការដាក់បង្ហាញឯកសាររបស់ខាង អូ.ស៊ី.ភី ខាងការិយាល័យសហព្រះរាជអាជ្ញាពីសំណុំរឿងផ្សេងមកនេះ យើងបានព្រមទទួលយកតាមយុត្តិសាស្ត្រអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិដែលគេធ្លាប់ប្រើ ហើយយើងបានបញ្ជាក់គ្នាច្បាស់ហើយថាគ្រាន់តែជាការដាក់បង្ហាញប៉ុណ្ណោះ។ ហើយចំណែកឯឯកសារថាយកជាភស្តុតាងយកមកដាក់ដេញដោលបាន លុះត្រាតែភាគីដែលពិនិត្យមើលឯកសារពាក់ព័ន្ធនោះស្នើសុំ ហើយអង្គជំនុំជម្រះពិនិត្យលើសំណើសុំរបស់ភាគី ហើយសម្រេចទទួលយកជាភស្តុតាង ដាក់បញ្ចូលទៅក្នុងសំណុំរឿងជាភស្តុតាងទើបភាគីអាចយកឯកសារនោះមកពិភាក្សាដេញដោលបាននេះ។

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៣:៣៤:៥០]

**លោក អាកទួរ វែកគែន៖**

ខ្ញុំឯកភាពទាំងស្រុងជាមួយលោក លោកប្រធាន។ ហេតុនេះហើយបានជាខ្ញុំលើកអំពីចំណុចនេះ ដោយរំឭកថា នៅថ្ងៃនេះទោះបីជាមានការប្រកាសដោយលោក លីសាក់ នៅពេលដែលគាត់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្រហែលជា៥០ជាង កាលពីប៉ុន្មានសប្ដាហ៍មុននោះ។ គាត់បានបញ្ជាក់ថា ឯកសារហ្នឹងមិនសូវមានព័ត៌មានសំខាន់ប៉ុន្មានទេ លើកលែងតែពាក្យសុំតាំងខ្លួនរបស់លោកសាក្សីនេះ។ ដូច្នេះខ្ញុំគិតថា នៅពេលនោះ គួរតែមានការស្នើសុំឲ្យដាក់ជាភស្តុតាង។ ហើយនៅថ្ងៃនេះ សាក្សីគាត់មកផ្ដល់សក្ខីកម្ម ហើយមិនមានការស្នើសុំពាក្យសុំតាំងខ្លួនរបស់គាត់ដាក់ជាភស្តុតាងទេ ទោះបីជាមានការប្រកាសរបស់លោក លីសាក់ ក៏ដោយ ខ្ញុំកត់សម្គាល់ឃើញថា បណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាមិនបាននិយាយអំពីឯកសារនេះ នៅក្នុងបញ្ជីរបស់ខ្លួនមុនពេលដែលសាក្សីនេះមកផ្ដល់សក្ខីកម្មទេ។ អង្គជំនុំជម្រះបានបញ្ជាក់រួចមកហើយ។ ហើយមកដល់ថ្ងៃនេះ គឺអត់ទាន់មានពាក្យសុំអីមួយទេ។ ខ្ញុំអត់មានពេលទេ ហើយខ្ញុំក៏មិនទាន់បានធ្វើសំណើអ្វីដែរ ហើយភាគីក៏មិនទាន់មានអ្នកណាមួយធ្វើសំណើដែរ។ ហើយលោកចៅក្រម ឡាវែន៍ បានបញ្ជាក់ថា ឯកសារនេះមានរួចហើយ វាជាចម្លើយពីមុនរបស់សាក្សី ខ្ញុំគិតថា ប្រហែលជាមិនមានការបកប្រែទេ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់ដឹងថាតើអង្គជំនុំជម្រះទទួលយកឯកសារនេះ ជាភស្តុតាងដោយស្វ័យប្រវត្តិតែម្ដង ឬក៏យ៉ាងម៉េច?

[១៣:៣៦:៤៤]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមផ្ដល់ការកត់សម្គាល់។ ឯកសារត្រូវបានដាក់បង្ហាញរួចមកហើយ ដូចមេធាវីការពារក្ដីទាំងពីរដែរ យើងបានដឹងអំពីឯកសារនេះ។ ការអនុវត្តរបស់យើងគឺថា ឯកសារត្រូវបានដាក់បង្ហាញជូនទៅឲ្យភាគីទាំងអស់នៅក្នុងសំណុំឯកសារអេឡិចត្រូនិច ដែលភាគីទាំងអស់អាចចូលមើលបាន។ យើងមានលទ្ធភាពអាចប្រើប្រាស់ឯកសារទាំងអស់នោះបាន។ ហើយចំពោះយើង យើងបានដាក់ឯកសារទាំងអស់នោះនៅក្នុង*អ៊ីនធើហ្វេស*កាលពីម្សិលមិញ ដើម្បីជូនដំណឹងដល់ភាគីទាំងអស់ ថាយើងនឹងប្រើប្រាស់ឯកសារទាំងអស់នេះ។ ហើយនៅពេលក្រោយ នឹងមានការសម្រេចថាតើយើងធ្វើសំណើផ្លូវការ យោងតាមវិធាន៨៤(៤) ឬក៏យ៉ាងម៉េច? ក៏ប៉ុន្តែចាប់តាំងពីពេលដាក់បង្ហាញមក ភាគីមានសិទ្ធិអាចប្រើប្រាស់ឯកសារបាននៅក្នុងសវនាការ ហើយភាគីទាំងអស់មាន

សិទ្ធិដាក់សំណើយោងតាមវិធាន៨៧(៤) ក៏ប៉ុន្តែខ្ញុំបាននឹកឃើញអំពីករណីជាច្រើនដែលមេធាវីការពារក្តីបានប្រើប្រាស់កំណត់ហេតុដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញា ហើយបន្ទាប់មកគាត់យកឯកសារមកប្រើប្រាស់នៅក្នុងសវនាការ ហើយគាត់មិនបានធ្វើសំណើជាក់លាក់យោងតាមវិធាន ៨៧(៤)នោះទេ។ ដូច្នេះ យើងអនុវត្តទៅតាមទម្លាប់អនុវត្តជាក់ស្តែងនៅចំពោះមុខអង្គជំនុំជម្រះ យើងបានបញ្ជាក់ជូនភាគីរួចមកហើយ ថាយើងចង់ប្រើប្រាស់ឯកសារទាំងអស់នេះ ក៏ប៉ុន្តែយើងមិនមានពេលគ្រប់គ្រាន់ក្នុងការដាក់សំណើដែលយោងតាមវិធាន៨៧(៤)នោះទេ។ ខ្ញុំគិតថា ខ្ញុំបានឆ្លើយតប ទៅនឹងចម្លើយរបស់សហភាតាខ្ញុំរួចមកហើយ។

**លោក អាកទូរ វែកគែន៖**

ដូចជាមិនឆ្លើយតបប៉ុន្មានទេ។ គឺឯកសារទាំងអស់នេះ គឺថាមិនទាន់បានផ្តល់សុពលភាពមុននៅឡើយទេ ហើយតាមការពិតទៅ គឺថាត្រូវតែធ្វើសំណើតាមវិធាន៨៧(៤) ដើម្បីប្រើប្រាស់នៅក្នុងសវនាការនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំសូមបញ្ជាក់ ការអនុវត្តគឺត្រូវបានកំណត់រួចមកហើយ។ ហើយភាគីទាំងអស់ក៏ត្រូវតែគោរពទៅតាមវិធានទាំងអស់នេះ របស់យើង គឺថាយើងគោរពដូចគ្នាទាំងមេធាវីការពារក្តី ទាំងសហព្រះរាជ-អាជ្ញា ទាំងមេធាវីដើមបណ្តឹង។ ដូច្នេះខ្ញុំគិតថា យើងគួរតែគោរពទៅតាមវិធាន ដែលអង្គជំនុំជម្រះ បានកំណត់តាំងពីដំបូងរួចមកហើយ។

[១៣:៣៩:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៦:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្តល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយបញ្ជាក់បញ្ហាដែលលើកឡើងដោយមេធាវី អាកទូរ វែកគែន អម្បាញ់មិញនេះ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះបានដឹងអំពីឯកសារដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក តក់ ប៊ុយ ដែលត្រូវបានផ្ដល់ជូនភាគីរួចមកហើយ។ អង្គជំនុំជម្រះក៏សូមជម្រាបផងដែរថា សហមេធាវីនាំមុខតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីមានបំណងចង់ប្រើប្រាស់ឯកសារនេះ នៅក្នុងក្របខ័ណ្ឌនៃការសួរសំណួរសាក្សីរូបនេះ។ ដោយសារតែអង្គជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានភាគីណាមួយជំទាស់ទៅនឹងការប្រើប្រាស់ឯកសារថ្មីនេះទេ ប្រសិនបើខ្ញុំច្រឡំសូមប្រាប់ខ្ញុំភ្លាម។ ខ្ញុំគិតថា មិនមានការជំទាស់ទេ។ ដូច្នេះអង្គជំនុំជ្រះចាត់ទុកថាឯកសារនេះអាចទទួលយកបាន ហើយដាក់ចូលទៅក្នុងសំណុំរឿង។ ដូច្នេះភាគីអាចប្រើប្រាស់ឯកសារទាំងអស់នេះបានក្នុងនាមជាភស្ដុតាងថ្មី មិនចាំបាច់មានការដាក់សំណើជាផ្លូវការ ដោយយោងតាមវិធាន៨៧(៤)នោះទេ។ ដូច្នេះការសម្រេចទទួលយកគឺនៅទីនេះតែម្ដង។ នៅពេលដែលភាគីចង់ប្រើប្រាស់ឯកសារថ្មី ហើយបើសិនជាមិនមានការជំទាស់ពីភាគីណាមួយនោះ គឺយើងអាចចាត់ទុកថាឯកសារហ្នឹងអាចទទួលយកបាន។ ខ្ញុំសូមបញ្ជាក់ផងដែរថា ការផ្ដល់ជូនពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនបែបនេះនោះ វាលើកឡើងនូវការលំបាកមួយចំនួន ហើយអង្គជំនុំជម្រះនឹងដោះស្រាយបញ្ហានេះ ហើយនិងជម្រាបជូនភាគីនៅពេលក្រោយ។

[១៣:៤៨:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ បាទសូមផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងរដ្ឋប្បវេណី។

**លោក វ៉ែន ពៅ៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ែន ពៅ៖**

**ស៖** ជម្រាបសួរលោកសាក្សីម្ដងទៀត។ ខ្ញុំនឹងបន្តសំណួរតទៅមុខទៀត។ នេះជាប្រធានបទមួយផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងរបបអាហារនៅទំនប់អាងត្រពាំងថ្ម។ សំណួររបស់ខ្ញុំចង់សួរលោកថា តើនៅពេលដែលលោកធ្វើការនៅអាងត្រពាំងថ្មនោះ តើគេមានចែករបបអាហារយ៉ាងណាដែរ?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ ការចែករបបអាហារនោះ គឺខ្ញុំមិនដឹងថាគេចែកយ៉ាងម៉េចទេ ក៏ប៉ុន្តែក្នុងការហូបចុកនោះ វាហូបបាន និយាយទៅថាវាគ្រប់គ្រាន់ណា។ វាមិនមែនជាបញ្ហាអីទេ ក៏ប៉ុន្តែដែលហូបនោះគឺហូប

ពុំស្កូវបាន ដោយសារតែយើងអត់ងងុយ។ បាទ សូមអរគុណ។

**ស៖** តើរបបអាហារដែលលោកថា ចែកឱ្យនោះជាហូបបបរ ឬក៏ហូបបាយ? ហើយហូបរួម ឬយ៉ាងម៉េច មានចុងភៅគេដាំជូន ឬយ៉ាងម៉េចបាទ?

[១៣:៥០:១៦]

**ឆ៖** បាទ គឺមានចុងភៅគេដាំរួម រួចបានបើកចែកឱ្យ។

**ស៖** តើលោកអាចបញ្ជាក់ឱ្យច្បាស់ថា តើហូបបាយ ឬហូបបបរខ្លះ បាយខ្លះ ឬយ៉ាងម៉េច នៅអំឡុងពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មនោះ?

**ឆ៖** បាទ នៅពេលនោះមិនបានហូបបបរទេ គឺហូបបាយ។ គឺគេបានឱ្យហូបគ្រប់គ្រាន់ក្នុងការពលកម្មលើកទំនប់។

**ស៖** សូមអរគុណ។ ចុះផ្នែកអនាម័យម្ហូបអាហារហ្នឹងវិញ តើលោកអាចបញ្ជាក់បានទេ ជាម្ហូបគេគ្របត្រឹមត្រូវ ឬក៏យ៉ាងម៉េចដែរ? ម្ហូបអាហារហ្នឹងមើលទៅមានអនាម័យ ឬក៏មានសត្វរុយសត្វអីច្រើនទេ ពាក់ព័ន្ធនឹងរបបអាហារម្ហូបអាហារកន្លែងហូបចុកអីហ្នឹងបាទ?

**ឆ៖** រឿងការអនាម័យនោះ គឺអត់មានការគ្របការអីទេ គឺនៅហាលវាលណ៎ា ពាសពេញដូច្នេះរុយរោម។ សូមអរគុណ។

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងរបបអាហារនេះដែរ តើលោកធ្លាប់បានឮ ឬមានកូនក្រុមលោករអ៊ូប្រាប់ថាគាត់ហូបមិនឆ្អែត ឬក៏មិនម្ហូបមិនឆ្ងាញ់អីនេះដែរទេ? គេមានសិទ្ធិរអ៊ូរទាំអីដែរទេបាទ?

**ឆ៖** បាទ ដូច្នេះនៅក្នុងកងរបស់ខ្ញុំបាទគឺមិនមានការរអ៊ូរទាំទេ ការហូប ក៏ប៉ុន្តែថាហូបពុំស្កូវបានដោយសារតែយើងអត់ងងុយនៅពេលយប់ ដែលលើកដីនេះឯង។ ដូច្នេះការហូបចុកវាគ្រប់គ្រាន់ហើយ ក៏ប៉ុន្តែហូបទៅវាហេរហត់អត់ងងុយ យើងហូបអត់បានដោយសារតែអត់ងងុយ។

[១៣:៥២:២៤]

**ស៖** បាទ សូមអរគុណ។ ពាក់ព័ន្ធនឹងអ្វីដែលលោកបានលើកថាមានហូបមិនស្កូវបាន អត់ងងុយ តើលោកមានសង្កេតឃើញនៅក្នុងក្រុមរបស់លោកហ្នឹងមានអ្នកមានធ្លាក់ខ្លួនឈឺដោយសារបាក់កម្លាំង ឬក៏រូបរាងកាយស្គមស្គាំងស្លេក យ៉ាងម៉េចដែរ លោកមានសង្កេតឃើញមានធ្លាក់ខ្លួនឈឺ ឬក៏ដោយសារការបាក់កម្លាំងហត់នឿយទេ?

**ឆ៖** ដោយសារសង្កេតរបស់ខ្ញុំបាទនៅក្នុងកងរបស់ខ្ញុំបាទ គឺមានតែការរាករូសប៉ុណ្ណោះ

ដោយសារថាវាហូបទឹកច្រើនទៅក្តៅទៅបណ្តាលឲ្យរាករូស។ ដូច្នេះការស្គមការស្គីនោះ បានបញ្ជូនទៅៗតាមកន្លែងពេទ្យ។ មិនដឹងថានេះទេ មិនដឹងគេយកទៅណាទេ គឺថាពេលឈឺទៅ បញ្ជូនទៅលើៗ មិនដឹងបញ្ជូនទៅកន្លែងពេទ្យណាទេ។

**ស៖** សូមអរគុណ។ លោកអាចបញ្ជាក់ថែមទៀតបានទេថា នៅពេលដែលមានកងចល័តឈឺ លោកថាឈឺមានរាករូសនោះ ថាតើមានពេទ្យប្រចាំការ ឬក៏គេមានចែកជាថ្នាំពេទ្យ ថ្នាំអីឲ្យដែរទេ?

**ឆ៖** បាទ នៅក្នុងកងនោះមានពេទ្យប្រចាំការ ក៏ប៉ុន្តែថ្នាំមានថ្នាំអីទេ ថ្នាំបុរាណ គឺគេផ្សំដោយស្លឹកឈើ ឫសឈើបុកផ្សំទៅ ស្ងួនទៅជាដុំ។ ដូច្នេះបើកឲ្យ បើថារាករូសគេឲ្យ បើថាគ្រុនក្តៅគេឲ្យ។ មិនមានថ្នាំយើងឱសថពី និយាយទៅថា ជាថ្នាំរបស់បុរាណ គេស្ងោររម្ងាស់ស្លឹកឈើស្លឹកអីទៅ មិនដឹងធ្វើយ៉ាងម៉េចទេ ទៅជាថ្នាំពណ៌ខ្មៅៗ និយាយរួមថាដូចអាចម៍ទន្សាយអ៊ីចឹង គេឲ្យមកបាទ។

[១៣:៥៤:២២]

**ស៖** សូមអរគុណ។ ខ្ញុំចង់បញ្ជាក់លោកថែមទៀត ពាក់ព័ន្ធនឹងពេទ្យ លោកថាពេទ្យ គ្រូពេទ្យហ្នឹង ថាតើលោកអាចបញ្ជាក់បានទេថា ពេទ្យនោះគាត់ជាពេទ្យជំនាញ ឬក៏គ្រាន់តែមានវិជ្ជាជីវៈពេទ្យអីដែរ តាមការសង្កេតរបស់លោក?

**ឆ៖** បាទ ការដែលពេទ្យនៅតាមកងនោះ មិនមែនបានទៅរៀនឯណាឯណី គ្រាន់តែរើសថាជាពេទ្យៗប៉ុណ្ណោះឯង ឲ្យគ្រាន់តែមើលអ្នកជំងឺ ការរាករូសទៅក៏ទៅបើកថ្នាំ មិនដឹងបើកឯណា បើកឯលើៗ មិនដឹងជាបើកនៅកន្លែងណាទេ។ ខ្ញុំក៏មិនដឹងដែរ ព្រោះជាផ្សេងគ្នា។ គេទៅបើកទៅបានមកដូចជាថាថ្នាំអាចម៍ទន្សាយ យកមកឲ្យលេបព្យាបាលអ្នកដែលរាករូស។ បាទអរគុណ។

**ស៖** ពាក់ព័ន្ធនឹងជំងឺនេះដែរ ខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើនៅទីនោះ លោកមានដែលជួបប្រទះ ឬឃើញមានអ្នកជំងឺស្លាប់ទេ ដោយៗការបាក់កម្លាំង ឬក៏ដោយជំងឺនោះបាទ?

**ឆ៖** បាទ អាការដែលឈឺថ្កាត់គ្រុនរងារ គឺបញ្ជូនទៅឯលើ លើគេបញ្ជូនទៅកន្លែងណាកន្លែងណីនោះ ខ្ញុំមិនដឹងទេ មិនដឹងជាបាត់ ឬមិនដឹងជាស្លាប់អី។ ជួនកាលគេជាទៅ គេខ្លាចទៅ គេរត់ទៅតាមសហករណ៍គេក៏មិនដឹង ស្អីក៏មិនដឹង។ តែបញ្ជូនទៅដឹងតែបាត់ខ្លួន មិនដឹងថាបាត់ដោយសារស្លាប់ ឬក៏បាត់ដោយសារគេរត់គេចទៅតាមសហករណ៍ក៏មិនដឹង។ បាទអរគុណ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោកពាក់ព័ន្ធនឹងគ្រោះថ្នាក់ការងារនៅទីនោះដែរ។ តើតាមការសង្កេតរបស់លោក លោកមានបានឃើញ ឬមានគេនិយាយប្រាប់លោកថានៅទីនោះមានកងចល័ត

ត្រូវបានគ្រោះថ្នាក់ដោយសារការធ្វើការដូចជាបាក់ដី ឬក៏ពាក់ព័ន្ធនឹងគ្រោះថ្នាក់ការងារ តើលោកមានបានឮ ឬក៏បានឃើញទេបាទ?

[១៣:៥៦:២៧]

**ឆ៖** បាទ អត់ទេ ខ្ញុំអត់ដែលឃើញទេ។

**ស៖** សូមអរគុណ។ ខ្ញុំចង់បញ្ជាក់លោកផងដែរថា ការងារនៅការដ្ឋានទំនប់អាងត្រពាំងថ្មនោះ តើលោកសង្កេតឃើញថា មានប្រើជាគ្រឿងចក្រអីដែរទេ ឬក៏ប្រើកម្លាំងមនុស្សសុទ្ធសាធបាទ?

**ឆ៖** បាទ ក្នុងៗនោះគឺអាងទឹកត្រពាំងថ្មនោះមិនបានប្រើប្រាស់ដោយគ្រឿងចក្រទេ គឺប្រើដោយកម្លាំងសុទ្ធសាធណ៎ា គឺកម្លាំងយើងផ្ទាល់ជីក រែកដោយខ្លួនឯងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំចូលប្រធានបទថ្មីមួយទៀតពាក់ព័ន្ធនឹងការចាប់ខ្លួនមនុស្ស ឬការបាត់ខ្លួនមនុស្ស។ ខ្ញុំចង់សួរលោកថាតើនៅក្នុងកងរបស់លោកនោះ ឬក៏លោកធ្លាប់បានឮ ឬមានគេអ្នកណាប្រាប់លោកថាមានគេចាប់មនុស្ស ឬក៏បាត់ខ្លួនមនុស្សទេនៅក្នុងកង ឬក៏នៅកងចល័តដែលធ្វើការនៅអាងត្រពាំងថ្មនោះ?

**ឆ៖** បាទ ក្នុងការឮៗដោយសារប្រធានវរៈ គេប្រាប់ថាគេចាប់គេចាប់មេធំទៅហើយ គេចាប់តាវ៉ាល់។ ដូច្នេះគឺខ្ញុំមិនបានឃើញនឹងផ្ទាល់ ឬក៏គ្រាន់តែឮដោយមេពីលើប្រាប់ថាគេចាប់ តាវ៉ាល់ ហើយដូច្នេះយើងប្រុងប្រយ័ត្ន។ បាទអរគុណ។

[១៣:៥៨:០៤]

**ស៖** សំណួរខ្ញុំមិនៗចង់ដឹងថាគេចាប់ថ្នាក់ដឹកនាំទេ ខ្ញុំចង់ដឹងកងចល័តដូចគ្នា កូនកង ក៏ដូចជាអ្នកធ្វើការនៅទីនោះ ថាតើមានបាត់ខ្លួន ឬគេចាប់ទេ នៅពេលណា ឬក៏?

**ឆ៖** បាទ អត់ទេ នៅខាងកងរបស់ខ្ញុំអត់មានអ្នកណាចាប់បាត់ខ្លួនទេ។

**ស៖** ចុះលោកមានបានដឹង ឬមានអ្នកណាប្រាប់លោក ឬក៏លោកបានឃើញថាអ្នកដែលពាក់ព័ន្ធជាមួយវៀតណាម ឬក៏ជនជាតិវៀតណាមធ្វើការនៅទីនោះ ត្រូវគេចាប់ខ្លួន ឬក៏គេនាំខ្លួនទៅបាត់ដែរទេនៅទីនោះ?

**ឆ៖** កាលនោះ គឺខ្ញុំនៅមិនទាន់បានចូលជាកងចល័តតំបន់ទេ គឺនៅតាមភូមិគឺឲ្យតែមានហៅថាជនជាតិចិន ជនជាតិវៀតណាម ដូច្នេះកងឈ្លបឃោធាគេប្រមូលទាំងស្រី ទាំងប្រុសគេចាប់យកទៅអស់អានោះខ្ញុំបានឃើញបានដឹងដែរណ៎ា។

**ស៖** បាទ សូមអរគុណ។ មុននេះបន្តិចលោកបានបញ្ជាក់ហើយថា តាវ៉ាល់ ត្រូវគេចាប់។ លោកអាចបញ្ជាក់បានទេ តើ តាវ៉ាល់ ហ្នឹងគាត់មានតួនាទីជាអី? ហើយគាត់នៅក្នុងអ្នកគ្រប់គ្រងឋានៈប៉ុនណាដែរបាទ?

**ឆ៖** បាទ តាវ៉ាល់ នោះគឺក្នុងឋានៈរបស់គាត់ គឺប្រធានចល័តតំបន់ណ៎ា ហើយប៉ុន្តែក្នុងរចនារបស់គេនោះមិនដឹងថា ក្នុងភូមិភាគ ឬក៏តំបន់នោះយ៉ាងម៉េចទេ ប៉ុន្តែគេគ្រប់គ្រងចល័តតំបន់ផ្ទាល់។

**ស៖** លោកថាគេចាប់គាត់។ លោកដឹងទេតើខាងណាចាប់គាត់?

**ឆ៖** ខ្ញុំមិនបានដឹងទេ មិនដឹងថាខាងណាចាប់ទេ ប៉ុន្តែដោយប្រធានវរៈប្រាប់ថា គេចាប់ តាវ៉ាល់ បាត់ទៅហើយ។ ខ្ញុំដឹងតែប៉ុណ្ណោះឯង មិនដឹងថា ពួកណាគេចាប់ផង។

[១៤:០០:៣២]

**ស៖** សូមអរគុណ។ ពាក់ព័ន្ធនឹងទីតាំងសាកសព ខ្ញុំចង់សួរថា តើលោកបានដឹង ឬមានអ្នកណាប្រាប់លោកថា នៅជុំវិញទំនប់អាងត្រពាំងថ្មហ្នឹង មានកន្លែងសាកសព មានអីទេបាទ?

**ឆ៖** បាទ ខ្ញុំសួរទៅវិញថា កន្លែងសាកសពនោះ សាកសពអ្នកណា? បញ្ជាក់ខ្ញុំឲ្យបានច្បាស់បន្តិចបាទ។

**ស៖** អាច គឺខ្ញុំចង់សំដៅថា អាចសាកសពផងកងចល័ត ឬក៏អ្នកដែលធ្វើការនៅជិត ឬក៏ត្រូវគេនាំយកទៅដែលលោកតែងថា មានគេនាំទៅបាត់ៗនោះ លោកអាចដឹងថាមានកន្លែងសាកសពនៅជិតៗនោះទេ?

**ឆ៖** បាទ អារឿងសាកសពកងចល័តនោះមាន ដូច្នេះនៅនឹងខ្នងទំនប់អាងក៏មានសាកសព នៅខាងក្រោមអាងក៏មាន នៅក្នុងអាង លើអាងនោះក៏មានសាកសពដែរ គេកាប់សម្លាប់ណ៎ា ដោយជីកនឹងចបទៅគេកប់ចោលនៅពេលយប់ដែលយើងអត់ដឹងថា គេមានទោសកំហុសអីទេ ស្រាប់តែបាត់ខ្លួន គេយកសម្លាប់ចោល។ ដល់តែពេលយើងរែកដីនៅលើទំនប់ទៅឃើញល្អិនល្អកៗ គឺសន្និដ្ឋានការគេវៃចោលយប់មិញហើយ។

**ស៖** លោកអាចបញ្ជាក់បាន មានច្រើនទេសាកសពដែលក្រុមលោកបានរែកដីទៅប្រទះឃើញនៅទីនោះ តើច្រើន ឬក៏?

[១៤:០២:០១]

**ឆ៖** បាទ បើនិយាយទៅថា រាប់មិនអស់ទេ ច្រើនទាំងខាងក្រោមអាង កណ្តាលវាល ហើយនិង

ក្នុងអាងក៏មាន។ ដូច្នេះ ទឹកឡើងទៅយើងមើលផ្ទះអត់ឃើញ បើនៅខាងក្រោមអាងអានោះមានដើរទៅមានផ្ទះ ធ្វើស្រែធ្វើអី បងប្អូនដែលក្រោយពីនេះមក ចូលទៅមានប៉ះក្បាលប៉ះអី មានច្រើន។ ដូច្នេះសន្និដ្ឋានថា ប៉ុន្មាននាក់ខ្ញុំអត់ដឹងទេអាហ្នឹង។

**ស៖** សូមអរគុណ។ សំណួរខ្ញុំជាបន្តទៀតពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ។ ខ្ញុំចង់សួរលោកថា តើលោកបានដឹង ឬធ្លាប់ចូលរួមដោយផ្ទាល់ ឬក៏បានដឹងទេ ចំពោះការរៀបការនៅសម័យនោះ?

**ឆ៖** បាទ ការរៀបការនោះ គឺនិយាយទៅ គឺមិនជាបង្ខំទេ គឺថាសាមីខ្លួនទាំងពីរគេត្រូវរ៉ូវគ្នាគឺគេចាប់ដៃគ្នារៀបការបណ្ដោយ។ ប៉ុន្តែកន្លែងណាណី អានោះខ្ញុំអត់ដឹងទេ ដឹងតែកន្លែងខ្ញុំហ្នឹងឯង។ បាទអរគុណ។

**ស៖** លោកចង់បញ្ជាក់ថា "មិនបង្ខំ" បានន័យថា យើងមានសិទ្ធិរើសខ្លួនឯង ឬក៏មេកង មេក្រុមអ្នកជ្រើសរើសឲ្យលោក ឲ្យអ្នកដែលត្រូវរៀបការនោះ?

**ឆ៖** បាទគឺគេជ្រើសរើសខ្លួនឯង ហើយស្រឡាញ់នារីណា ឧទាហរណ៍នារី "ក" អ៊ីចេះទៅ ស្នើដល់មេក្រុម មេកងឲ្យទៅទាក់ទង។ គេទៅនិយាយកងនារី ឲ្យទៅត្រូវរ៉ូវគ្នា គឺគេរកថ្ងៃរៀបអាពាហ៍-ពិពាហ៍ឲ្យ គេថា ចាប់ដៃរៀបការ។ ប៉ុន្តែមិនមែនតែមួយគូទេ ៥០, ៦០គូ បាទ។

[១៤:០៣:៥២]

**ស៖** សូមអរគុណ។ លោកបញ្ជាក់ថា រៀបការម្តង៥០, ៦០គូ តើលោកធ្លាប់បានចូលរួមផ្ទាល់ទេ ទៅមើលគេរៀបការ ឬក៏លោកឮតាមគេ?

**ឆ៖** បាទ ខ្ញុំបាទបានទៅផ្ទាល់ ព្រោះគេហៅទៅចូលរួមក្នុងកម្មវិធីចាប់ដៃរៀបការ។

**ស៖** តើក្នុងពិធីរៀបការនោះ លោកឃើញមានឪពុកម្ដាយទាំងសងខាងចូលរួមទេ ឬហៅតែកងចល័តជាមួយគ្នា?

**ឆ៖** បាទ អត់មានទេ មានតែគូភាគីទាំងពីរដែលយុវជននារីហ្នឹងហើយ។ អត់មានឪពុកម្ដាយទៅបៀតបតទេ បាទ។

**ស៖** សូមអរគុណ។ ពាក់ព័ន្ធនឹងជំនឿសាសនាវិញ តើខ្ញុំចង់សួរលោក ថាតើនៅសម័យនោះនៅពេលមានមនុស្សស្លាប់មានអី ថាតើគេអនុញ្ញាតឲ្យមានពិធីបុណ្យសព បុណ្យអី តាមប្រពៃណីដែរទេ?

**ឆ៖** បាទ បើនិយាយខាងព្រះពុទ្ធសាសនាវិញ ជំនឿវិញ អត់មានទេ ការស្លាប់គឺស្លាប់ អត់មានថារកអាចារ្យ ឬក៏លោកស្ទឹងឯណាទៅសូត្រមន្ត ឬអីទេ ស្លាប់មានតែសែងយកទៅកប់ចោលហ្នឹងឯង។

**ស៖** ហើយពាក់ព័ន្ធនឹងវត្តអារាមនៅជុំវិញនោះវិញ តើលោកបានដឹងថាវត្តអារាមទាំងនោះមានព្រះសង្ឃគង់នៅ ឬក៏ត្រូវបានគេយកធ្វើជាស្អីដែរ លោកអាចដឹងទេបាទ?

**ឆ៖** បាទ ទីវត្តអារាមអត់មានលោកសង្ឃ អត់មានអីទេណ៎ា គឺក្លាយទៅជាកន្លែងឱសថបូរាណផលិតនូវថ្នាំឱសថបូរាណសម្រាប់ព្យាបាល។

**ស៖** សូមអរគុណ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់សួរលោកថា នៅពេលលោកធ្វើការនៅអាងត្រពាំងថ្មនោះ តើលោកធ្លាប់បានទទួលគណៈប្រតិភូ ឬក៏ថ្នាក់ដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យទៅទស្សនកិច្ចនៅទីនោះទេ?

[១៤:០៦:០៧]

**ឆ៖** បាទ ខ្ញុំបាទបានទទួលគណៈប្រតិភូចិន គឺឈ្មោះលោក យ៉ឹងគុយ ដែលទៅទស្សនានៅអាងត្រពាំងថ្ម។

**ស៖** តើមានថ្នាក់ដឹកនាំតំបន់ ឬក៏ភូមិភាគ ឬក៏ពីមជ្ឈិមខាងភ្នំពេញនេះទៅទេលោក ឬក៏មាននរណាប្រាប់លោកថាមានថ្នាក់ដឹកនាំណាទៅទេ ក្រៅពីគណៈប្រតិភូចិននោះ?

**ឆ៖** អានោះខ្ញុំមិនដឹងដែរ ព្រោះខ្ញុំនៅការតូចតាច មិនបានដឹងជ្រៅជ្រះទេ ប៉ុន្តែឡានគេមកប្រហែលជាឡានខ្ពង់២០ឡាន។ ហើយអ្នកដែលនៅនឹងឡាននោះ មកសុទ្ធតែអាវស ខោខ្មៅសំឡុសហើយគ្រាន់តែគេប្រាប់ថា គណៈប្រតិភូនោះគឺចិនហៅ អឹង យ៉ឹងគុយ។ ដល់យប់ឡើងបានគេបញ្ចាំងកុនឲ្យមើល រឿងការធ្វើនៅក្នុងប្រទេសចិន។

**លោក វ៉ែន ពៅ៖**

សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ ប៉ុន្តែសហមេធាវីនាំមុខជាតិគាត់មានសំណួរពីរបីសំណួរចង់បន្ត។ បាទសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[១៤:០៧:១៦]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំមានសំណួរតិចតួចទេចំពោះលោកសាក្សីរូបនេះបាទ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមគោរពលោកសាក្សី។ ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សំណួរទី១ របស់ខ្ញុំពាក់ព័ន្ធទៅនឹងរឿងបញ្ហាម៉ោងធ្វើការ។ លោកបានឆ្លើយទៅនឹងលោកមេធាវី វ៉ែន ពៅ ថាម៉ោងធ្វើការ គឺចាប់ផ្តើមពីម៉ោងប្រាំពីរព្រឹករហូតទៅដល់ម៉ោងដប់មួយ ហើយនិងពេលល្ងាចក៏លោកបានបញ្ជាក់ដែរ។ ក៏ប៉ុន្តែចង់សួរបញ្ជាក់លោកបន្ថែម ថាតើនៅជាក់ស្តែង តើកងចល័តរបស់លោក និងកងចល័តគេផ្សេងៗទៀតដែលនៅជិតលោក ដែលលោកបានឃើញ គេចាប់ផ្តើមធ្វើការពីម៉ោងប្រាំពីរព្រឹកអ៊ីចឹងគ្រប់ពេល ឬក៏យ៉ាងដូចម្តេចដែរ?

**លោក តក់ ប៉ិុយ៖**

**ឆ៖** បាទ ដូច្នេះគឺការដែលធ្វើការពលកម្មជីកអាងលើកទំនប់នោះ គឺម៉ោងប្រាំពីរព្រឹកទៅដល់ម៉ោងដប់មួយ។ អានេះចំពោះតែអ្នកដែលខ្វាក់មាន់ទេណ៎ា ដូចខ្ញុំពីព្រឹកមិញ ខ្ញុំបានផ្តល់ព័ត៌មានទៅវាច្រឡំបន្តិច។ គឺល្ងាចម៉ោងមួយ ទៅដល់ម៉ោងប្រាំ ដូច្នេះចំពោះកងដែលខ្វាក់មាន់ តែកងមិនបានខ្វាក់មាន់ អានោះគឺធ្វើនៅពេលយប់។

[១៤:០៨:៥៣]

**ស៖** តើអាចមានកងណា ឬក្រុមរបស់លោកធ្លាប់ចាប់ផ្តើមធ្វើការ ឬក៏ក្រោកទៅធ្វើការមុនម៉ោងប្រាំពីរព្រឹកដែរឬទេ?

**ឆ៖** បាទ អត់ទេ គឺគោរពម៉ោងទៀងទាត់ណាស់ ដល់ម៉ោងបានទៅធ្វើការ មិនបានទៅក្រោយម៉ោងទេ។

**ស៖** តើលោកនិយាយសំដៅទៅលើកងរបស់លោក ឬក៏លោកនិយាយសំដៅទៅលើកងរបស់គេដែលនៅជិតលោកដែរ ដែលលោកបានឃើញដែរ?

**ឆ៖** បាទ អានេះជាកងរបស់ខ្ញុំទេ បើកងរបស់គេមិនដឹងយ៉ាងម៉េចទេ វានៅផ្សេងៗពីគ្នា ឃើញតែធ្វើការដូចតែគ្នាអ៊ីចឹង។

**ស៖** សូមសួរបញ្ជាក់ពាក់ព័ន្ធនឹងបញ្ហាផ្សេងទៀត។ អម្បាញ់មិញលោកបានឆ្លើយអំពីមនុស្សដែលលោកឃើញគេកប់នៅនឹងទំនប់ ក្រៅទំនប់ ហើយនិងបាតទំនប់។ តើការឃើញនោះគឺលោកឃើញដោយផ្នែកខ្លួនលោកផ្ទាល់ ឬយ៉ាងណា? ហើយឃើញហ្នឹង ឃើញនៅ -- លោកអាចបញ្ជាក់បានទេ មានចំនួនតិច ឬក៏ច្រើន?

[១៤:១០:២១]

**ឆ៖** បាទ មិនបានឃើញនឹងភ្នែកទេ គ្រាន់តែយើងបង្គីទៅលើស្នារែកទៅ គឺនៅលើបាតទំនប់ យើងជាន់ទៅឃើញល្អកៗ ដូច្នេះយើងសន្និដ្ឋានថា គេវៃចោលនៅយប់មិញ។ ហើយដល់ពេលក្នុងអាង ឬខាងក្រោមអាងនោះ ពេលដែលយើងសម្រាកបត់ដៃបត់ជើងធំតូច យើងដើរទៅឃើញមានអន្លង់មាន អី។ ដូច្នេះការសន្និដ្ឋាននោះមិនដឹងថាប៉ុន្មានទេ វាច្រើន។

**ស៖** នៅពេលដែលលោកមានប្រសាសន៍ថា ឃើញល្អកៗហ្នឹង លោកចង់មានន័យថា យ៉ាង ដូចម្ដេច ពាក្យហ្នឹង?

**ឆ៖** បាទ ព្រោះនែ៎ យើងរែកទៅចាក់ទៅបើសិនកុំមាន ដីវារឹង តែដល់ពេលនោះ ជាន់ទៅល្អក វាអន្ទិលៗ វាអត់មានទឹក ហើយអត់មានអីទេ។ ដូច្នេះយើងសន្និដ្ឋានថា គេវៃចោលនៅកន្លែងនេះឯង។ ដូច្នេះគ្រាន់តែកកាយ និយាយទៅវាមិនជ្រៅទេ គ្រាន់តែកាយលុបតែខ្លួននោះឯង យើងចាក់ទៅ មានអី ល្អក។

**ស៖** តើដីដែលមានលក្ខណៈល្អកៗ ទន់ៗហ្នឹង វាអាចមកពីជារដូវវស្សា ហើយនាំឲ្យដីមាន លក្ខណៈទន់បែបនេះ ឬក៏យ៉ាងម៉េច? ឬក៏ថាដោយសារវាជារដូវ ដីហ្នឹងជាទូទៅរដូវប្រាំង ហើយដីរឹង ដោយឡែកកន្លែងដែលលោកសង្ស័យហ្នឹង វាមានលក្ខណៈទន់?

[១៤:១២:០០]

**ឆ៖** បាទ ក្នុងលក្ខណៈដែលថា ទន់ល្អកនោះ មិនមែនជារដូវវស្សាទេ គឺរដូវប្រាំង។ ហើយដី កាប់ទៅគឺព្រាយ រឹងកំព្រឹស រឹងអី គឺថាទន់។ ដូច្នេះគឺចាក់ទៅរឹង សង្កត់ទៅវាប្រេះ ដូច្នេះយើងជាន់ទៅពី លើខ្មោច វាមានការទន់ល្អៀចល្អក។

**ស៖** លោកបាននិយាយអំពីរណ្ដៅអម្បាញ់មិញ លោកអាចនិយាយបានទេ រណ្ដៅហ្នឹងយ៉ាង ម៉េច? រណ្ដៅហ្នឹង តូចឬក៏ធំ? រាក់ឬក៏ជ្រៅ ដែលលោកបានមានប្រសាសន៍អម្បាញ់មិញហ្នឹង?

**ឆ៖** បាទ រណ្ដៅហ្នឹងមិនមែនរណ្ដៅធំទេ រណ្ដៅថា និយាយទៅថាខ្លួនមួយ។ ដូច្នេះការដែល កប់មិនបានជាកប់ជ្រៅទេ ដល់តែពេលខ្មោចឡើងហើមទៅ ដៃហ្នឹងវាឡើងប្រេះ ប្រេះទៅវាចំហាយ មក។ ដូច្នេះហើយគឺបានន័យថា គេកប់ខ្មោច។

**ស៖** តើលោកឃើញស្ថានភាពបែបហ្នឹងនៅទីនោះ ញឹកញាប់ដែរឬទេ? ចង់និយាយថា ដីដែល ល្អកៗ ហើយលោកគិតថាជាកន្លែងកប់ខ្មោចហ្នឹង ជារណ្ដៅខ្មោចហ្នឹង លោកមានឃើញស្ថានភាពបែប

ហ្នឹងញឹកញាប់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំឃើញតែម្តងប៉ុណ្ណោះឯង ដែលលើក រែកទៅចាក់ទៅស្រាប់ល្អៀចល្អកនោះឯង ខ្ញុំឃើញតែម្តង។ ក្រៅពីនោះឃើញតែនៅតាមវាល តាមអី អានោះឃើញតាមរណ្តៅ ពេលដែលវាហើមប្រេះ អានោះឃើញ។

**សៈ** មុននឹងលោកមានប្រសាសន៍ថា មានក្លិនចេញពីដីដែលប្រេះ ដែលល្អកៗហ្នឹង។ តើក្លិនហ្នឹងជាក្លិនអ្វី?

[១៤:១៤:១៣]

**ឆ៖** បាទ មិនមានធុំក្លិននៅកន្លែងដែលថា ល្អកទេ គឺធុំក្លិននៅកណ្តាលវាលដែលកប់ទៅមិនបានជ្រៅ ហើយដីហើមប្រេះមក អានោះបានធុំក្លិន។ បើនៅកន្លែងបាតទំនប់នោះ គឺអត់មានក្លិនទេ គឺរែកចាក់ៗទៅ អត់មានថា ធុំក្លិនមកបានទេ។ អាហ្នឹងខ្ញុំបញ្ជាក់ គ្រាន់តែធុំក្លិននៅតាមវាល ដែលយើងទៅបត់ជើងធំទៅ វាឃើញ ទៅវាស្អុយតែម្តង។

**សៈ** បាទ ដោយសារលោកនិយាយអំពីវាលហ្នឹង ខ្ញុំចង់សួរបញ្ជាក់អំពីវាលហ្នឹង ថាតើលោកមានឃើញកន្លែងដែលគេកប់ច្រើនទេ នៅតាមវាលហ្នឹង នៅពេលដែលលោកចេញពីម្តុំទំនប់ទៅខាងវាលហ្នឹងមានបានឃើញច្រើនទេ?

**ឆ៖** បាទ នៅខាងក្រោមអាង គឺច្រើនណាស់ គេកប់ច្រើនរហូតដល់ធុំក្លិនណ៎។ ទាល់តែយើងទៅជិត បានធុំក្លិន បើយើងចម្ងាយប្រហែលជាពីរបីរយម៉ែត្រ ពីជើងទំនប់ ពីកន្លែងរោងដែលពួកខ្ញុំទៅទៅត្បូងនោះ ទាល់តែយើងទៅបត់ជើងនៅឆ្ងាយទៅ អានោះបានឃើញ ឃើញអន្តង់ មកប្រាប់គ្នាទៅអ៊ំ្ហា ទៅបត់ជើងណោះ ឃើញដីប្រេះណ៎ា គេកប់ខ្មោច។ នោះម្នាក់ៗភ្ញាក់ខ្លួនតែម្តង ក្នុងកងនុ៎ង។

**សៈ** បាទ សូមអរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ លោកបានបញ្ជាក់ថាវាល តើវាលដែលលោកមានប្រសាសន៍ ដែលលោកបានឃើញសាកសព ឬក៏សង្ស័យថា ជាសាកសពហ្នឹង ដែលគេកប់ហ្នឹង វាលហ្នឹងនៅក្នុងបរិវេណនៃអាង ឬក៏នៅខាងក្រៅបរិវេណនៃអាង?

**ឆ៖** បាទ នៅក្រៅបរិវេណអាងក៏មាន នៅក្នុងអាងក៏មាន។ បើនិយាយទៅថា ខាងត្បូងអាង ក៏មានដែរណ៎ា វាទាក់ទងនឹងបរិវេណក្នុងអាងជុំវិញហ្នឹងឯង។ វាគ្រាន់តែខុសគ្នាប្លែកថា មួយនៅក្នុងអាង មួយនៅខាងក្រោមអាង បរិវេណ។

[១៤:១៦:១៣]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ដើម្បីទុកពេលវេលាជូនតំណាងសហព្រះរាជអាជ្ញា ខ្ញុំសូមអស់សំណួរត្រឹមប៉ុណ្ណេះ។ សូមអរគុណលោកប្រធាន និងលោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាតទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីនេះ។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី លោកអាចធ្វើការប៉ាន់ប្រមាណរយៈពេល ដែលលោកបានធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មទេ? បើលោកអាចនឹកឃើញ គឺថាគិតមើល លោកចាប់ផ្ដើមធ្វើនៅខែណា ឆ្នាំណា ហើយបញ្ចប់នៅខែណា ឆ្នាំណា?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ ខ្ញុំមិនចាំបានទេ វាយូរណាស់ទៅហើយ។

**ស៖** លោកនិយាយអំពីថា លោកធ្លាប់ធ្វើការនៅកងចល័តមុនចូលទៅធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម តើកងចល័តដែលលោកនៅជាមួយ មុនទៅធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង ជាកងចល័តដែលចំណុះឱ្យស្រុក ឬក៏តំបន់ ឬក៏យ៉ាងណា?

**ឆ៖** បាទ មុននឹងខ្ញុំចូលទៅកងចល័តតំបន់ គឺខ្ញុំនៅក្នុងសហករណ៍ ក្នុងភូមិ នៅក្នុងសហករណ៍ គឺចំណុះឱ្យសង្កាត់ ស្រុកនោះ។

[១៤:១៨:២៥]

**ស៖** លោកបាននិយាយកាលពីមុននេះថា ការដែលគេបញ្ជូនលោកឱ្យធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម គឺគេទៅដោយស្ម័គ្រចិត្តទេ។ ឥឡូវនេះ ថាតើគេជ្រើសរើសលោកឱ្យទៅធ្វើជាមេកងដោយរបៀបណា? ហើយលោកទៅធ្វើការដោយស្ម័គ្រចិត្តហ្នឹង ដោយរបៀបណា?

**ឆ៖** មិនមែនស្ម័គ្រចិត្តទេ គឺគេជ្រើសរើស ឱ្យតែនារី ឱ្យតែយុវជននៅក្នុងភូមិ គេអត់ឱ្យនៅៗ

នៅជុំឪពុកម្ដាយទេ គេបំបែកចេញអំពីពុកម្ដាយ ឲ្យទៅចូលជាកងចល័ត។ បាទ អរគុណ។

**ស៖** ខ្ញុំចង់អានចម្លើយរបស់លោកឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងសូមឲ្យលោកពន្យល់បន្ថែមទៅលើចម្លើយរបស់លោកនោះ គឺឯកសារ D366, E3/7968, *អ៊ីងគ្លីស* ERN 00726228, ខ្មែរ 0057745 ដល់ 50, បារាំង 00743261 គឺថាលោកថា ៖"តើលោកទៅធ្វើការហ្នឹងទៅដោយសារស្ម័គ្រចិត្តឬ? លោកឆ្លើយថា៖ គេជ្រើសរើសខ្ញុំ គេជ្រើសរើសយើងឲ្យយើងទៅធ្វើការទីនោះ។ ហើយក្រោយមកបានគេចាត់តាំងថាអ្នកណាត្រូវទៅ។ គេបញ្ជូនយើងទៅតាមគោលដៅរបស់គេ ហើយយើងត្រូវតែធ្វើតាមបញ្ជារបស់គេ ទោះបីយើងត្រូវទៅហ្នឹងរស់ឬក៏ស្លាប់ក៏ដោយ ត្រូវតែធ្វើតាមគេ។ នៅពេលទៅដល់ការដ្ឋានការងារនោះ គឺថាគេឲ្យយើងមានចប បង្គី។" សំណួររបស់ខ្ញុំសួរហេតុអ្វីបានជាលោកមានការឆ្ងល់នេះ នៅពេលដែលគេជ្រើសរើស ហើយបញ្ជូនទៅឲ្យធ្វើការដ្ឋាននៅទំនប់ត្រពាំងថ្មហ្នឹង ថាម៉េចបានលោកលើកពាក្យថា គេឲ្យទៅហ្នឹងមិនដឹងថារស់ឬក៏ស្លាប់នោះ?

[១៤:២១:០១]

**ឆ៖** បាទ ដែលគេជ្រើសរើស ហើយបញ្ជូនពួកខ្ញុំនៅនោះ ទៅដល់គេគឺគេរៀបចំ។ រៀបចំមានកងមានក្រុម ដែលខ្ញុំបានទៅជាកងតូច ហើយគេបើកបង្គី ចបឲ្យធ្វើ ណេះបានខ្ញុំចុះជីកលើកទំនប់បណ្ដោយ។

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំទើបអានឲ្យលោកស្ដាប់នេះ ហាក់បីដូចជាថា លោកបញ្ជាក់ថាលោកមាន ហាក់បីដូចជាលោកបញ្ជាក់ថា លោកមានអារម្មណ៍ភ័យខ្លាចណាស់ នៅពេលដែលគេឲ្យលោកទៅធ្វើការនៅកងចល័ត ហើយបញ្ជូនទៅការដ្ឋានការងារ។ លោកចាំចំណុចដែលលោកថាមានការភ័យខ្លាចនេះទេ?

**ឆ៖** បាទ គឺខ្ញុំមានការភ័យខ្លាច ព្រោះខ្ញុំជាប់និន្នាការនយោបាយ ធ្វើទាហានផង ដល់តែពេលទៅ ខ្លាចលោវាគ្រោះថ្នាក់ដោយប្រការណាមួយ គេស៊ើបដឹងថាខ្ញុំជាទាហាន គេចាប់យកទៅសម្លាប់ចោល។ អាហ្នឹងខ្ញុំភ័យព្រួយបារម្ភត្រង់ណេះឯង។

**ស៖** នៅពេលដែលលោកឆ្លើយសំណួរទៅនឹងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី លោកនិយាយអំពីឈ្មោះ តាវ៉ាល់។ តើលោកសូមបញ្ជាក់បន្តិចមើល តើ តាវ៉ាល់ មានតួនាទីអ្វីដែរនៅការដ្ឋានលើកទំនប់នោះ?

[១៤:២២:៤៤]

**ឆ៖** បាទ តាវ៉ាល់ មានតួនាទីក្តាប់ួមួយអាងត្រពាំងថ្មទាំងអស់។ អរគុណ។

**ស៖** បាទ សូមអរគុណ។ លោកថាលោកគឺជាមេកងតូច។ ឥឡូវនេះខ្ញុំសួរអំពីរចនាសម្ព័ន្ធនៅកងរបស់លោក។ តើគេហៅថាជាកងអ្វីដែរ កងដែលធំបន្ទាប់ពីកងតូចនេះ?

**ឆ៖** បន្ទាប់ពីកងតូច គឺមានក្រុម។ ចុះពីក្រុមមកគឺសមាជិក។ អត់មាននេះទេ ចុះមកក្រោម។

**ស៖** នេះគឺកងដែលមានរចនាសម្ព័ន្ធទាបជាងកងតូច។ ឥឡូវខ្ញុំសួរអំពីរចនាសម្ព័ន្ធដែលខ្ពស់ជាងកងតូចនោះ។

**ឆ៖** គឺខ្ពស់ជាងកងតូចគឺកងធំ។ កងធំរួចបានវរៈ។ វរៈរួចបានប្រធានក្តាប់ក្នុងអាងតែម្តង គឺតាវ៉ាល់។

**ស៖** ដូច្នេះ -- ប៉ុន្តែលោកចាំឈ្មោះមេបញ្ជាការផ្ទាល់នៅពីខាងលើលោកទេ មេបញ្ជាការមួយថ្នាក់នៅពីខាងលើលោកហ្នឹង?

**ឆ៖** បាទ គឺនៅពីលើកងតូចនោះ គឺមានកងធំ។ កងធំគឺមានឈ្មោះ ពេជ មុំ ប៉ុន្តែគាត់ស្លាប់ហើយ ស្លាប់ប្រហែលជាជិត១០ឆ្នាំហើយ។ ដល់ទៅផុតពីកងធំ គឺមានវរៈនោះគេឈ្មោះ មិត្តបូ។ ប៉ុន្តែគេចាប់អស់ហើយ មិត្តបូ (ស្លាប់)។

[១៤:២៥:០៨]

**ស៖** សូមលោកជម្រាបជូនអង្គជំនុំជម្រះឈ្មោះ ពេជ មុំ ជាមេបញ្ជាការកងធំរបស់លោកមើល គាត់ឈ្មោះអី? ហើយធ្វើអ្វីខ្លះដែរ?

**ឆ៖** បាទ ពេជ មុំ នោះគាត់ជាមេកងធំ គឺក្តាប់ចំនួនបីកងតូច ដូចខ្ញុំជម្រាបថាគាត់ស្លាប់បាត់ទៅហើយណា។

**ស៖** ដូច្នេះក្នុងឋានៈលោកជាមេកងតូចនេះ លោកត្រូវនិយាយជាមួយគាត់ រាយការណ៍ជូនគាត់ប្រចាំថ្ងៃឬយ៉ាងម៉េច? ឧទាហរណ៍ការងារដែលសម្រេចបានប្រចាំថ្ងៃ ឬក៏ចំនួនកម្លាំងការងារដែលលោកក្តោបក្តាប់ តើលោកមានទំនាក់ទំនងប្រចាំថ្ងៃយ៉ាងម៉េចដែរជាមួយមេកងធំនោះ?

**ឆ៖** បាទ រាល់ពេលល្ងាចម៉ោងប្រាំ ដែលយើងឈប់ពីសម្រាកការងារគឺត្រូវតែរាយការណ៍ជូនទៅមេកងធំ អំពីកម្លាំងពលកម្មដែលយើងធ្វើបាន។ ក្នុងមួយកងតូចយើងធ្វើបានប៉ុន្មាន យើងបូកសរុបទៅ បើមួយថ្ងៃក្នុងម្នាក់៣ម៉ែត្រគូប យើងសរុបទៅឃើញប៉ុន្មាន យើងរាយការណ៍ជូនគេ។ អរគុណ។

**ស៖** អ៊ីចឹងតើមេកងធំមានណែនាំ ឬបង្គាប់អ្វីមកលោកទេ?

**ឆ៖** បាទ មិនមានអីទេ គ្រាន់ថាខំប្រឹងធ្វើការ ហើយណែនាំនៅក្នុងកងរបស់មិត្តឯងកុំឲ្យមានពីណាថាអាក់ខានធ្វើការ កុំឲ្យខ្ជិលច្រអូសប្រយ័ត្នបាត់ខ្លួន គ្រាន់តែប្រាប់តែប៉ុណ្ណោះ។

**ស៖** អ្នកណាប្រាប់លោកថា កុំឲ្យខំប្រឹងធ្វើការអីអ៊ីចឹង ហើយបើកុំឲ្យមានបញ្ហាអី បើមិនអ៊ីចឹងទេប្រយ័ត្នបាត់ខ្លួន អ្នកណាជាអ្នកនិយាយសម្ដីនេះ?

**ឆ៖** គឺមិត្តប៊ូ ប្រធានវរៈ។

[១៤:២៧:៣៨]

**ស៖** ចាំ លោកចាំទេពេលហ្នឹងពេលដែលគាត់ប្រាប់អ៊ីចឹងមកលោកហ្នឹង ថាតើពេលហ្នឹងលោកមានវត្តមាននៅជាមួយអ្នកណាដែរ?

**ឆ៖** អត់ទេ អត់មានវត្តមានអ្នកណាទេ គឺខ្ញុំទៅរាយការណ៍គេផ្ទាល់អំពីការធ្វើពលកម្មបានប៉ុន្មានម៉ែត្រគូបជូនមេវរៈ មេកងធំដែលគេនៅជុំគ្នាប៉ុណ្ណោះឯង។

**ស៖** ដូច្នេះពាក្យដែលលោកបានប្រើថា មេកងតូច និងមេកងធំហ្នឹង គឺថាវាជាពាក្យពេចន៍គេប្រើក្នុងរចនាសម្ព័ន្ធកងទ័ព។ ហេតុអីបានជាគេយករចនាសម្ព័ន្ធពាក្យពេចន៍ដែលគេប្រើក្នុងជួរកងទ័ពនេះយកទៅប្រើនៅក្នុងកងចល័តក្នុងតំបន់៥នេះ?

**ឆ៖** បាទ មិនដឹងជាយ៉ាងម៉េចដែរអារឿងនោះខ្ញុំអត់ដឹងទេ អារឿងគេរៀបចំអារចនាសម្ព័ន្ធនោះណ៎ា។ ប្រៀបបានដូចជាយោធាអ៊ីចឹងណ៎ា គេរៀបចំមានតាមលំដាប់ៗមក។ រឿងឲ្យខ្ញុំដឹងថាយ៉ាងម៉េច យ៉ាងណានោះ គឺខ្ញុំអត់ដឹងទេបាទ។

**ស៖** ពាក្យថា “សមរភូមិក្ដៅ សមរភូមិស្រួច” អីជាដើមនេះ ថាតើគេមានយកទៅពាក្យពេចន៍ទាំងនេះប្រើប្រាស់នៅការដ្ឋានទំនប់ត្រពាំងថ្មទេ?

**ឆ៖** បាទ គេតែងលើកឡើងថា ទំនប់អាងត្រពាំងថ្មជាសមរភូមិក្ដៅណាស់ គឺកម្លាំងស្រួច គឺចល័តតំបន់ គេហៅថាកម្លាំងស្រួច កម្លាំងទី១។

[១៤:២៩:៣៩]

**ស៖** ចុះលោកនិយាយ -- លោកយល់ថាម៉េចដែរ នៅពេលដែលគេប្រើពាក្យថាជា “សមរភូមិក្ដៅ” អ៊ីចឹង?

**ឆ៖** បាទ ខ្ញុំយល់ថាពាក្យប្រើនោះ គឺជាពាក្យក្ដៅបំផុត ធ្វើឲ្យយើងខ្ញុំនោះគឺថាមិនអាចទម្រន់ស្នាក់ ទម្រន់បានទេ ត្រូវតែប្រឹង ខំដោយសារខ្លាច។ គេមើលឃើញថា ឯងមិនប្រឹង គឺជាប់និន្នាការ

នយោបាយ ដូច្នេះត្រូវតែប្រឹង ព្រោះថាជាក្តៅបំផុត អាហ្នឹងសមរភូមិ។ និយាយទៅថា សមរភូមិខ្លាំងអាងហ្នឹង។

**ស៖** តើលោកធ្លាប់ដែលឮសួរអ្នកណាម្នាក់និយាយអំពីការបូជាជីវិតរបស់គេ នៅក្នុងពេលធ្វើសង្គ្រាមជាមួយនឹងទាហាន លន់ នល់ ទេ? មានដែលឮគេនិយាយអំពីពាក្យ “កងទ័ពបូជាជីវិត” អីនេះទេ?

**ឆ៖** បាទ អត់ទេ។ ខ្ញុំអត់ដែលដឹងទេ។

**ស៖** បាទ អរគុណ។--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

គ្រាន់ជាការកត់សម្គាល់ទេ លោកប្រធាន គឺខ្ញុំស្នើទៅតំណាងសហព្រះរាជអាជ្ញា ថាតើតំណាងសហព្រះរាជអាជ្ញាបានព័ត៌មាននេះមកពីណាដែរ?

[១៤:៣១:២៥]

**លោក ត្រាវីស ហ្វារ៖**

គឺឯកសារ E3/771 ជាឯកសារទស្សនាវដ្តីទង់បដិវត្ត ជាទស្សនាទង់យុវជនបដិវត្តចុះខែកក្កដា ១៩៧៧ មានការរៀបរាប់នៅត្រង់ ពីរទំព័រមក មកដល់ពីរទំព័រកន្លះមក ឃើញនិយាយអំពីស្ថានលក្ខខណ្ឌការងារ ដែលក្នុងនោះនិយាយពីកម្លាំងនោះ គឺថាធ្វើទាំងថ្ងៃ ទាំងយប់។ ធ្វើការក្រោមកម្តៅថ្ងៃ ក្រោមភ្លៀង ហើយគេប្រៀបធៀបឲ្យប្រឹងធ្វើការ ដោយសារកងទ័ពនោះ គឺថាបូជាអាយុជីវិតមិនស្តាយអាយុជីវិតរបស់ខ្លួន គឺថាមាននិយាយចំណុចនេះ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សី លោកបានលើកឡើងអំពីឈ្មោះ តាវ៉ាល់ ៗនេះជាមនុស្សរបៀបណាដែរ តាមដែលលោកដឹង?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ តាវ៉ាល់ នោះគឺរាងវៀរបស់គាត់ គឺមិនជាធំ ហើយមិនជាខ្ពស់ ទាបអីប៉ុន្មានទេ

កណ្តាល ប៉ុន្តែគាត់និយាយទៅ គឺដូចថា ឃើញតែមុខគួរតែខ្លាច ព្រោះគាត់កាចសាហាវ បាទ។

**ស៖** សូមលោក -- តើលោកចង់និយាយថាម៉េច? ថាគាត់កាចហ្នឹង ចង់និយាយថាម៉េច?

**ឆ៖** បាទ ព្រោះគាត់កាចនោះ គឺសម្តីគាត់ឡូឡា។ ពេលដែលកម្លាំងធ្វើការអ៊ីចេះ គាត់មើលឃើញ ព្រោះខ្ញុំនៅឆ្ងាយឃើញឡូឡា។ នៅកន្លែងជាងធ្វើស្ពានទី១។ ដល់ជាងធ្វើទៅវាមិនសូវបានត្រឹមត្រូវដូចចិត្តគាត់ គាត់យកប៉ែលបានចូកគ្រវីគ្រវាត់ ធ្វើចេះវាខ្លាំង។ ដូច្នេះអានោះហើយដែលថាកាចមិនហៅថា ប្រើនយោបាយអប់រំណែនាំសោះ។

[១៤:៣៣:៥៦]

**ស៖** លោកដែលឮសួរ ឬក៏ឮសួរអ្នកណាប្រៀបធៀបឈ្មោះគាត់ហ្នឹងថា គឺជាមេឃាតករទេ?

**ឆ៖** បាទ អានេះបើនិយាយទៅ គាត់កាចដល់តែនៅក្នុងអាង ក្រោមអាងដែលស្លាប់ គឺក្នុងការគ្រប់គ្រងរបស់គាត់។ មានតែគាត់ជាមេឃាតករ ព្រោះមានអ្នកណាធំជាងគាត់ គាត់នៅក្នុងអាងហើយ។ ដូច្នេះអាការស្លាប់នៅនឹងអាង គឺមានតែគាត់បញ្ជាឲ្យក្រោមឱវាទ ដូចជាមានកងយោធា យោអីនៅប្រចាំការនៅនោះសម្លាប់។

**ស៖** តើលោកមានបានដឹងថា គាត់មានជំនួយការ ដែលទទួលខុសត្រូវជំនួសគាត់ក្នុងការដាក់ទណ្ឌកម្មអ្វីមួយចំពោះអ្នកធ្វើការខុសឆ្គងណាមួយទេ?

**ឆ៖** បាទ គឺនៅក្រោមឱវាទរបស់គាត់ គឺមានឈ្មោះ មិត្តយន់ ហៅ តាយន់ៗ ដែលនៅក្រោមឱវាទ។ ដូច្នេះបើគាត់មិននៅ យន់ ជាអ្នកការគ្រប់គ្រង។

**ស៖** ហើយលោកដឹងអំពីឈ្មោះ តាយន់ នេះមានចូលរួមពាក់ព័ន្ធក្នុងដាក់ទណ្ឌកម្មទៅដល់កម្លាំងធ្វើការដែលគេចាត់ទុកថាជាមនុស្សខ្ជិលច្រអូសអីទេ?

**ឆ៖** បាទ សូមសាដើមទៀតសំណួរ ខ្ញុំស្តាប់មិនទាន់។ សូមលោកប្រធានម្តងទៀត ខ្ញុំស្តាប់អត់ទាន់។

[១៤:៣៦:០៥]

**ស៖** បាទ ដើម្បីសន្សំពេលវេលាខ្លះនោះ គឺថាខ្ញុំសូមអានឲ្យលោកស្តាប់នូវចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារតែមួយទេដែលខ្ញុំបង្ហាញពីខាងដើមមុនគឺERN អង់គ្លេស 00726113, ខ្មែរ 0057732, បារាំង 00743242។ ត្រង់កន្លែងនេះ គេសួរលោកអំពីឈ្មោះ តាវ៉ាល់ ហើយលោកបាននិយាយសំដៅគាត់ថា ជាមេឃាតករដែរដល់ ហើយលោកបន្តមកខាងក្រោមទៀតថា៖

"គាត់ជាមេក្តាប់រួម មានអ្នកដទៃទៀតជិតស្និតនឹងគាត់។ ឧទាហរណ៍ ជំនួយការដៃស្តាំរបស់គាត់ គឺជាអ្នកទទួលខុសត្រូវក្នុងការដាក់ទណ្ឌកម្មទៅលើអ្នកកម្លាំងណាដែលមើលទៅឃើញថា ខ្ជិលច្រអូស ខ្ជិលធ្វើការ ឧទាហរណ៍នៅពេលណាគេចាត់ឲ្យធ្វើការ ហើយអ្នកដែលធ្វើការនោះគឺថា មើលទៅឃើញ ខ្ជិលទ្រេតទ្រោតនោះគឺថា ត្រូវបានគេដកចេញមកដូចស្តែអ៊ីចឹង។" អ៊ីចឹងសូមលោកជម្រាបផង តើបុគ្គលដែលលោកនិយាយថា ជាអ្នកទទួលខុសត្រូវដាក់ទណ្ឌកម្មដូចថា តែកាលណាគេឃើញអ៊ីចឹង គឺថាគេដកចេញដូចដកកូនស្តែអ៊ីចឹង លោកសំដៅនិយាយអ្នកណាហ្នឹង?

**ឆ៖** បាទ ព្រោះនៅនោះ បើសិនជានៅក្នុងសមាជិកណាមួយខ្ជិលច្រអូស ប៉ុន្តែដោយឡែកកងខ្ញុំអត់មានទេ គឺមានកងគេ ខ្ជិលច្រអូសគេដកចេញ។ ដកចេញយកទៅ គេយកទៅឯលើ ដូច្នេះមិនដឹងណាដូចខ្ញុំបានជម្រាបប្រាប់ថា តាវ៉ាល់ នោះគឺជាមេឃាតករ។ គឺគាត់ជាអ្នកគ្រប់គ្រងនៅកន្លែងនោះ ដូច្នេះនៅក្រោមឱវាទរបស់គាត់ អ្នកដែលដល់ ដូចជាគាត់នោះអ្នកទទួលការខុសត្រូវជំនួស។ បើសិនជាគាត់កុំបញ្ជាឲ្យទៅសម្លាប់ គឺមិនបានទៅជាឃាតករទេ។ ដូច្នេះគឺបញ្ជាឲ្យទៅសម្លាប់ចោល គឺគាត់ហើយជាមេឃាតករផ្ទាល់តែម្តង។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំក្រឡេកទៅមើលឃើញថា ជិតដល់ពេលសម្រាកហើយ។ តើពេលឈប់សម្រាកសិន ឬក៏បន្តទៅទៀតលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩នាទី ដល់ម៉ោង ១៤:៥៩នាទី)*

[១៤:៥៩:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកសាក្សីមុនពេលឈប់សម្រាកនេះ លោកបានឆ្លើយ និយាយអំពីឈ្មោះម្នាក់ដែលថាជាអនុរបស់ តាវ៉ាល់ នៅពេល តាវ៉ាល់ អវត្តមាន។ លោកដឹងទេ តាវ៉ាល់ អវត្តមានពីការដ្ឋានការងារហ្នឹងញឹកញាប់ប៉ុនណាដែរ?

**លោក តក់ ប៉ិុយ៖**

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ ការអវត្តមាន មិនដឹងជាញឹក ឬក៏ញាប់ទេណា គ្រាន់តែជួនកាលមេវរៈថាលោក តាវ៉ាល់ អត់បាននៅ តាវ៉ាល់ គាត់មិនបាននៅ។ ដឹងតែតាមរយៈប្រធានវរៈហ្នឹង។

**ស៖** លោកដឹងទេថា តាវ៉ាល់ ទៅណាដែរ នៅពេល តាវ៉ាល់ មិនមានវត្តមាននៅការដ្ឋានការងារហ្នឹង?

**ឆ៖** អានោះ ដែលនិរតីចូលមក បាត់ខ្លួន បានគាត់មិនបាននៅ។ ប្រហែលជាចាប់ខ្លួនគាត់បាត់ក្នុងការចាប់នេះ គឺប្រហែលជានិរតីគេចាប់។ នេះការសន្និដ្ឋានរបស់ខ្ញុំបាទ។

[១៥:០១:៣៥]

**ស៖** នៅក្នុងអំឡុងពេលដែលគេចាប់ខ្លួនគាត់ អំឡុងពេលដែលគាត់បាត់ខ្លួន លោកដឹងថា មេពីលើ តាវ៉ាល់ ហ្នឹងជាអ្នកណាទេ? ដឹងថា តាវ៉ាល់ រាយការណ៍ទៅមេខាងលើគាត់ហ្នឹងជាអ្នកណាទេ?

**ឆ៖** បាទ គឺទៅលើទៀត ខ្ញុំមិនដឹងថាមេនៅលើនោះ អ្នកណាទេ គ្រាន់តែដឹងថា គេរាយការណ៍ទៅលើ មិនដឹងទៅលើត្រឹមណា លើតំបន់ក៏មិនដឹង។ នេះខ្ញុំមិនសន្និដ្ឋានថា អ្នកណាទេ ព្រោះខ្ញុំអត់បានស្គាល់។

**ស៖** ហើយខ្លួនលោកផ្ទាល់នេះ លោកដែលរាយការណ៍ផ្ទាល់ទៅ តាវ៉ាល់ អំពីការងារ លទ្ធផល

ការងារ ឬក៏អ្វីៗទេ?

**ឆ៖** បាទ អត់ទេ ខ្ញុំអត់ដែលបានរាយការណ៍ជូន គាវ៉ាល់ ទេ ព្រោះខ្ញុំនៅតូចតាចណាស់មិនអាចទៅដល់ទេ។ បានតែត្រឹមរាយការណ៍ជូន ត្រឹមកងធំ ឬក៏វរៈប៉ុណ្ណោះឯង អំពីលទ្ធផលដែលធ្វើការងារបាន។ បាទ អរគុណ។

**ស៖** បាទ អរគុណ។ ឥឡូវហ្នឹង ខ្ញុំចង់សួរលោកអំពីពិធីមួយដែលលោកបានរៀបចំ -- ដែលលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមើលទៅគឺថា ជាការគោរពពិធីមួយ គឺជាពិធីប្រារព្ធ ក្នុង -- ពិធីពីរក្នុងពេលតែមួយ គឺពិធីចូលឆ្នាំខ្មែរផង និងពិធីជោគជ័យថ្ងៃរំដោះ ១៧ មេសាផង។ តើលោកអាចជម្រាបអង្គជំនុំជម្រះអំពីពិធី ដែលគេរៀបចំនេះបានទេ?

**ឆ៖** បាទ ក្នុងពិធីចូលឆ្នាំ ហើយនិងពិធី ១៧ មេសា គឺវាជាប់គ្នាណា។ ដូច្នេះគេត្រូវប្រារព្ធធ្វើអង្គមីទ្ទិង។ ប៉ុន្តែខ្លឹមសារនៃការអង្គមីទ្ទិងនោះ ខ្ញុំមិនបានចាំបានទេ ប៉ុន្តែគេ មីទ្ទិងគេធ្វើពីភ្នំពេញ ដូច្នេះខ្ញុំនៅឯណោះ គ្រាន់តែបានមួយអង្គុយស្តាប់។ ខ្លឹមសារនៃអង្គមីទ្ទិងនោះ ខ្ញុំចាំអត់បានវាយូរឆ្នាំណាស់មកហើយ។ គ្រាន់ថាធ្វើមីទ្ទិង ហើយនិងចូលឆ្នាំវាជុំគ្នា ព្រោះចូលឆ្នាំថ្ងៃ១៤, ១៥, ១៦ ហើយនិង១២ មេសាអីចឹងណ៎ា។ គេសរុបគ្នា យកមកអាថ្ងៃ១៤, ១៥ហ្នឹងហើយ ធ្វើមីទ្ទិង។ វាធ្វើមិនមែនធ្វើនេះទេ ធ្វើតែមួយថ្ងៃ។ មួយថ្ងៃមិនបានមួយថ្ងៃ មួយព្រឹក។ បាទអរគុណ។

[១៥:០៤:៣១]

**ស៖** ហើយលោកចាំទេ នៅពេលគេប្រារព្ធពិធីយ៉ាងដូច្នេះ មានភ្លេង មានតន្ត្រី មានអីយកទៅលេង ដើម្បីជាការកំដរដល់ពិធីហ្នឹងទេ?

**ឆ៖** អត់ទេ អត់មានពិធីណានោះទេ មានតែចប់ពីមីទ្ទិងទៅ ត្រឡប់ទៅការដ្ឋានរៀងៗខ្លួនកន្លែងនៅកន្លែងណា គឺត្រឡប់ទៅកន្លែងនោះវិញ។

**ស៖** ឥឡូវ ខ្ញុំសូមសួរលោកនូវអ្វីដែលលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺ ERN អង់គ្លេស 00726120, ខ្មែរ 00057440, បារាំង 00743250 ដល់ 51។ លោកនិយាយអំពីពិធីប្រារព្ធខួបជ័យជម្នះនេះ គឺថាជាការប្រារព្ធចូលគ្នារវាងពិធីបុណ្យចូលឆ្នាំខ្មែរផង និងពិធីខួបជ័យជម្នះផង។ ហើយអ្នកសម្ភាសនោះសួរថា ក្នុងរយៈពេល៣ថ្ងៃហ្នឹង ១៥, ១៦, ១៧ហ្នឹង សូមដកស្រង់ លោកឆ្លើយថា៖ "ត្រឹមត្រូវហើយ។ គេធ្វើការនៅអាងទឹកហ្នឹង មានភ្លេង មានអ្នករាំដែរ ប៉ុន្តែអ្នករាំទាំងអស់ហ្នឹង គឺថាស្លៀកឯកសណ្ឋាន--។

លោកប្រធាន មានៗបញ្ហាសំឡេង ឬក៏យ៉ាងម៉េច លោកប្រធាន? វាជាបញ្ហារបូតខ្សែពីត្រចៀកនេះទេ។ បាទ ខ្ញុំសូមអានចម្លើយជូនឲ្យលោកស្ដាប់ម្ដងទៀត លោកបានឆ្លើយ សូមដកស្រង់៖ "ត្រឹមត្រូវហើយ គេរៀបចំពិធីនេះនៅការដ្ឋានលើកទំនប់ មានភ្លេង មានអ្នករាំ ប៉ុន្តែគេរាំមានស្លៀកពាក់ឯកសណ្ឋានដូចគ្នា ហើយស្ពាយកាំភ្លើងទៀត។ ខ្លឹមសារនៃបទចម្រៀងហ្នឹង គឺនិយាយអំពីការចាប់ខ្លួនអាខ្មាំងយួន ហើយនិងអាខ្មាំង លន់ នល់។" បញ្ចប់ការដកស្រង់។ សូមអធ្យាស្រ័យ លោកចាំទេ លោកថាលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថាអ៊ីចឹង។ អ៊ីចឹងលោកពន្យល់បន្តិចបានទេ អំពីចម្រៀងដែលគេចាក់នៅពេលនុ៎ង?

[១៥:០៧:៣៩]

**ផ៖** បាទ ការសម្ដែងសិល្បៈនោះ គឺមិនមែននេះទេ គឺប្រហែលជាច្រឡំ។ គឺសម្ដែងសិល្បៈនៅពិធីរៀបអាពាហ៍ពិពាហ៍ដែលគេសម្ដែងសិល្បៈស្លៀកពាក់ជាឯកសណ្ឋានខ្មៅ ហើយកាន់កាំភ្លើង។ ដូចនេះឃើញថា ការដែលច្រៀងនោះ ខ្ញុំក៏ចាំមិនបានដែរ វាយូរឆ្នាំទៅហើយ មិនដឹងម៉េច។ ប៉ុន្តែដឹងថាការកម្ទេចអាខ្មាំង អាខ្មាំងនោះវាមានខ្មាំងទាហាន លន់ នល់ នោះវាស្រែកថាខ្មាំង, វាកម្ទេច វាយកកាំភ្លើងភ្ជង់កម្ទេច។ ហើយរហូតដល់អ្នកដែលធ្វើទាហាននោះ គឺស្លៀកពាក់ខោអាវទាហាន អ្នកដែលធ្វើយោធាស្លៀកពាក់ជាខ្មៅ។ ដល់តែពេលគេច្រៀងកម្ទេច កម្លាំងទៅ ច្បាំងគ្នាទៅ បាញ់ប្រេវប្រាវ អានោះមិនមែនបាញ់គ្រាប់នេះ គេបាញ់គ្រាប់ឡង់។ ប្រេវប្រាវទៅ ខ្មាំង លន់ នល់ ក៏ដួលស្លាប់អស់ យកជ័យជម្នះ គេស្រែកថា "ជយោ៧មករា! -- អូន៉េ ១៧មេសា!" បាទ។

**ស៖** អរគុណ។ ឥឡូវខ្ញុំសួរអ៊ីចេះវិញ តើលោកនៅចាំទេ នៅពេលហ្នឹងស្ដាប់ឮថា មានការចាប់ខ្លួនវៀតណាម ចាប់ខ្លួនខ្មាំងរបប លន់ នល់ ទេ?

**ផ៖** បាទ អានោះអង្កាល់ដែល និយាយទៅវាចូលទៅអំឡុងដើមនោះវិញ គឺកាលដែលខ្ញុំនៅក្នុងសហករណ៍ នោះគេប្រមូលចាប់ចិន ចាប់យួន អានោះចាប់មែន។ ដល់តែខ្ញុំនៅកងចល័តនោះ មិនមានទេណ៎ា។

[១៥:០៩:៣១]

**ស៖** សូមផ្ដោត សូមឲ្យលោកផ្ដោតតែលើចម្រៀងបានហើយ។ លោកចាំ នៅចាំទេខ្លឹមសារនៃបទចម្រៀងដែលច្រៀងអំពីការចាប់ខ្លួនអាខ្មាំងយួនហ្នឹង?

**ផ៖** អត់ទេ ខ្ញុំចាំអត់បានទេ អារឿងចម្រៀង។ វាយូរទៅហើយ ខ្ញុំចាំអត់បាន រឿងការច្រៀង

របស់ពួកសិល្បៈនោះ។

**ស៖** ឥឡូវត្រឡប់ទៅនិយាយអំពីអ្វីដែលលោកទើបលើកឡើងថា មានការចាប់ខ្លួនវៀតណាម នៅតាមឃុំមែន។ សូមលោករៀបរាប់ឲ្យលម្អិតបន្តិចមើល តើលោកអាចប៉ាន់ប្រមាណចំនួនមើល គេចាប់ប្រជាជនវៀតណាមហ្នឹងបានប្រហែលជាចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** ដូច្នេះគឺការដែលប៉ាន់ស្មានរបស់ខ្ញុំ ខ្ញុំមិនប៉ានសន្និដ្ឋានថាចាប់ប៉ុន្មានទេ ប៉ុន្តែការប្រមូលគឺទាំងប្រពន្ធកូនរបស់គេ គឺគេប្រមូល ប៉ុន្តែប្ដីគេចាប់ទៅមុន ប៉ុន្តែក្រោយមកបានគេប្រមូលប្រពន្ធកូន។ គេថាផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយ។ ដូច្នេះមិនដឹងថា គេយកទៅកន្លែងណា ស្រាប់តែបាត់ខ្លួនតែម្ដង។ ដូច្នេះសន្និដ្ឋានថាប្រហែលជាយកទៅសម្លាប់ចោល។

**ស៖** សូមលោកបញ្ជាក់បន្តិចមើល៍ តើយានយន្តដែលគេយកទៅដឹកជញ្ជូនជាឡានប្រភេទអ្វីដែរ?

**ឆ៖** ឡានដែលដឹកទៅនោះ គឺឡានកងទ័ព ហៅឡានអាមេរិកាំងពណ៌ទាហាន ខៀវៗ។

[១៥:១១:៣៦]

**ស៖** ហើយលោកអាចប្រាប់អំពីពេលវេលាបានទេ ពេលដែលគេចាប់ខ្លួន ដឹកជញ្ជូនទៅហ្នឹង តើក្នុងពេលវេលាណាដែរ?

**ឆ៖** កាលដែលដឹកជញ្ជូនប្រពន្ធកូនរបស់គេនោះ គឺប្រហែលជាបើមិនម៉ោងដប់ទេ ម៉ោងដប់មួយព្រឹក។ គេប្រមូលយកទៅ ឡើងឡានទៅទាំងអស់ ដឹកទៅមកងត្បូង ប៉ុន្តែមិនដឹងថាទៅកន្លែងណា។ ខ្ញុំមិនបានជានេះទេ គឺថានៅនឹងសហករណ៍ធ្វើការលើកភ្លឺស្រែភ្លឺអី ហើយកាប់ចម្ការដាំដំឡូង។ ដូច្នេះអាការដែលគេដឹកជញ្ជូនទៅ ព្រោះយើងក៏សន្និដ្ឋានថាគេដឹកយកទៅវ៉ៃចោល ឬក៏យកទៅកន្លែងណា ប៉ុន្តែឮគេថាផ្លាស់ទីលំនៅពីកន្លែងមួយទៅកន្លែងមួយ។ បាទ អរគុណ។

**ស៖** ហើយតើត្រឹមត្រូវដែរឬក៏អត់ទេ ក្នុងអំឡុងពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម ពេលហ្នឹងគឺថាវាកើតចំពេលលោកនៅទំនប់ត្រពាំងថ្ម ឬយ៉ាងណា?

**ឆ៖** បាទ អត់មានទេ អានោះគឺដែលប្រមូលប្រជាពលរដ្ឋចិន និងវៀតណាមនោះ គឺមិនទាន់បានលើកទំនប់អាងត្រពាំងថ្មទេ គឺក្នុងអំឡុងឆ្នាំប្រហែលជាដើម២០០៦ ឬពាក់កណ្ដាល -- ពាក់កណ្ដាល៧៦ ឬក៏ដើម៧៦ហ្នឹងឯង។

**ស៖** ការបកប្រែបកថាឆ្នាំ២០០៦ ហើយក្រោយ តើខ្ញុំថា១៩៧៦ វិញ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ ព្រោះសព្វថ្ងៃវាឆ្នាំពីរពាន់ជាងហើយ ដោយការច្រឡំមាត់ គឺឆ្នាំ១៩៧៦ ឬក៏

ដើម ឬក៏ពាក់កណ្តាល១៩៧៦ហ្នឹងបាទ។

[១៥:១៤:០៣]

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមឲ្យលោកផ្តោតការយកចិត្តទុកដាក់ទៅលើពេលវេលាដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម។ ខ្ញុំចង់ឲ្យលោកបញ្ជាក់កន្លែងមួយឈ្មោះថា "វាលតាគុយ"។ តើវាលតាគុយនេះគេប្រើប្រាស់សម្រាប់ធ្វើអ្វីដែរនៅពេលដែលលោកនៅឯការដ្ឋាននោះ?

**ឆ៖** បាទ វាលតាគុយ គឺជាវាលស្រែដែលប្រកបដោយការងារកសិកម្ម នៅខាងក្រោមអាង គេហៅវាលតាគុយ។ នោះហើយជាកន្លែងកប់នៃសាកសពដែលចល័ត ដែលគេយកទៅសម្លាប់ចោល។ ប៉ុន្តែមិនមានថាជារណ្តៅធំទេ គ្រាន់តែជីកមួយកន្លែងៗ ម្នាក់មួយៗកន្លែង ម្នាក់មួយកន្លែងៗ មិនបានជីកជារណ្តៅធំ ហើយសម្លាប់ក្នុង – ឧទាហរណ៍ថា គ្នាប្អូនដប់នាក់ស្លាប់តែមួយកន្លែងនោះទេ គឺវាយប៉ាយពាសពេញណាពាយណើ។ អរគុណ។

**ស៖** ដូច្នេះ តើវាលតាគុយមានចម្ងាយប៉ុន្មានពីកន្លែងដែលលោកធ្វើការប្រចាំថ្ងៃនេះ មានចម្ងាយប៉ុន្មានម៉ែត្រ ឬក៏មានចម្ងាយប៉ុន្មានគីឡូម៉ែត្រអ៊ីចឹង?

**ឆ៖** បើនិយាយពីវាលតាគុយ គឺវាជាប់នឹងជើងទំនប់អាងត្រពាំងថ្មនេះឯង អត់មានឆ្ងាយប៉ុន្មានទេ។ វាជាប់គ្នានឹងអាង នឹងជើងទំនប់ លាតសន្ធឹងដូចជាអាងទឹកអ៊ីចេះទៅ ទំនប់អ៊ីចេះគឺវាលតាគុយទៅអ៊ីចេះទាំងអស់ណេះ។

**ស៖** លោកបាននិយាយថា សាកសពកងកម្លាំងចល័តហ្នឹង គឺថាត្រូវបានគេយកទៅកប់ទៅត្រង់ហ្នឹង។ តើលោកដឹងទេ តើលោកដឹងដោយរបៀបណា? មានគេប្រាប់លោក? លោកឃើញដោយផ្ទាល់ ឬក៏យ៉ាងណា?

[១៥:១៦:១៣]

**ឆ៖** បាទ ខ្ញុំបានដើរទៅបត់ជើងធំទៅឃើញ ឃើញរណ្តៅប្រេះ រណ្តៅប្រេះដូចធុំក្លិនស្អុយ ដូចខ្ញុំសន្និដ្ឋានថាគេកប់ខ្មោចនៅកន្លែងនោះ។ បាទអរគុណ។

**ស៖** តើការសម្លាប់នេះដែល -- ពេលដែលលោកទៅបត់ជើងហ្នឹង លោកបានឃើញរឿងហ្នឹងតែម្តងទេ ឬក៏លោកឃើញញឹកញាប់ដែរ?

**ឆ៖** បាទ ដែលខ្ញុំទៅបត់ជើងៗតែម្តងទេ ដល់ឃើញទៅ ខ្ញុំឈប់ទៅបណ្តោយគឺខ្ញុំបត់នៅកន្លែងដែលជីកនៅតាមកងណ៏ា តាមក្រុម ធ្វើបង្គន់អនាម័យ ព្រោះមិនមែនតែអនាម័យទេ គ្រាន់តែជីកជាអន្លង់

ដាក់ឈើគងពីរ សម្រាប់យើងបត់ជើងណ៎ា ដែលហ៊ុមមានស្បូវដាក់ហ៊ុមត្រឹមខ្លួនប៉ុណ្ណេះៗ។ ពេលនោះ ខ្ញុំបត់ជើងនេះ ឈប់ទៅកន្លែងនោះបណ្តោយ វាមើលទៅឃើញ នឹកឃើញថារូបគេរូបឯងបើស្លាប់ទៅ យ៉ាប់។ ដូច្នេះខ្ញុំវាក្នុងនាមជាប់ប្រវត្តិផង ខ្ជិលទៅកំប៉ិកកំប៉ុកនៅកន្លែងនោះ សុខចិត្តបត់ជើងនៅតាម កន្លែងដែលជីកងណោះ។

**ស៖** ខ្លួនលោកផ្ទាល់ ធ្លាប់ដែលបានឃើញគេសម្លាប់អ្នកណាម្នាក់នៅវាលតាគុយ ឬនៅកន្លែង ណាមួយទេ?

**ឆ៖** បាទ អត់ទេ អត់ដែលឃើញទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីការចាប់ខ្លួនវិញម្តង ការចាប់ខ្លួននៅក្នុងកង របស់លោក។ តើលោកមានបានដឹងថា មានកម្លាំងកម្មករណាម្នាក់ត្រូវបានគេចាប់ខ្លួន ឬក៏បាត់ខ្លួនដោយ ហេតុផលណាមួយទេ?

[១៥:១៨:១៥]

**ឆ៖** អត់ទេ នៅកងរបស់ខ្ញុំអត់មានបាត់ខ្លួន បាត់អីទៅណាទេ មានតែពីរត់ចេញពីកន្លែងនោះ ទៅផ្ទះសម្បែងសហករណ៍គេវិញប៉ុណ្ណោះឯង។

**ស៖** ចុះនៅខាងក្រៅកងតូចរបស់លោក តើលោកមានដឹងថា មានការចាប់ខ្លួនអ្នកណាម្នាក់ ក្រៅពីកងតូចរបស់លោកទេ?

**ឆ៖** អានោះខ្ញុំអត់ដឹងទេ ជារឿងរបស់គេ ខ្ញុំដឹងតែរឿងកងរបស់ខ្ញុំ។ រោងនៅផ្សេងៗពីគ្នា រឿង អីខ្ញុំដឹងថាចាប់នោះ ខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវខ្ញុំសូមអានសារមួយចេញពីកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌល ឯកសារកម្ពុជា ហើយភាសាអង់គ្លេសគឺ 00726119, ខ្មែរ 00057739, អង់គ្លេស បារាំង 00723249 លោកនិយាយអំពីការចាប់ខ្លួន និងការបាត់ខ្លួន។ សំណួរដែលសួរលោក៖ "ថាតើមានប្រជាជន -- តើ មានលោកមានបានកត់សម្គាល់ គេយកប្រជាជនទៅទីណាទេ មុនពេលបាត់ខ្លួនហ្នឹង? សូម្បីតែយើងធ្វើ ការនៅជាប់គ្នាហ្នឹង ក៏យើងអត់ដឹងដែរ ដល់តែពេលគេមកចាប់ខ្លួនទៅនេះ ទើបយើងដឹង។ ឧទាហរណ៍ លោកត្រូវបានគេប្រាប់ថា ឲ្យបញ្ជូនទៅធ្វើការនៅក្នុងក្រុមមួយផ្សេងទៀត ឧទាហរណ៍ថាគេបញ្ជូនទៅ ពេលព្រឹក គេអត់យល់ស្របទេ គឺថាគេបញ្ជាឲ្យទៅប្តូរទៅកងមួយទៀតក្នុងពេលយប់តែម្តង។ ហើយ ក្រោយពីបុគ្គលនេះចាកចេញពីអគារ ឬកន្លែងនៅទៅ គឺថាបុគ្គលនោះត្រូវបានគេចាប់ខ្លួនតែម្តង។"

បញ្ឈប់ការដកស្រង់។ នៅក្នុងចម្លើយនេះ គឺថាមានការបញ្ជាក់លម្អិតដោយយោងទៅលើការបញ្ជូនទៅឲ្យធ្វើនៅក្នុងកងផ្សេង គេឲ្យពាក់ខោអាវ គេនិយាយពី ទៅជួបប្រជុំនៅកន្លែងណាមួយ។ តើលោកបានឃើញព្រឹត្តិការណ៍បែបនេះ កើតមានឡើងនៅត្រពាំងថ្មដែរទេ?

[១៥:២០:៥៩]

**ឆ៖** បាទ អាការដែលបាត់ខ្លួន បាត់អីនេះ គឺច្រើនតែគេដកចេញពីអង្គភាពទៅអង្គភាពមួយ។ ដូចជាប្រធានវរៈ ឈ្មោះ មិត្តបូ នេះគឺដកចេញវរៈរបស់ខ្ញុំ ទៅថាឲ្យទៅកាន់នៅកន្លែងណា។ ដូច្នេះទៅ ក៏បាត់ជ្រាប មិនដឹងជាយ៉ាងម៉េច។ ដូច្នេះការសន្និដ្ឋានរបស់ខ្ញុំ ប្រហែលជាស្លាប់ ព្រោះអត់ដែលឮឈ្មោះបោះសំឡេង។

**ស៖** លោកធ្លាប់បានឃើញគាត់ម្តងណាទៀតទេ ក្រោយពីគាត់ត្រូវគេបញ្ជូនគាត់ទៅឲ្យធ្វើនៅជាមួយកងផ្សេងនោះ?

**ឆ៖** បាទ អត់ឃើញទេ គឺមិនដឹងគេទៅកន្លែងណា គឺបាត់ជ្រាបតែម្តង។ ស្រាប់តែពេលនោះឃើញមាននិរតីគ្រប់គ្រងឡើងកាន់ភ្លាម។ ដូច្នេះ សន្និដ្ឋានថាបាត់ខ្លួន។

**ស៖** តើមាន -- ចំណុចលម្អិតពីរដែលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង តើគេហៅគាត់ចេញក្រៅអគារ ដោះខោអាវចេញ ឬក៏យ៉ាងម៉េច?

**ឆ៖** អត់ទេ អត់មានដោះខោអាវចេញទេ គឺអីវ៉ែអីវ៉ាន់ ហើយសាក់កាដូណោះ គឺច្រកខោអាវទៅតែម្តងណ៎ា ដូចយើងថាទៅនៅកាន់កន្លែងណាមួយ គឺយកទៅ។ អត់មានស្រាតខោអាវចេញទេ គឺគេឲ្យទៅតាមសម្រួល ប៉ុន្តែចេញពីកន្លែងនោះទៅ ក៏មិនដឹងយ៉ាងម៉េច យ៉ាងណានោះទេ ខ្ញុំអត់ដឹង។

[១៥:២៣:០២]

**ស៖** គាត់ទៅដោយខ្លួនឯង ឬក៏មានគេមកនាំខ្លួនគាត់ទៅ?

**ឆ៖** បាទ គាត់ទៅដោយខ្លួនឯង។ ប៉ុន្តែគេប្រាប់ថា ខ្ញុំត្រូវគេដកទៅកន្លែងនោះ ដូច្នេះគាត់ដើរទៅខ្លួនឯង ស្ពាយសាក់កាដូទៅ ពួកខ្ញុំចេញធ្វើការ គេក៏ចេញទៅឯណោះបណ្តោយ។ ដូច្នេះមិនដឹងថា គេយ៉ាងម៉េច ស្រាប់តែបាត់ខ្លួនបណ្តោយ។

**ស៖** ខ្ញុំសូមសួរលោកតែមួយចំណុចទៀត ស្តីអំពីកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺវាភ្ជាប់ទៅនឹងផ្នែកដែលខ្ញុំទើបអានអម្បាញ់នេះ។ តើគេមានឲ្យលោកមកទទួលយកមនុស្សជាជនស៊ីវិល ឬទាហានទេ? និយាយរួមគឺថាពួកគេស្លៀកពាក់ខោអាវខ្មៅ ស្ពាយកាំភ្លើងជា

ឯកសណ្ឋានសម្រាប់កងទ័ពរបស់គេ។ តើវាជួយរំឭកដល់ការចងចាំរបស់លោកថា អ្នកដែលស្លៀកពាក់ខោអាវខ្មៅ ស្ពាយអាវុធនេះធ្លាប់បានមកនាំខ្លួនលោកយកចេញទៅទេ?

**ឆ៖** អត់ទេ ខ្ញុំអត់ដែលឃើញទេ។

**លោក ត្រាវីស ហ្សារ៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១៥:២៤:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំសូមចាប់ផ្តើមដោយសួរសំណួរលោកពាក់ព័ន្ធនឹងរយៈកាលមុនខែមេសា ឆ្នាំ១៩៧៥។ លោកបាននិយាយថា លោកបានចូលធ្វើទាហាននៅក្នុងឆ្នាំ១៩៧២។ ហើយលោកមានតួនាទីជាកាប៉ូរ៉ាល់។ តើអ៊ីចឹងមែនទេ?

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ មុនឆ្នាំ៧៥ គឺនៅឆ្នាំ១៩៧២ ខ្ញុំបាទធ្វើទាហាន ប៉ុន្តែមិនមែនថាកាប៉ូរ៉ាល់ទេ ពលទោខ្ញុំសូមជម្រាបថាពលទោ កូនទាហាន។

**ស៖** ជាភាសាអង់គ្លេស ខ្ញុំឮថាពលទោ អ៊ីចឹងមែនទេ លោកអាចបញ្ជាក់ម្តងទៀតបានទេ? ឋានៈលោកជាអ្វីដែរនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំបាទជម្រាបប្រាប់ថា ក្នុងឋានៈខ្ញុំជាពលទោ ជាកូនទាហានទេ មិនមែនជាកាប៉ូរ៉ាល់កាប់អីទេ។

[១៥:២៦:៤៨]

**ស៖** តើលោកមានតួនាទីនិងភារកិច្ចអ្វីខ្លះក្នុងឋានៈលោកជាទាហាន លន់ នល់? លោកមានធ្លាប់

បានចូលរួមវាយប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហមទេ?

**ឆ៖** ក្នុងឋានៈខ្ញុំ ដូចខ្ញុំបានជម្រាបខាងដើមថា ជាពលទាហាន។ ហើយការធ្វើសង្គ្រាមគឺបានពើបប្រយុទ្ធគ្នាបីបួនដងដែរ នៅក្នុងសមរភូមិនៃស្រុកភ្នំស្រុក។

**ស៖** សូមទោស អម្បាញ់មិញនេះ ខ្ញុំអត់ស្ដាប់ឮចម្លើយទេ ក៏ប៉ុន្តែមេធាវីខាង ខៀវ សំផន បានប្រាប់ខ្ញុំហើយ។ តើខ្ញុំយល់ត្រឹមត្រូវទេ ថាលោកបានចូលរួមប្រយុទ្ធវាយទាហានខ្មែរក្រហម? ហើយលោកបានបាញ់គ្នាជាមួយនឹងទាហានខ្មែរក្រហម តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ បានបាញ់មែន។

**ស៖** ក្នុងពេលវៃគ្នា លោកមានបានសម្លាប់ទាហានខ្មែរក្រហមទេ?

**ឆ៖** អត់ទេ មិនថាត្រូវ ឬខុសទេ ចេះតែបាញ់ ដឹងជាត្រូវ វាមិនមែនថាដូចទល់មុខអ៊ីចេះទេ គឺបាញ់ឆ្ងាយណ៎ា ចម្ងាយពីរបីរយម៉ែត្រ។ បាញ់ដាក់គ្នាទៅវិញទៅមក។ មិនដឹងជាត្រូវឬក៏ខុសយ៉ាងម៉េចយ៉ាងណានោះទេបាទ។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** បើខ្ញុំមិនច្រឡំទេ គឺលោកឈរជើងនៅស្រុកភ្នំស្រុក នៅពេលដែលធ្វើការជាទាហាននោះ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែន។

[១៥:២៩:៥០]

**ស៖** ពេលដែលលោកធ្វើជាទាហាននៅចន្លោះឆ្នាំ៧២ ដល់ឆ្នាំ៧៥ តើលោកធ្លាប់ឃើញគេកាត់ក្បាលទាហានខ្មែរក្រហមដែលគេចាប់យកមកធ្វើជាឈ្លើយសឹកទេ?

**ឆ៖** បាទ អត់ទេ អត់ដែលឃើញទេ។

**ស៖** នៅក្នុងប្រវត្តិរូបរបស់លោក គឺប្រវត្តិរូបដែលគេតម្រូវឱ្យលោកសរសេរនៅក្រោយខែមេសាឆ្នាំ៧៥ តើលោកមានបានសរសេរនៅក្នុងប្រវត្តិរូបហ្នឹងថា លោកជាអតីតទាហាន លន់ នល់ ទេ?

**ឆ៖** បាទ ខ្ញុំបានរៀបរាប់ អតីតជាទាហាន លន់ នល់ មែន ក៏ប៉ុន្តែការលាក់ខ្លួនរបស់ខ្ញុំគឺមិនបានធ្វើយូរទេ ដូចខ្ញុំជម្រាបថា ធ្វើតាំងពី៧២ ដល់ពេលក្រោយ១៧ មេសា ខ្ញុំលាក់ប្រវត្តិរូប។ មុនដំបូង គឺខ្ញុំជាស្ម័យត្រាណចាប់ឆ្នោត។ ដល់នោះមក បានគេផ្ដាច់ខ្លួនទៅជាទាហាន។ ដូច្នេះក្រោយ១៧ មេសា គឺការលាក់ប្រវត្តិរូបធ្វើទាហានដែរ ប៉ុន្តែអត់បានធ្វើយូរទេ ធ្វើបន្តិចបន្តួច។

**ស៖** ខ្ញុំសូមអាននូវអ្វីដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់មកខ្ញុំសូមឱ្យ

លោកឆ្លើយតប។ ទំព័រ ERN ជាភាសាអង់គ្លេសគឺ 00726111, ជាភាសាបារាំង 00743240, ជាភាសាខ្មែរគឺ 00057713 (សុំទោស) 7730។ លោកបានឆ្លើយថា៖ "នៅសម័យនោះ ខ្ញុំសរសេរថា ខ្ញុំបានចូលធ្វើទាហាន ក៏ប៉ុន្តែខ្ញុំជាកូនទាហានធម្មតា។ ហើយគេសួរខ្ញុំ ខ្ញុំប្រាប់ថា ខ្ញុំធ្វើជាទាហានបាន ៣ខែ។ គេមកសួរខ្ញុំថា ពីមុនខ្ញុំធ្វើអី? ខ្ញុំថា ខ្ញុំធ្វើទាហានបានតែ៣ខែទេ។ បន្ទាប់មកមានមេទាហានមួយទៀត មកសួរខ្ញុំទៀត ហើយខ្ញុំបានឆ្លើយថា ខ្ញុំនៅក្នុងកងការពារភូមិមួយ គឺធ្វើជាកងស្វ័យត្រាណនៅក្នុងភូមិ។" អ៊ីចឹងខ្ញុំចង់សួរលោក ថាតើលោកចាំទេថា លោកបានសរសេរប្រវត្តិរូបជាច្រើនក្រោយខែមេសា ឆ្នាំ១៩៧៥ នោះ?

[១៥:៣៣:២៥]

**ឆ៖** បាទ ខ្ញុំបានសរសេរមែន បានឆ្លើយប្រាប់គេមែន ព្រោះដូចខ្ញុំបានជម្រាបខាងដើមថា ខ្ញុំធ្វើទាហានបន្តិចបន្តួចគឺក្នុងរយៈពេល៣ខែ។ ដល់ក្រោយមកទៀត មេមួយផ្លាស់ទៅ មេមួយចូលមកទៀត ក៏ខ្ញុំបានធ្វើស្វ័យត្រាណនៅហ្នឹងឃុំ។ មេមួយបាត់ទៅ ក៏ណេះខ្ញុំទៅជាប្រជាជនធម្មតា។ បាទ ស្របមែនយល់ព្រម។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ ពីដំបូងលោកបានឆ្លើយថា ប្រសិនបើគេរកឃើញថាអ្នកណាជាទាហាន លន់ នល់ គេនឹងសម្លាប់ចោល។ ហើយលោក ទោះបីជាលោកបានកាត់បន្ថយស្ថានភាពរបស់លោកក៏ដោយ ក៏លោកបានសរសេរក្នុងប្រវត្តិរូបលោក ថាលោកជាទាហាន លន់ នល់។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ ពន្យល់ខ្ញុំបានទេ ថាហេតុអ្វីបានជាគេមិនសម្លាប់លោក ពីព្រោះលោកបានសរសេរក្នុងប្រវត្តិរូបលោកថា លោកជាទាហាន លន់ នល់ ទៅហើយនោះ?

**ឆ៖** បាទ ដែលខ្ញុំបានឆ្លើយថាទាហាន ដោយគេមិនបានសម្លាប់នោះ គឺនៅក្នុងការគ្រប់គ្រងរបស់ពាយ័ព្យ។ មិនបាននេះទេ ធ្វើទាហានបន្តិចបន្តួច ដូច្នេះខ្ញុំប្រាប់ថា ដូចជាគោចូលនឹម គេចាក់ គេរុញ គេវាយ ចេះតែទៅ ដូច្នេះការយល់ដឹងយ៉ាងម៉េច អត់ដឹងទេណា។ បាទ ដល់តែចូលនិរតីមក អានោះបានខ្ញុំផ្តាច់ ឈប់ធ្វើស្អីទាំងអស់ ទៅជាប្រជាជនធម្មតា។ ការលាក់ប្រវត្តិរូបរបស់ខ្ញុំបាទ។

**ស៖** ខ្ញុំមិនសួរចម្លើយរបស់លោក លោកបានឆ្លើយបញ្ជាក់ថា លោកជាទាហាន លន់ នល់ ទោះបីជាលោកធ្វើក្នុងរយៈពេលខ្លីក៏ដោយ ក៏ប៉ុន្តែគេដឹងប្រវត្តិរបស់លោកហើយ អ៊ីចឹង។ ហើយលោកអត់មានរឿងអីកើតឡើង ឬលោកអាចរួចខ្លួនហ្នឹង ខ្ញុំដូចជាមិនយល់អំពីបញ្ហាហ្នឹង។

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបខាងដើមហើយ គឺថាគឺនៅក្នុងការគ្រប់គ្រងហ្នឹង គឺនៅខាងភូមិភាគ

ពាយ័ព្យ អ្នកគ្រប់គ្រង ដូច្នេះគឺនៅក្នុងភូមិ ឃុំខ្លួនឯងតែម្តងអ្នកគ្រប់គ្រង។ ដូចខ្ញុំបានជម្រាបថា បើខ្ញុំមិនលាក់ប្រវត្តិរូបទេ ខ្លាចលោវាគ្រោះថ្នាក់។ ដូច្នេះ ដល់និរតីមក អានោះបានខ្ញុំលាក់ប្រវត្តិរូប ដូចខ្ញុំបានជម្រាបខាងដើម។

[១៥:៣៧:០២]

**ស៖** បាទ អរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទផ្សេងទៀត ខ្ញុំចង់និយាយអំពី តាវ៉ាល់។ មុននេះបន្តិច លោកបានឆ្លើយថា តាវ៉ាល់ ជាមនុស្សកាចសាហាវ។ មិនមែនមានតែលោកទេ ដែលនិយាយបែបនេះនោះ គឺមានសាក្សីជាច្រើនបាននិយាយបញ្ជាក់ដូចគ្នានេះផងដែរ។ តើលោកមាននឹកឃើញថាលោកបានធូរស្រាលក្នុងចិត្តទេ នៅពេលដែលគេចាប់ខ្លួន តាវ៉ាល់ នៅក្នុងខែមិថុនា ឆ្នាំ ១៩៧៧នោះ?

**ឆ៖** បាទ ខ្ញុំបាទមិនបានធូរចិត្តទេ ព្រោះនៅក្នុងដែលចាប់ តាវ៉ាល់ ទៅនោះ ក៏មានពួកនិរតីគេឡើងគ្រប់គ្រង ដូច្នេះការភ័យខ្លាចរបស់យើងខ្ញុំ ក៏នៅតែការភ័យខ្លាចណ៎ា។ មានតែព្រួយ ព្រួយបារម្ភខ្លាចតែថ្ងៃណាមួយ អញត្រូវស្លាប់។ និយាយទៅថា ថ្ងៃនេះអញរស់ ស្អែកអញស្លាប់។ ចេះតែគិតថា អឺចេះហើយ បានជាខ្ញុំចេះតែ – អ្វីដែលនេះគឺខ្ញុំចេះតែប្រឹងណ៎ា មិនៗថាធ្វើការដោយចុងដៃ ចុងជើងទេ ចេះតែប្រឹង ដោយខ្លួនជាប់និន្នាការនយោបាយ ធ្វើទាហាន លន់ នល់ របស់អាមេរិកាំង រហូតដល់ខ្ញុំចាំដល់អត្តលេខដល់សព្វថ្ងៃ។

**ស៖** នៅក្នុងចម្លើយរបស់លោក គឺក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺលេខ 00726114, ជាភាសាបារាំងគឺ 00743244, ជាភាសាខ្មែរ 00057734។ លោកបានឆ្លើយថា៖ "សមាជិកកងធំ មានទំនាក់ទំនងជិតស្និទ្ធជាមួយ តាវ៉ាល់ ហើយប្រធានកងធំដែលមិនជិតស្និទ្ធនឹង តាវ៉ាល់ នោះបាននៅរស់ ប៉ុន្តែអ្នកដែលជិតស្និទ្ធបែរជាស្លាប់។" តើលោកអាចពន្យល់ពីចំណុចនេះបានទេ ពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកនេះ? ហេតុអ្វីបានជាអ្នកជិតស្និទ្ធនៅជាមួយ តាវ៉ាល់ ត្រូវបានគេចាប់ខ្លួន ហើយអ្នកដែលមិនសូវជិតស្និទ្ធ ដែលនៅឆ្ងាយពី តាវ៉ាល់ នោះមិនត្រូវបានគេចាប់ខ្លួនទេ?

[១៥:៤០:០៣]

**ឆ៖** បាទក្នុងឆ្លើយនោះ គឺខ្ញុំជម្រាបថា បើអ្នកដែលនៅជិតស្និទ្ធជាមួយ តាវ៉ាល់ គេចាប់ តាវ៉ាល់ហើយ ត្រូវតែចាប់បន្តបន្ទាប់គ្នា។ អ្នកដែលនៅឆ្ងាយគឺមិនបានចាប់ទេ ព្រោះគ្នាអត់ដឹងរឿងអ្នកដទៃ។ បើនិយាយទៅដូចសេនាដៃស្តាំរបស់ តាវ៉ាល់ បានគេចាប់បន្តបន្ទាប់នោះ។ ហើយខ្លះទៅក៏គេចខ្លួនរត់

ដោយចាប់មិនបាន រត់ចេញពីកន្លែងនោះ។ អរគុណ។

**ស៖** ចុះលោកផ្ទាល់លោកជិតស្និទ្ធនៅកៀកនឹង តាវ៉ាល់ ទេ?

**ឆ៖** បាទ អត់ទេ នៅដាច់ដោយឡែកឆ្ងាយ។

**ស៖** ដូច្នេះខ្ញុំអាចនិយាយបានទេថា លោកគឺលោកមិនខ្លាចគេចាប់ខ្លួនទេ ពីព្រោះលោកមិនជិតស្និទ្ធអីនឹង តាវ៉ាល់ ទេ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ព្រោះរឿងខ្ញុំគឺនៅឆ្ងាយពី តាវ៉ាល់ ណា។ ដូច្នេះការដែលចាប់ខ្លួន លុះត្រាតែនៅកៀកនឹង តាវ៉ាល់។ និយាយទៅស៊ីចុកបុកទំពា ល្អកល្អិនជុំ តាវ៉ាល់ អានោះបានបាត់ខ្លួន។ អ្នកដែលនៅឆ្ងាយដូចខ្ញុំពួកតូចតាច មិនអាចនឹងនេះបាន គឺមិនភ័យខ្លាចអ្នកណាចាប់ទេ ភ័យខ្លាចតែខ្លួនមានប្រវត្តិរូបអត់ល្អ ប៉ុន្តែខ្លាចតែគេស្រាវជ្រាវដឹង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ លោកសាក្សី។ តើលោកកត់សម្គាល់យ៉ាងម៉េចបាន ថាអ្នកដែលជិតស្និទ្ធនឹង តាវ៉ាល់ ត្រូវបានគេចាប់ខ្លួននោះ? លោកឃើញដោយផ្ទាល់ភ្នែក ឬក៏លោកស្តាប់ឮពីគេ? លោកដឹងដោយរបៀបណាថា អ្នកដែលជិតស្និទ្ធនឹង តាវ៉ាល់ ត្រូវបានគេចាប់ខ្លួននោះ?

[១៥:៤២:៥០]

**ឆ៖** បាទ គឺអ្នកដែលនៅក្រោមឱវាទ គឺនិយាយទៅគឺចេញចូលនៅកន្លែងគាត់ កន្លែង តាវ៉ាល់ រាយការណ៍ជូន តាវ៉ាល់។ ដូច្នេះបានជាត្រូវចាប់ តាវ៉ាល់ ត្រូវតែចាប់ខ្លួន។ អ្នកដែលមិនបានចាប់ខ្លួន ខ្លាចលោជាប់ ក៏រត់គេចខ្លួនចេញពីកន្លែងកងចល័ត។ មិនដឹងជាទៅណាទៅណីទេ នេះការសន្និដ្ឋានរបស់ខ្ញុំ។

**ស៖** លោកចាំអ្នកហ្នឹងថាជាអ្នកណាខ្លះទេ?

**ឆ៖** កាលដែលយូរទៅហើយ ចាំអត់បានទេ ខ្ញុំដឹងថាពួកមិត្តស្រេះ អីនេះសុទ្ធតែរត់មិនបានចាប់ទេ រត់ចេញពីកន្លែងនោះ មិនដឹងជាទៅកន្លែងណា មិនដឹងស្លាប់ ឬក៏រស់ទេ។ ដូច្នេះការចាំគឺចាំមិនបានទេ មិនដឹងអ្នកណាទេ វាយូរទៅហើយ។ បាទអរគុណ។

**ស៖** តើមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង តាវ៉ាល់ អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង តាវ៉ាល់ ហ្នឹងនាំគ្នារត់គេចហ្នឹង រត់គេចទៅភ្នំកូនខ្លែងមែនទេ?

**ឆ៖** បាទ ខ្ញុំបាទមិនបានច្បាស់ទេ មិនដឹងជារត់ទៅកន្លែងណាកន្លែងណីទេ។ គឺនៅក្រោមឱវាទនោះ ដល់ពេលចាប់ តាវ៉ាល់ ទៅ ពួកដែលនៅក្រោមអំណាច និយាយទៅដូចសេនាដៃស្តាំក៏ មិនទាន់បានចាប់ ក៏ខ្លាចខ្លួនក៏រត់គេចទៅ។ ប៉ុន្តែអារឿងឆ្ពោះទៅគោលដៅណានោះ តំបន់ណានោះ ខ្ញុំអត់ដឹងទេ។

**ស៖** នៅសម័យនោះ ឬក្រោយមកទៀតលោកធ្លាប់ស្តាប់ឮគេប្រាប់ថា ហេតុអ្វីបានជាគេចាប់ខ្លួនអ្នកជិតស្និទ្ធនឹង តាវ៉ាល់ ទេ? លោកមានដឹងទេ មានឮគេនិយាយរហិចរហៀងថាពីមូលហេតុដែលគេចាប់ខ្លួនអ្នកដែលជិតស្និទ្ធនឹង តាវ៉ាល់ ហ្នឹងទេ?

[១៥:៤៥:៣៩]

**ឆ៖** បាទ គឺបើនិយាយទៅ គឺថាដឹងតាមរយៈមេវរៈ គេថាចាប់អ្នកដែលជិតស្និទ្ធជុំ តាវ៉ាល់ ទៀត ដូច្នេះគឺបានជាពួកនោះរត់ចេញទៅ។ ដូច្នេះការដឹងគឺដឹងថារយៈមេវរៈ។

**ស៖** តើ តាវ៉ាល់ និងអ្នកនៅក្រោមបង្គាប់របស់ តាវ៉ាល់ ត្រូវបានចាប់ខ្លួនហ្នឹង ដោយសារគាត់ប្រព្រឹត្តកំហុស ឬក៏យ៉ាងម៉េច? លោកដឹងទេពីមូលហេតុដែលនាំឲ្យគេចាប់ខ្លួន តាវ៉ាល់ និងអ្នកនៅក្រោមបង្គាប់របស់គាត់នោះ?

**ឆ៖** ខ្ញុំអត់ដឹងទេអារឿងនោះណា មិនដឹងជាយ៉ាងម៉េចទេ ប៉ុន្តែដឹងថាអ្នកដែលនៅក្រោមឱវាទគឺមិនមែនថានៅក្រោមឱវាទឆ្ងាយទេ គឺអ្នកដែលជិតស្និទ្ធជាមួយគាត់ ប៉ុណ្ណោះឯងដែលគេចាប់ខ្លួន។

**ស៖** មានមេកងចល័តមួយបានឆ្លើយជូនអ្នកស៊ើបអង្កេតថា តាវ៉ាល់ ត្រូវបានគេសម្លាប់ចោលពីព្រោះថា តាវ៉ាល់ ហ្នឹងជាឃាតករ។ តើលោកធ្លាប់ឮគេនិយាយអ៊ីចឹងទេ ថាគេសម្លាប់ តាវ៉ាល់ ចោលហ្នឹងដោយសារតែគាត់ហ្នឹងជាឃាតករ?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ ប៉ុន្តែដឹងថាគេចាប់ តាវ៉ាល់ៗ។ ប៉ុន្តែ តាវ៉ាល់ គឺជាឃាតករ ព្រោះបញ្ហានៅក្រោមឱវាទ សេនាដៃស្តាំរបស់គាត់ដែលជិតស្និទ្ធ និយាយទៅថានៅការពារនៅអីនោះឯង មិនដឹងអារឿងចាប់ទៅសម្លាប់អីឯណាឯណី ខ្ញុំអត់ដឹងទេ។

[១៥:៤៨:១៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ដើម្បីឲ្យមានភាពពេញលេញ លោកប្រធានខ្ញុំយោងទៅចម្លើយរបស់សាក្សីមួយរូបនៅក្នុងឯកសារ E3/7805, ERN ជាភាសាអង់គ្លេស 00277815, ជាភាសាខ្មែរ 00267430, ជាភាសាបារាំងគឺ 0031574 *(ស៊ីក)*។

**លោក ត្រាវីស ហ្វារ៖**

លោកប្រធាន ដោយសារតែមានការអត្ថាធិប្បាយដោយមេធាវីការពារក្តី ខ្ញុំសូមបញ្ជាក់ថានៅភាសាអង់គ្លេសគឺ 00277817, ជាភាសាខ្មែរគឺ 00267746 ហើយជាភាសាបារាំង 00315177 គឺ

មានការបញ្ជាក់ថា តាយន់ មកពីនិរតី ត្រូវបានៗចាប់ខ្លួន និងសម្លាប់មនុស្សជាច្រើន ហើយ តាយន់ មកជំនួស តាវ៉ាល់។ ដូច្នេះ តាវ៉ាល់ ដែលជាពេជ្ឈឃាដហ្នឹងត្រូវបានមកជំនួសដោយ តាយន់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាសហព្រះរាជអាជ្ញាកំពុងតែធ្វើការសន្និដ្ឋានជាចុងក្រោយហើយ។ ខ្ញុំនិយាយអំពី តាវ៉ាល់ ទោះបីជាអ្នកជំនួសគាត់ជាប់ពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធខ្ញុំមិនដឹងទេ ប៉ុន្តែនៅទីនេះ គឺមានការបញ្ជាក់ច្បាស់ណាស់ថា តាវ៉ាល់ ត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហម ពីព្រោះថាគាត់ជាឃាតករ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ទោះយ៉ាងណាក៏ដោយលោកសាក្សី។ ខ្ញុំចង់ដឹងថា តើលោកធ្លាប់ឮថា តាវ៉ាល់ និងអ្នកនៅក្រោមបង្គាប់របស់គាត់បានរៀបចំការបះបោរប្រដាប់អាវុធប្រឆាំងនឹងពួកខ្មែរក្រហមដែរឬទេ?

[១៥:៥០:៣១]

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេ អាការបះបោរ បះអីហ្នឹង ខ្ញុំអត់ដឹងទេ មិនដឹងជាយ៉ាងម៉េចទេ។ គ្រាន់តែដឹងថាចាប់ តាវ៉ាល់ ហ្នឹង។ ដល់ពីចាប់ តាវ៉ាល់ ទៅណេះបាន តាយន់ ហ្នឹងឡើងគ្រប់គ្រងក្នុងអាងត្រពាំងថ្មតែម្តង។

**ស៖** សូមអរគុណលោកសាក្សី។ មុននេះនៅពេលដែលគេសួរលោកអំពីអ្នកដែលជាជនជាតិចិនដែលត្រូវបានគេកំណត់មុខសញ្ញា លោកក៏បាននិយាយនៅក្នុងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បានទេថា តើអ្នកដែលមានសែស្រឡាយចិនហ្នឹង គេចាប់ខ្លួនយ៉ាងម៉េច? ហើយវាកើតឡើងនៅពេលណា ហើយលោកដឹងរឿងនេះពីណាដែរ?

**ឆ៖** បាទ គឺការដែលគេជម្លៀសប្រជាពលរដ្ឋពីភ្នំពេញទៅនៅតំបន់នោះទៅ ដូច្នេះគឺគេ -- មិនដឹងជាគេយ៉ាងម៉េចទេ គេស្រាវជ្រាវ ៗទៅបើមានខ្សែចិន ឬក៏ខ្សែវៀតណាម គេនឹងចាប់ដូចខ្ញុំជម្រាបប្រាប់ពីដើមហើយ គេចាប់តែប្តីទេ។ ដល់ក្រោយមកទៀត បានគេប្រាប់ថា ប្តីឲ្យទៅធ្វើការនៅកន្លែងណាមួយនោះ។ ដូច្នេះ គឺត្រូវប្រមូលប្រពន្ធកូននោះយកទៅផង។ ដូច្នេះគេដឹកទាំងឡានយកទៅ។ ឲ្យខ្ញុំដឹងថាយ៉ាងម៉េចនោះ គឺខ្ញុំគ្រាន់តែជម្រាបជូនតែប៉ុណ្ណោះ។

**ស៖** ឥឡូវយើងទុកជនជាតិវៀតណាមមួយឡែកសិន។ ឥឡូវយើងនិយាយអំពីអ្នកដែលជាជនជាតិចិន។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ 00726113 ជាភាសាបារាំង -- ជាភាសាអង់គ្លេស (សូមទោស) ជាភាសាខ្មែរគឺ 00057732។ លោកបានឆ្លើយថា៖

"គ្មានអ្នកណារួចខ្លួនទេ នៅពេលដែលគេដឹងថាជាជនជាតិចិន។ ប្រពន្ធខ្ញុំសម្បុរស គេចោទថាជាជនជាតិចិន ជាកូនចិន ប៉ុន្តែគាត់មិនមែនជាជនជាតិចិនទេ ប៉ុន្តែប្រហែលជាមានខ្សែ ជាប់សែស្រឡាយចិន ក៏មិនដឹង។" លោកបានឆ្លើយបែបនេះ។ តើលោកអាចឆ្លើយបញ្ជាក់ឱ្យបានច្បាស់បន្តិចបានទេពាក់ព័ន្ធទៅនឹងថា អ្នកដែលជាជនជាតិចិនហ្នឹង ត្រូវបានគេកំណត់មុខសញ្ញា? តើលោកឃើញនៅកន្លែងណាដែរ ដែលគេកំណត់មុខសញ្ញាចំពោះជនជាតិចិនបែបនេះនោះ?

[១៥:៥៤:៣៤]

**ឆ៖** បាទ កាលនោះនៅឆ្នាំ១៩៧៨ ដោយខ្ញុំបាទនៅយុវជន ក៏ខ្ញុំក៏មានការស្នើ និយាយទៅថាដណ្ដឹង កាលពីសម័យនោះ គេថាស្នើគូស្រករ ដល់យើងសព្វថ្ងៃថាទៅដណ្ដឹង។ ដល់នេះ មេវរៈរបស់ខ្ញុំគឺឈ្មោះ តានិន។ តានិន នោះអតីតពីដើមគាត់ខាងយោធាមកពីខាងនិរតី ហើយនិង តានិន នៅប្រធានវរៈជុំគ្នា។ ដល់ពេលនេះដក តានិន ចេញពីកន្លែងខ្ញុំ បានទៅកាន់កងនេសាទខាងប្រពន្ធខ្ញុំ។ គាត់ក៏បានដឹងព័ត៌មាននេះថាខ្ញុំដណ្ដឹងប្រពន្ធខ្ញុំមែន។ ដល់ពេលទៅឃើញប្រពន្ធខ្ញុំស ហើយគេស្រែកថា ចិន ហើយខ្ញុំក៏បានជម្រាបប្រាប់ តានិន ដែលជាប្រធានវរៈថាមិនមែនចិនទេ គឺអ្នកភូមិជុំគ្នា បើលោកឯង -- បើសិនជាបងឯងចង់ដឹង ស្រាវជ្រាវចុះណ៎ា គឺគ្នាខ្មែរសុទ្ធសាធ។ អានេះសំដៅតែលើប្រពន្ធខ្ញុំដែលជាស។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ លោកបានប្រើប្រាស់ឧទាហរណ៍មួយ គឺនៅពេលដែលលោកជួបជាមួយនឹងប្រពន្ធរបស់លោក។ ក៏ប៉ុន្តែនៅក្នុងឯកសារទំព័រដដែលនោះ លោកបាននិយាយថាមានឡានដឹកយកជនជាតិចិន យកទៅកម្ទេចចោល។ តើលោកមានសំអាងអី បានជាលោកប៉ានិយាយបែបហ្នឹង? លោកមានប្រភពបែបមកពីណា ថាគេដឹកជនជាតិចិនហ្នឹងទាំងឡានៗយកទៅកម្ទេចចោល?

[១៥:៥៦:៤៧]

**ឆ៖** បាទ ព្រោះគេដឹកយកទៅ ប្រពន្ធកូននោះទៅវាបាត់ដំណឹងជ្រាបណ៎ា មិនដឹងជាទៅទៅណាទៅណី។ ដូច្នេះការសន្និដ្ឋានរបស់ខ្ញុំ ប្រហែលជាគេយកទៅសម្លាប់ចោល ប៉ុន្តែមិនដឹងថាគេយកទៅដាក់គុក ឬក៏ដាក់ម៉េចទេ វាបាត់ពីកន្លែងនោះ។ បាទ អានេះការសន្និដ្ឋានរបស់ខ្ញុំ។ សូមអស់។

**ប្រធានអង្គជំនុំ៖**

សាក្សីសូមបញ្ជាក់ឡើងវិញ យើងបានប្រាប់អំពីករណីយកិច្ចរបស់សាក្សីហើយ ឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ បានមានបទពិសោធន៍ជួបប្រទះដោយផ្ទាល់នូវព្រឹត្តិហេតុណ៍ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ។ លោកមិនគប្បីឆ្លើយចម្លើយតប

នូវការសន្និដ្ឋានរបស់លោកទេ។ ការសន្និដ្ឋានគឺស្មាន គឺការប៉ាន់ស្មានមិនឆ្លើយតបទៅនឹងតម្រូវការនៃអង្គជំនុំជម្រះដែលចង់បាន ដើម្បីស្វែងរកការពិតទេ។ នេះសូមរំឭកឡើងវិញ។ នៅក្នុងករណីគឺថាមិនដឹង គឺឆ្លើយថាមិនដឹង ហើយក្នុងករណីដឹងកម្រិតណា គឺឆ្លើយតែកម្រិតដែលលោកដឹងបានហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងប្រធានបទនេះ លោកសាក្សីខ្ញុំសួរលោកបែបនេះដោយសារតែខ្ញុំមិនដែលស្តាប់ឮអ្នកណាម្នាក់និយាយថា ជនជាតិចិនត្រូវបានគេនាំយកទៅកម្ទេចចោលទាំងឡានៗនោះទេ។ តើរឿងនេះគឺលោកប្រឌិតឡើងដោយខ្លួនឯងមែនទេ?

[១៥:៥៨:៣៨]

**លោក តក់ ប៊ុយ៖**

**ឆ៖** បាទ មិនមែនប្រឌិតទេ និយាយដូចប្រធាននិយាយអំមិញថា មិនដឹង នោះល្អម្យ៉ាង ព្រោះឃើញតែគេដឹកទៅប៉ុណ្ណោះឯង។ មិនដឹងជាយ៉ាងម៉េចទេ ខ្ញុំមិនដឹងទេ និយាយឲ្យខ្លី ស្តាប់បាន។

**ស៖** ចុះម៉េចក៏លោកដឹងថា អ្នកដែលនៅក្នុងឡានទាំងអស់ហ្នឹងជាជនជាតិចិន?

**លោក ត្រាវីស ហ្វារ៖**

នៅក្នុងឃ្លានោះគាត់និយាយថា មានទាំងជនជាតិចិន និងជនជាតិវៀតណាម។ ហើយគាត់សួរហ្នឹង គឺដដែលៗគឺតែពាក់កណ្តាលឃ្លាទេ គាត់បានកាត់ឃ្លាខ្លះ ពាក្យខ្លះចេញនៅក្នុងឃ្លា។ អ៊ីចឹងអាចធ្វើឲ្យសាក្សីអាចភ័ន្តច្រឡំ។

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់ក៏បាននិយាយអំពីជនជាតិចិន និយាយអំពីប្រពន្ធរបស់គាត់ គាត់និយាយអំពីឡានដឹកជនជាតិចិនទៅទាំងឡានៗ។

[១៦:០០:០០]

**លោក ត្រាវីស ហ្វារ៖**

គាត់និយាយថា ជនជាតិចិន ឬក៏ជនជាតិវៀតណាម ត្រូវបានដឹកយកទៅកម្ទេច។ អ៊ីចឹងត្រូវតែមានពាក្យវៀតណាមផង មិនត្រូវនិយាយតែពាក្យចិនទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែខ្ញុំមិនចាប់អារម្មណ៍ទៅលើជនជាតិវៀតណាមទេ ខ្ញុំចាប់អារម្មណ៍តែទៅលើជនជាតិចិនតែប៉ុណ្ណោះ។ អ៊ីចឹងហើយបានជាខ្ញុំសួរពាក់ព័ន្ធទៅនឹងជនជាតិចិន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី អ្នកដែលនៅក្នុងឡាននោះ ម៉េចបានជាលោកដឹងថា ពួកគាត់ហ្នឹងជាជនជាតិចិន?

**លោក តក់ ប៊ុយ៖**

**ឆ៖** អានេះមិនដឹងទេ ប៉ុន្តែខ្ញុំដឹងតាមអ្នកជិតខាងនៅក្នុងភូមិ គេថាប្រមូលពួកចិន។ អានោះការស្រាវជ្រាវរបស់ពួកកងឈ្លប ឬក៏ប្រធានសហករណ៍ ឬក៏មេភូមិ គេប្រមូល។ មិនដឹងជាគេមើលយ៉ាងម៉េច យ៉ាងណានោះ ខ្ញុំមិនដឹងទេ។ ឃើញគេដឹកចេញ ឃើញប្រពន្ធកូនរៀបចំអីវ៉ែអីវ៉ាន់ ចានឆ្នាំងឡើងឡាន តែអារឿងទៅត្រង់ណាខ្ញុំ អត់ដឹងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

[១៦:០១:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗលោក វ៉ិចទ័រ កូប៉េ។ អរគុណលោកសាក្សី ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២០ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី តក់ ប៊ុយ បញ្ចប់ ហើយនិងផ្ដើមស្ដាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-841 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក តក់ ប៊ុយ។ ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួន។ ហើយឥឡូវនេះ លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

ជូនលោក តក់ ប៊ុយ ត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ និងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន ឲ្យគាត់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការតែម្តង ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញ នៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*